# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណាំងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៨ លេខ ៨ ខែសីហា ព.ស.២៤៩៩ គ.ស.១៩៥៦

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — សន្ដោសកថា ............ | យុទ្ធបណ្ណានុរក្ស ប៊ូ-ប៉ូ ....... | ៧០៣ |
| — ប្រជុំធម៌ឧបាសក (ត-ចប់)....... | ព្រះទេពសត្ថា កិម-តួរ ....... | ៧១២ |
| — ទោសនៃសុរា ............ | ព្រិទ្ធបាលទោ ឆា-ប៉ូរ........ | ៧២៩ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — សេចក្ដីសុខនឹងសេចក្ដីចំរើនរបស់ប្រទេស តែងប្រព្រឹត្តទៅជាមួយនឹងវប្បធម៌ .... | លោក រ៉ាយ-ប៊ុក ........... | ៧៣៣ |
| — ពេជ្រព្រះរាជា (តមក) ........ | លោក ស៊ុន-ហ៊ាន ប្រែ ..... | ៧៤៥ |
| — រឿងសាមកុក (តមក) ....... | ឧកញ៉ា នូ-កន ......... | ៧៥៥ |
| — រឿងបល្ល័ង្កទិព្យ (តមក) ...... | លោក រ៉ាយ-ប៊ុក ប្រែ ...... | ៧៦២ |
| — រឿងកូនភ្លោះ .......... | អ្នកស្រី សារិះយ៉ាន់ ប្រែ.... | ៧៦៧ |
| — រឿងសៅរ៍សោយ (ត-ចប់) ...... | ព្រះមហាឧត្ដមវិជ្ជា ប៊ុង-ប៉ម ប្រែ... | ៧៧៧ |
| — សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ .. | លោក ចាប-ពិន ........ | ៧៨៥ |
| **កំណត់និងប្រវត្តិការណ៍** | | |
| — មន្ទីរពេទ្យព្រះសង្ឃ ខេត្រតាកែវ (ត-ចប់) | ពុទ្ធសាសនបណ្ឌិត្យ........ | ៧៩០ |

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២៣០រ,០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

### PARTIE RELIGIEUSE:

*Page*

— Santosakatha . . . . . . . *par M. BOU-PO . . . . . 703*

— Recueil des disciplines Bouddhiques des fidèles (suite et fin) *par Vénérable KEM-TO . . . 712*

— Les conséquences de l'alcool . *par M. CHEA-PO . , . . . . 729*


### PARTIE LITTÉRAIRE:

— La culture est la base du progrès. *par M. RAY-BUC . . . 733*

— Conte "Le Diamant du Raja" (suite) . . . . . . . . . . *Traduit par M. SIN-HEAN* 745

— Histoire du Samkok (suite) . . *Traduit par M. NOU-KAN. 755*

— Les trente-deux récits du Trône (suite) . . . . . . . *Traduit par M. RAY-BUC . 762*

— Histoire de deux frères jumeaux *par Mme. SARIS-YANN . . 767*

— Le "Sau-Soy" ou l'influence saturnienne (suite et fin) . . . *par Vénérable PEUNG-PAM 777*

— Activités de la Commission des Mœures et Coutumes . . *par M. CHAP-PIN . . . . 785*


### NOTES ET CHRONIQUES:

— L'hôpital des Bonzes dans la Province de Takeo (suite et fin) *par l'Institut Bouddhique . . . 790*


Prix d'abonnement annuel (comprenant 12 numéros) 230$00

## ផ្នែកសាសនា

# សន្ដោសកថា

ឃុនបណ្ឌានុរ័ក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

---

*ខ្ញុំធ្លាប់បានឮអ្នកខ្លះនិយាយបន្ទោសព្រះពុទ្ធសាសនាថា* "ពុទ្ធ-សាសនាធ្វើឲ្យមនុស្សខ្ជិល, ឲ្យល្ងង់ខ្លៅ, ធ្វើឲ្យស្រុកទេសអាប់ឱនមិនចំរើន ព្រោះព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យកាន់ធម៌សន្ដោស ។ មើលចុះមនុស្សជាតិខ្មែរច្រើនតែខ្ជិល, ច្រើនតែល្ងង់ខ្លៅ, ស្រុកខ្មែរអាប់ឱនមិនចំរើនដូចស្រុកគេ ។ ហេតុតែជាតិខ្មែរកាន់ធម៌សន្ដោស បានជាខ្មែរទម្រន់, ខ្ជិលច្រអូស, មិនខំធ្វើការ, មិនចង់មានបាន, ចេះតែបណ្ដោយឲ្យជនបរទេសចូលមកលុកលុយដណ្ដើមយកការងារក្នុងប្រទេសខ្លួនបាន ។ ជាតិខ្មែរចេះតែចាញ់ប្រៀបជនបរទេសគ្រប់អន្លើ តាំងពីផលដំណាំរហូតដល់សេដ្ឋកិច្ចជាតិធ្លាក់ដុនដាបងើបមិនរួច មកពីជាតិខ្មែរកាន់ពុទ្ធសាសនា ហើយធ្វើតាមធម៌សន្ដោស" ។

ខ្ញុំសូមឆ្លើយតបនឹងពាក្យបន្ទោសខាងលើនេះថា " ជាតិខ្មែរអ្នកពុទ្ធសាសនា មិនយល់ព្រមទទួលថាព្រះពុទ្ធសាសនាប្រដៅមនុស្សឱ្យអន់ទន់ទាបដូចជាពាក្យបន្ទោសនោះទេ ។ ឯពាក្យបន្ទោសនោះផ្ទុយនឹងព្រះពុទ្ធសាសនាស្រឡះ បើបន្ទោសចំពោះលើរូបមនុស្សអ្នកកាន់ពុទ្ធសាសនាវិញទើបត្រឹមត្រូវជាង ព្រោះថាធម្មតាសាសនាទាំងអស់ សុទ្ធតែមានវត្ថុបំណងក្នុងការដឹកនាំមនុស្សទៅរកសេចក្តីសុខ និងសេចក្តីចំរើនដូចគ្នា ចុះបើអ្នកកាន់សាសនានោះ នៅតែបានទុក្ខទោសវិនាសទៀត នោះមិនមែនមកពីសាសនានាំឱ្យទុក្ខទេ គឺមកតែពីអ្នកនោះឯងមិនធ្វើឱ្យទៀងទាត់ត្រឹមត្រូវតាមសាសនា ។

បើតាមយោបល់ខ្ញុំថា " ខ្មែរយើងដែលជាអ្នកកាន់ព្រះពុទ្ធសាសនា មិនមែនសុទ្ធតែខ្ជិល, សុទ្ធតែល្ងង់ខ្លៅទាំងអស់គ្នាទេ មានអ្នកឧស្សាហ៍, អ្នកចេះដឹងដែរ មិនខុសគ្នាពីជាតិដទៃប៉ុន្មាន ទាំងស្រុកទេសក៏មិនសុទ្ធតែអាប់ឱនដែរ មានចំរើនទៅដល់ថ្នាក់មហាអំណាចផង តាមកាលៈទេសៈ និងតាមធាតុទឹកដីអាកាសផ្សំគ្នាជួយជាកំឡាំង " ។

ខ្ញុំសូមអធិប្បាយអំពីធម៌សន្តោស ។ ពាក្យថា " សន្តោស " ជាភាសាបាលី ប្រែថា " សេចក្តីត្រេកអរឬពេញចិត្ត ចំពោះវត្ថុផ្សេងៗ ដែលជារបស់ខ្លួន " គឺថា បើមាន បើបានប៉ុន្មាន ក៏ល្មមចិត្តត្រឹមប៉ុណ្ណោះ មិនរវេះរវាម មិនរាគអាធិ ហួសហេតុហួសទំនង ។

ត្រង់ពាក្យថា " បើមាន បើបានប៉ុន្មាន ក៏ល្មមចិត្តត្រឹមប៉ុណ្ណោះ " មិនមែនបង្គាប់ឱ្យឈប់ស្ងៀមលែងធ្វើការរកស៊ីទេ គឺត្រូវតែមានព្យាយាម

ទំរកទ្រព្យថ្មីតទៅទៀត របៀបដូចសូម បើគេឲ្យប៉ុន្មានក៏សុខចិត្តទទួលយកប៉ុណ្ណោះមិនហ៊ានប្រកែក ហើយទំដើរទៅសូមគេខានមុខទៀតមិនឈប់ ៗ អ្នកមានទ្រព្យសម្បត្តិរបស់ខ្លួនស្រាប់ហើយ ហើយនៅតែប្រឹងប្រែងស្វែងរកឲ្យបានទ្រព្យសម្បត្តិថ្មីថែមមកទៀត ដោយត្រឹមត្រូវតាមផ្លូវច្បាប់លោកនិងច្បាប់ធម៌ ចាត់ជាអ្នកកាន់ធម៌សន្តោស ៗ អ្នកណាកុហកបញ្ឆោតបោកប្រាស់លួចលាក់បំបាត់ យកទ្រព្យគេមកធ្វើជាទ្រព្យខ្លួន អ្នកនោះចាត់ជាមនុស្សគ្មានធម៌សន្តោស ៗ ហេតុនោះព្រះពុទ្ធសាសនាបញ្ញត្តសីលសិក្ខាបទទី ២ (អទិន្នាទាន) កុំឲ្យលួចលាក់ទ្រព្យគេមានម្ជុលនិងបេសជាដើមនោះ ដើម្បីឲ្យកើតធម៌សន្តោស, មើលចុះ ការលួចប្លន់ឆបោកគ្នាកើតមានជាពល់ថ្ងៃមិនដាច់ មិនមែនកើតមកពីហេតុអ្វីទេ កើតមានមកតែអំពីមនុស្សអ្នកឥតធម៌សន្តោសប៉ុណ្ណោះ ៗ បើមនុស្សត្រប់រូបមានសន្តោសហើយ អំពើចោរកម្មនោះក៏គ្មានដែរ ៗ អ្នកហ៊ានសម្លាប់គេ, ហ៊ានលួចទ្រព្យគេ, ហ៊ានលួចប្តីប្រពន្ធគេ, ហ៊ាននិយាយកុហកគេ, ហ៊ានផឹកទឹកស្រវឹង មកពីគ្មានចិត្តសន្តោស ៗ អ្នកឥតសន្តោសឈ្មោះថាធ្វើបាបខ្លួនឯង និងបៀតបៀនអ្នកដទៃឲ្យបានទុក្ខទោស រហូតដល់ធ្វើស្រុកទេសឲ្យអាប់ឱន ធ្វើសេដ្ឋកិច្ចជាតិឲ្យធ្លាក់ខ្សត់ខ្សោយ ៗ

ព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យកាន់ធម៌សន្តោស ដើម្បីធ្វើខ្លួននិងអ្នកឯទៀតឲ្យបានសុខចំរើន ៗ ព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យចេះស្វែងរកប្រយោជន៍ក្នុងបច្ចុប្បន្ន ៤ យ៉ាងគឺ ៖

១– ឲ្យខំរកទ្រព្យសម្បត្តិឲ្យបានច្រើន (ឧដ្ឋានសម្បទា);

២– ឲ្យចេះថែរក្សាទ្រព្យទុកឲ្យល្អ (អារក្ខសម្បទា);

៣ ឲ្យចេះចាយវាយទ្រព្យល្មមប្រមាណ (សមជីវិតា);

៤– ឲ្យសេពគប់មនុស្សល្អជាមិត្រ (កល្យាណមិត្តតា) ។

ព្រះពុទ្ធសាសនាមានពាក្យប្រៀនប្រដៅមនុស្សច្រើនប្រការណាស់ មិនអាចនឹងយកមកពណ៌នាឲ្យចប់បានទេ ។ ពាក្យប្រដៅទាំងនោះមានរបៀបប្លែកៗគ្នាទៅតាមភូមិតាមភេទ បើភេទគ្រហស្ថត្រូវកាន់ធម៌បែបនេះ បើភេទបព្វជិតត្រូវកាន់ធម៌បែបនោះ ។ បើគ្រហស្ថចង់បានទ្រព្យសម្បត្តិ ឬយសសក្តិក្នុងបច្ចុប្បន្នជាតិនេះត្រូវកាន់ធម៌ដូច្នេះ បើគ្រហស្ថចង់បានស្ថានសួគ៌ ឬព្រះនិព្វានត្រូវកាន់ធម៌ដូច្នោះ គោលធម៌ទាំងនោះមានសេចក្តីល្អិតពិស្តារនៅក្នុងព្រះសុត្តន្តបិដក ។

ព្រះពុទ្ធសាសនាតែងតែលើកតំកើងសរសើរគុណនៃសេចក្តីព្យាយាមជាទីបំផុតថា "មនុស្សនឹងចួងឲ្យផុតពីទុក្ខទោសទៅបានដោយសារតែសេចក្តីព្យាយាម" ហើយតិះដៀលសេចក្តីខ្ជិលច្រអូសថា "កុំធ្វើឲ្យជាមនុស្សចង្អៀតលោក, មនុស្សមិនត្រូវប្រគល់ខ្លួនទាំងមូលឲ្យគេទេ, មនុស្សមិនត្រូវរស់នៅដោយសារគេទេ" ប៉ុណ្ណេះជាដើម ។

ជនជាតិខ្មែរអ្នកកាន់ពុទ្ធសាសន៍ មិនចេះធុញទ្រាន់ទឹងព្រះពុទ្ធសាសនាទេ ទាំងកាន់ព្រះពុទ្ធសាសនាទៀតក៏ដោយការស្ម័គ្រចិត្តពិតប្រាកដ មិនបាច់មានគេមកបង្ខិតបង្ខំឡើយ ព្រោះមនុស្សប្រុសជាតិខ្មែរបានបួសរៀនស្ទើរតែគ្រប់គ្នា ធ្លាប់ចេះដឹងហើយថា ព្រះពុទ្ធសាសនាមានគោល

ច្បាប់យ៉ាងត្រឹមត្រូវណាស់ ព្រះពុទ្ធសាសនាជាឃ្លាំងសម្រាប់ផ្ទុកនូវឱវាទដំបូន្មានគ្រប់មុខឥតខ្វះ ដូចជាច្បាប់រក្សាខ្លួន, ច្បាប់រក្សាគ្រួសារ, ច្បាប់សម្រាប់មុខមន្ត្រីនិងព្រះមហាក្សត្រ ។ល។

អ្នកពុទ្ធសាស្ន៍គ្រប់ជាតិ មិនតែជាតិខ្មែរមួយទេ តែងបានដឹងវត្ថុបំណងរបស់ព្រះពុទ្ធសាសនាច្បាស់លាស់ហើយ បានជាខំកាន់ធម៌សន្តោស ព្រោះយល់ឃើញថាធម៌សន្តោសនេះមានផលប្រយោជន៍យ៉ាងធំទូលាយណាស់ អាចដឹកនាំខ្លួនឯងនិងអ្នកឯទៀតឲ្យបានសុខសប្បាយ រហូតដល់ធ្វើស្រុកទេសឲ្យបានចំរើនរុងរឿង មិនឲ្យមានការទាស់ទែងខ្វែងគំនិតគ្នា, មិនឲ្យបៀតបៀនគ្នា, មិនឲ្យមានសឹកសង្គ្រាមកាប់សម្លាប់គ្នា ។ ចំណែកអ្នកបន្ទោសព្រះពុទ្ធសាសនាថាប្រដៅមនុស្សឲ្យល្ងង់ជាដើមនោះ សូមជ្រាបថា មិនមែនព្រះពុទ្ធសាសនាប្រដៅមនុស្សឲ្យល្ងង់ទេ គឺល្ងង់ពីមនុស្សដែលមិនព្រមរៀនធ្វើតាមឱវាទរបស់ព្រះពុទ្ធសាសនានោះទេតើ ប្រៀបដូចគ្រូចង់ឲ្យសិស្សចេះបានប្រឹងបង្ហាត់បង្រៀនណាស់ ប៉ុន្តែបើសិស្សមិនខំរៀនសោះ សិស្សនោះក៏នៅជាល្ងង់ទៀតទៅ ដូច្នេះតើនឹងបន្ទោសគ្រូឯណាបាន ។

ពួកពុទ្ធសាស្ន៍មិនអាក់អន់ចិត្តនឹងអ្នកបន្ទោសទេ ព្រោះសំគាល់ថា ពាក្យបន្ទោសនោះជាគុណជាប្រយោជន៍ អាចទាញទឹកចិត្តអ្នកកាន់ពុទ្ធសាសនាឲ្យរឹតតែខំប្រឹងកាន់ធម៌សន្តោសនោះទៅច្រើនឡើងទៀត ។

# រឿងអ្នកគ្មានសន្ដោស

ទុកាសនេះសូមនាំរឿងអ្នកគ្មានសន្ដោសមកដំណាលថា កាលពីព្រេងនាយ[១] មានបុរោហិតម្នាក់របស់ព្រះបាទពារាណសី ចេះមន្តបឋវីជ័យ គឺមន្តសំរាប់បញ្ចូលចិត្តអ្នកដទៃឲ្យនៅក្រោមអំណាចខ្លួន ៗ ថ្ងៃមួយ បុរោហិតនោះចូលទៅក្នុងព្រៃស្ងាត់អង្គុយលើផែនថ្មមួយផ្ទាំងសូត្ររំលឹកមន្តចប់ហើយ ក្រោកដើរចេញមកវិញ ។ បានជាបុរោហិតមិនហ៊ានសូត្ររំលឹកមន្តក្នុងផ្ទះ ព្រោះខ្លាចក្រែងគេឮទីងចេះចាំមន្តដូចខ្លួនដែរ ។ ក្នុងពេលដែលបុរោហិតកំពុងសូត្ររំលឹកមន្តនោះ មានចចកមួយដេកក្នុងរូងឈើក្បែរថ្មដែលបុរោហិតអង្គុយនោះ ស្ដាប់ឮមន្តនោះហើយក៏ចាំបាន ទើបចូលទៅក្នុងព្រៃសូត្ររាយមន្តនោះឡើង ហៅចចកជាច្រើនឲ្យមកប្រជុំគ្នា វាធ្វើសព្វសត្វចតុប្បាទដូច ដំរី, សេះ, សីហ:, ខ្លាធំ, ខ្លាឃ្មុំ, ទីងម្រឹគជាដើម ឲ្យនៅក្នុងអំណាចខ្លួនបានហើយ ក៏តាំងខ្លួនឯងជាព្រះរាជាមាននាមថា "សព្វទាឋ:" ព្រមទាំងអភិសេកមេចចកមួយ ឲ្យធ្វើជាអគ្គមហេសី ហើយបង្គាប់ឲ្យដំរីពីរឈរទន្ទឹមគ្នា ឲ្យសីហ:មួយឡើងទៅឈរនៅលើខ្នងដំរីទាំងពីរនោះ ឯខ្លួនឯងនាំមហេសីឡើងទៅអង្គុយលើខ្នងរាជសីហ៍មួយជាន់ទៀត សោយរាជ្យជាស្ដេចលើសត្វចតុប្បាទក្នុងព្រៃទាំងអស់ ។

ស្ដេចចចកសព្វទាឋ: សូម្បីមានឫទ្ធិអំណាចយសសក្តិធំដល់ម្ល៉ោះហើយក៏នៅតែមិនស្កប់ស្កល់ កើតចិត្តព្រហើនកោងកាចលោភចង់បាន

---

១) សព្វទាឋជាតក ទសមវគ្គ ទុកនិបាត ។

ហួសប្រមាណខុសច្បាប់លោកច្បាប់ធម៌ គឺគ្មានចិត្តសន្តោសសោះ ហ៊ាន លើកកងទ័ពសត្វបក្សាទ មានចំនួនប្រមាណ ១២ យោជន៍ ទៅពីនគរ ពារាណសី ប្រុងច្បាំងដណ្តើមយករាជសម្បត្តិ ប្រើទូតឲ្យកាន់រាជសាស្ន៍ ចូលទៅថា ព្រះបាទពារាណសីនឹងឲ្យរាជសម្បត្តិមកយើង ឬចេញច្បាំង ជាមួយយើង ប្រាប់ឲ្យឆាប់ ៗ ពួកអ្នកនគរមានសេចក្តីភិតភ័យតក់ស្លុត ខ្លាំងណាស់ នាំគ្នាបិទទ្វារនគរជិតអស់ ៗ បុរោហិតក្រាបទូលសម្រួល ព្រះទ័យព្រះរាជា នឹង សម្រួលចិត្តអ្នកនគរទាំងឡាយឲ្យសប្បាយរីករាយ ហើយទទួលធានាថា ការច្បាំងនឹងស្តេចបបកស្រេចលើខ្លួន ទើបឡើង ទៅលើប៉មស្រែកសួរបបកថា នែសត្វទាបៈសំឡាញ់! អ្នកនឹងធ្វើឧបាយ ដូចម្តេច ទើបដណ្តើមយករាជសម្បត្តិបាន ៗ ស្តេចបបកឆ្លើយថា យើង នឹងឲ្យរាជសីហ៍ស្រែកសម្រែកឲ្យពួកមនុស្សបែកត្រចៀកស្លាប់ ហើយ ដណ្តើមយករាជសម្បត្តិ ៗ

បុរោហិតឮដូច្នោះហើយចុះពីប៉មមកវិញ ប្រើមនុស្សឲ្យវាយស្គរ ប្រកាសប្រាប់អ្នកនគរថា អ្នកទាំងឡាយចូរយកសំឡីចុកត្រចៀកឲ្យជិត គ្រប់គ្នា ៗ អ្នកនគរក៏យកសំឡីចុកត្រចៀករៀងខ្លួន ព្រមទាំងចុកត្រចៀក សត្វជើងបួនដូចដំរី, សេះ, គោ, ក្របី, ឆ្កែ, ឆ្មាជាដើម ៗ លុះអ្នកស្រុក ចុកត្រចៀកស្រេចហើយ បុរោហិតឡើងទៅលើប៉មម្តងទៀត និយាយ បញ្ឆឺចិត្តបបកឲ្យខឹងថា នែរចៅសត្វទាបៈមុខក្រាស់អើយ! ឯងប្រើ រាជសីហ៍ឲ្យកំហឹងសម្រែងមិនបានទេ ព្រោះជាធម្មតាកេសររាជសីហ៍ ជា សត្វមានជាតិខ្ពង់ខ្ពស់ណាស់ មានជើងមុខនឹងជើងក្រោយដ៏ក្រហម កាល

ណា នឹងធ្វើតាមបង្គាប់របស់ចចកចាស់ដូចជាខ្លួនឯងនេះកើត បើថាឯងត្រាន់បើណាស់ បើប្រើរាជសីហ៍ឲ្យស្រែកបាន ឯងចូរប្រើឲ្យស្រែកទៅមើល យើងឥតខ្លាចបន្តិចសោះ ។

ស្តេចសត្វតាបៈចចកឮដូច្នោះខឹងប្រឡាត កើតចិត្តមានៈព្រហើន ស្រែកប្រកាសដល់បណ្តារាជសីហ៍ថា "សីហៈឯទៀតចូរឈប់សិនចុះ កុំអាលស្រែក ឲ្យតែរាជសីហ៍ ១ ដែលយើងអង្គុយលើខ្នងនេះស្រែកមុនគេ" ថាហើយក៏តទ្រិះជើងធាក់ខ្នងរាជសីហ៍ ។

រាជសីហ៍ឮស្តេចចចកប្រាប់ដូច្នោះ ក៏ដាក់មាត់ខ្ទប់ទៅលើពោងដំរី ហើយស្រែក ៣ ដងដោយធ្វើសម្រែកយ៉ាងខ្លាំងអស្ចារ្យ ដែលសត្វឯទៀតមិនអាចនឹងស្រែកត្រាប់បាន ។ ឯដំរីភ័យស្លុតស្លាំងកាំង, ស្តេចសត្វតាបៈចចកនឹងមហេសីដាំក្បាលធ្លាក់ចុះពីខ្នងរាជសីហ៍ ទៅនៅក្បែរជើងដំរី ។ ស្រុះប្រឡាតជាន់ក្បាលចចកបែកល្អិតខ្ទេចខ្ទីស្លាប់មួយរំពេច ។ បណ្តាដំរីទាំងឡាយកើតភិតភ័យតក់ស្លុតដាលច្រួលច្របល់ដេញព្រៀតជ្រួតជាន់គ្នាឯងស្លាប់អស់ ។ ចំណែកសត្វចតុប្បាទទាំងពួងក្រៅពីរាជសីហ៍ ក៏ស្លាប់នៅទីនោះទាំងអស់ សល់តែហ្វូងរាជសីហ៍នាំគ្នាបោលចូលព្រៃបាត់អស់ទៅ ។ សាច់សត្វដែលស្លាប់មានចំនួនប្រមាណដល់ ១២ យោជន៍ ក៏នៅគរគ្នាដេរដាសពាសពេញទីនោះ ។

បុរោហិតឃើញដូច្នោះ ប្រើមនុស្សឲ្យវាយស្គរប្រកាសប្រាប់អ្នកនគរថា បើអ្នកណាត្រូវការសាច់សត្វ ចូរមកដឹកជញ្ជូនយកទៅតាមចិត្តចុះ ។ មនុស្សទាំងពួងនាំគ្នាដឹកជញ្ជូនយកសាច់សត្វទៅបរិភោគរាល់ខ្លួន

សាច់ដែលសល់ក៏ធ្វើជាងៀតហាលឲ្យស្ងួតគ្រៀម ទុកបរិភោគទៅថ្ងៃមុខទៀត ។ ហេតុនោះមានលោកខ្លះប្ញលចិត្តថា សាច់ងៀតកើតមានឡើងតាំងពីគ្រានោះជាដើមមក ។

## រឿងនេះបានគតិ:

១– យើងមិនត្រូវមើលងាយការងារនឹងមនុស្សស្មូគទេ ។

២– យើងមិនត្រូវចង់បានយសសក្តិធំហួសសមត្ថភាពខ្លួនទេ ។

៣– យើងមិនត្រូវចង់បានវត្ថុអ្វីៗដែលផុតនិស្ស័យខ្លួនប្រាថ្នាទេ ។

៤– យើងត្រូវមានចិត្តសន្តោស គឺត្រេកអរតែនឹងសម្បត្តិរបស់ខ្លួនតាមមានតាមបាន, ។

ព្រោះបើស្វែងរកទ្រព្យសម្បត្តិ ឬប្រាថ្នាបុណ្យស័ក្តិត្រូវតាមថ្នាក់ខ្លួននោះរមែងបានចំរើន ។ បើស្វែងរកទ្រព្យ ឬចង់បានបុណ្យស័ក្តិហួសថ្នាក់ខ្លួនហើយ រមែងវិនាសខ្លូវលាភ ទំនងយស់ចាស់ផង ខានបានលាភ ទំនងយសថ្មីទៀតផង ដូចជាស្តេចចចកស្មូគទាប: ត្រូវខូចខាតលាភនិងយសហេតុដល់ជីវិតខ្លួនដែលជាទីស្រឡាញ់យ៉ាងក្រៃលែង សមដូចសុភាសិតថា "ចបើងចង់លាភ វែងបាត់ធនទៅ" ។

# ប្រជុំធម៌ឧបាសក

## ប្រស្នាសួរ-ឆ្លើយ

ព្រះទេពសត្ថា ភិម-ត៊ូ បន្ទមង្គលោ

ក្រុមជំនុំព្រះត្រៃបិដកក្នុងពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

(ត-ចប់)

ស. សីលនេះ បង្ហាញផលឲ្យឃើញប្រាកដឡើងដូចម្ដេច ដែលអាចឲ្យគេសំគាល់បានថា មនុស្សនេះជាអ្នកមានសីល មនុស្សនោះជាអ្នកមិនមានសីល?

ឆ. បើបុគ្គលណាជាអ្នកមានសីល, សីលតែងធ្វើបុគ្គលនោះឲ្យជាអ្នកស្អាតកាយ ស្អាតវាចា ស្អាតចិត្ត, តែបើមិនស្អាតកាយវាចាចិត្តទេ ត្រូវដឹងថាមិនមែនជាអ្នកមានសីលឡើយ ។

ស. គួរឲ្យចង់ដឹងថា ចុះសីលដែលមិនទាន់កើតនៅឡើយ ហើយអាចកើតឡើងបាន ដែលកើតឡើងហើយ ក៏អាចតាំងនៅដោយបរិសុទ្ធ មិនមានបែកធ្លុះធ្លាយទៅវិញ តើដោយមានអ្វីជាហេតុ?

ឆ. ដោយមានធម៌ ២ យ៉ាងជាហេតុ ។

ស. ធម៌ ២ យ៉ាងនោះអ្វីខ្លះ?

ឆ. ធម៌ ២ យ៉ាងនោះ គឺ

១ — ហិរិ ធម្មជាតិដែលអៀនខ្មាសចំពោះអំពើទុច្ចរិត

២– និត្តប្បៈ ធម្មជាតដែលខ្លាចតក់ស្លុតចំពោះផលរបស់អំពើទុច្ចរិត ។

អធិប្បាយ : កាលបើធម៌ទាំង ២ យ៉ាងនេះ មានទៅក្នុងសន្តាននៃបុគ្គលណាហើយ ទុកជាបុគ្គលនោះមិនទាន់បានរក្សាសីលនៅឡើយ ក៏ទីងរកអាក់ខានមិនកើត មុខជានឹងស្ទុះស្ទាំប្រឹងរក្សាត្រាតែបាន; កាលបើបានរក្សាសីលហើយ ទុកជាមានហេតុដល់ស្លាប់ជីវិតក៏មិនប្រថុយទំលាយនូវសីលរបស់ខ្លួនឡើយ ។

ស. សីលដាច់មានប៉ុន្មានយ៉ាង?

ឆ. មាន ២ យ៉ាងគឺ ដាច់មានទោស ១ ដាច់មិនមានទោស ១ ។

ស. គួរឲ្យចង់ដឹងថា ដាច់មានទោសនោះដូចម្តេច? ដាច់មិនមានទោសនោះដូចម្តេច?

ឆ. ដាច់មានទោសនោះ គឺការប្រព្រឹត្តកន្លងឲ្យខូចសិក្ខាបទទាំងអស់ឬសិក្ខាបទណាមួយដែលជាលោកវជ្ជៈ (ទោសសម្រាប់លោក), ដាច់មិនមានទោសនោះ គឺស្លាប់ ។

ស. ឧបោសថ បើកំណត់ឈ្មោះតាមប្រភេទរបស់បុគ្គលអ្នករក្សាតើមានប៉ុន្មានយ៉ាង? អ្វីខ្លះ? ចូរអធិប្បាយ !

ឆ. មាន ៣ យ៉ាងគឺ គោបាលឧបោសថ ១, និគ្គន្ថឧបោសថ ១, អរិយឧបោសថ ១ ។

អធិប្បាយ : អ្នករក្សាឧបោសថមិនសូវមានសេចក្តីត្រេកអរពេញចិត្តនឹងរក្សាប៉ុន្មាន ទន្ទឹងឲ្យតែអស់កាលឧបោសថ ហើយនឹងប្រព្រឹត្តធ្វើ

កិច្ចអ្វីផ្សេង ៗ តាមសេចក្ដីប្រាថ្នារបស់ខ្លួន ឧបោសថនេះមានផលតិច មានអានិសង្សតិច ដូចជាអ្នកគង្វាលគោ ស៊ីឈ្នួលឃ្វាលគោឲ្យគេ គៀងគោទៅកាន់ទីដែលមានទឹកនិងស្មៅ អ្នកគង្វាលគោនោះ តែងទទួលឲ្យតែដល់ពេលល្ងាច ទើងអាលគៀងគោមកប្រគល់ឲ្យម្ចាស់គោវិញ, រួចទារយកតែថ្លៃឈ្នួលប៉ុណ្ណោះ ឯត្រង់បញ្ចគោរស (រសនៃគោ ៥ យ៉ាង) ក៏ឥតមានជីវិតរស់ជាតិអ្វីបន្តិចបន្តួចសោះ; អ្នករក្សាឧបោសថបែបនេះ ហៅថា គោបាលឧបោសថ ។

ពួកនិគ្រន្ថរក្សាឧបោសថ វៀរអំពើអាក្រក់ មានកំណត់ទីឬកំណត់សត្វ ។ កំណត់ទីនោះ ដូចសត្វនៅទិសខាងកើតសម្លាប់មិនបាន, សត្វនៅទិសខាងលិចសម្លាប់បាន; កំណត់សត្វនោះ ដូចសម្លាប់មាន់បានសម្លាប់ទាមិនបាន ដូច្នេះជាដើម; ចំណែកខាងបុគ្គលណារក្សាឧបោសថកាន់យកតាមរបៀបពួកនិគ្រន្ថដូច្នេះ ហៅថា និគន្ថឧបោសថ ។

ឧបោសថរបស់អរិយបុគ្គល ដែលលះកិលេសណាបានហើយ កិលេសនោះមិនត្រឡប់កើតឡើងវិញ លោករក្សាឧបោសថដើម្បីកំចាត់បង់នូវកិលេសដែលសេសសល់ទាំងប៉ុន្មាននោះ ឲ្យស្អាតពីសន្ដានរបស់លោក; អ្នករក្សាឧបោសថ កាន់របៀបអរិយបុគ្គល ដើម្បីនឹងកំចាត់បង់នូវកិលេសដូច្នេះ ហៅថា អរិយឧបោសថ ។

ស – ត្រង់ពាក្យថា បញ្ចគោរស (រសនៃគោ ៥ យ៉ាង) នោះគឺអ្វីខ្លះ?

ឆ - ១. ទិរិ ទឹកដោះស្រស់, ២. ទធិ ទឹកដោះជូរ, ៣. ឃតំ ទឹកដោះថ្លា, ៤. តក្កំ ប្រេង, ៥. នោនីតំ(១) ទឹក-ដោះខាប់ ។

ស - ពាក្យថា ឧបោសថកម្ម, ឧបោសថសីល, ឧបោសថកាល ទាំង ៣ នេះមានសេចក្ដីផ្សេងគ្នាយ៉ាងណា ?

ឆ - មានសេចក្ដីផ្សេងគ្នាយ៉ាងនេះ : ឧបោសថកម្មនោះ គឺជាអំពើដែលឧបាសកឧបាសិកា ត្រូវធ្វើក្នុងថ្ងៃឧបោសថ មានទទួលព្រះត្រៃសរណគមន៍ជាដើម ឈ្មោះថា ឧបោសថកម្ម ។ ឧបោសថសីលនោះ គឺសីលដែលកើតអំពីការសមាទានន្ធូវសិក្ខាបទទាំង ៨ ក្នុងថ្ងៃឧបោសថនោះ ឈ្មោះថា ឧបោសថសីល ។ ឧបោសថកាលនោះ គឺថ្ងៃដែលត្រូវរក្សានូវឧបោសថ មានថ្ងៃ ៥ កើតជាដើម ក្នុង ១ ខែមានកាលដែលត្រូវរក្សាឧបោសថ ៨ ថ្ងៃ ដូច្នេះ ឈ្មោះថា ឧបោសថកាល ។

ស - ឧបោសថ ដែលឧបាសកឧបាសិកាគួររក្សាបាន តាមសេចក្ដីពេញចិត្តរបស់ខ្លួន តើមានប៉ុន្មាន? អ្វីខ្លះ? ចូរអធិប្បាយ !

ឆ .- មាន ៣ គឺ បកតិឧបោសថ ១, បដិជាគរឧបោសថ ១, បាដិហារិយឧបោសថ ១ ។

អធិប្បាយ : បកតិឧបោសថនោះក្នុង ១ ខែមាន ៨ ថ្ងៃ គឺថ្ងៃបញ្ចមី, អដ្ឋមី, ចាតុទ្ទសី, បណ្ណរសី ខាងខ្នើត ៤ ថ្ងៃ ខាងរនោច ៤ ថ្ងៃ ត្រូវជា ៨ ថ្ងៃ ។ បដិជាគរឧបោសថនោះ កំណត់យកថ្ងៃអមខាងដើមនិងខាងចុងនៃថ្ងៃ

១ មានប្រើដោយច្រើនជា នវនីតំ ។

បកតិឧបោសថ ហៅថា បដិជាគរឧបោសថ ។ បដិហារិយឧបោសថនោះ មានសេចក្ដីអធិប្បាយក្នុងអដ្ឋកថាមនោរថបូរណី គម្ពីរអង្គុត្តរនិកាយថា ឧបោសថដែលបុគ្គលត្រូវរក្សាជាប់ជានិច្ចអស់ ៣ ខែខាងក្នុងវស្សា គឺកំណត់ពីត្រឹមថ្ងៃចូលវស្សាទៅដល់ថ្ងៃបវារណាចេញវស្សា ហៅថា បាដិ-ហារិយឧបោសថ ។ ម្យ៉ាងទៀត បើបុគ្គលមិនអាចនឹងរក្សាអស់កំណត់កាល ៣ ខែខាងក្នុងវស្សានោះបានទេ ត្រូវរក្សាឲ្យបានជាប់ជានិច្ចអស់ ១ ខែក្នុងចន្លោះនៃបវារណាទាំងពីរ គឺកំណត់ពីត្រឹមថ្ងៃ ១ រោចខែអស្សុជទៅដល់ថ្ងៃពេញបូណ៌មីខែកត្តិក, កាលបើបុគ្គលមិនអាចនឹងរក្សាអស់កំណត់ ១ ខែក្នុងចន្លោះនៃបវារណាទាំងពីរនោះបានទេ ត្រូវរក្សាជាប់ជានិច្ចអស់កាលត្រឹមកន្លះខែ ចាប់ដើមតាំងអំពីថ្ងៃបឋមបវារណាមក គឺកំណត់ពីត្រឹមថ្ងៃ ១ រោចទៅដល់ថ្ងៃ ១៤ រោចខែអស្សុជ ក៏បាន ហៅថា បាដិហារិយ-ឧបោសថដែរ ។

ន័យមួយទៀត ក្នុងអដ្ឋកថាបរមត្ថជោតិកា គម្ពីរខុទ្ទកនិកាយ សុត្ត-និបាត លោកវិនិច្ឆ័យត្រង់ពាក្យថា បាដិហារិយឧបោសថនេះ មានកំណត់កាល ៥ ខែ គឺខែអាសាឍពេញ ១ ខែ, ខាងក្នុងវស្សា ៣ ខែ, ខែកត្តិកពេញ ១ ខែ; ទាំង ៥ ខែនេះលោកហៅថា កាលជាទីរក្សានូវបាដិ-ហារិយឧបោសថ ។ មានអាចារ្យដទៃទៀតពោលថា មានត្រឹមតែ ៣ ខែ គឺ ខែអាសាឍ, កត្តិក, ផល្គុន, ទាំង ៣ ខែនេះ ហៅថា កាលជាទីរក្សានូវបាដិហារិយឧបោសថ ។ មានអាចារ្យមួយពួកទៀតពោលថា ថ្ងៃសេសគូ គឺថ្ងៃ ១៣ កើត ១៣ រោច, ថ្ងៃ ១ កើត ១ រោច, ថ្ងៃ ៧ កើត ៧ រោច,

ថ្ងៃ ៩ កើត ៩ កេច គ្រប់បក្សទាំងអស់ ( ទាំងជុណ្ហបក្ស “ ខាងខ្នើត ” ទាំងកាឡបក្ស “ ខាងរនោច ”) ដោយអំណាចថ្ងៃខាងដើមនិងខាងចុង នៃថ្ងៃឧបោសថ ហៅថា កាលជាទីរក្សានូវបាដិហារិយឧបោសថ ។ ពាក្យ ដែលបានពោលមកទាំងប៉ុន្មានអន្លើនោះ បើបុគ្គលពេញចិត្តពាក្យណា គប្បីកាន់យកតាមពាក្យនោះចុះ ប៉ុន្តែបុគ្គលអ្នកចង់បានបុណ្យ គួរតែ ធ្វើឲ្យបានសព្វគ្រប់ តាមន័យនោះៗ ។

ស.– បាដិហារិយឧបោសថ ត្រូវរក្សាសីលប៉ុន្មាន ?

ឆ.– ត្រូវរក្សាសីល ៨ ប៉ុន្តែត្រូវរក្សាជាប់ជានិច្ច តាមកាល កំណត់ ដូចបានអធិប្បាយរួចមកហើយ ។

ស.– បាដិហារិយ ប្រែថាដូចម្តេច? ហើយមានសេចក្តីវិសេស ជាងឧបោសថណាខ្លះ ?

ឆ.– ប្រែថា: ធម្មជាតិនាំចេញនូវធម៌ជាសត្រូវ ឬថាកំចាត់បង់នូវ ធម៌ជាសត្រូវឲ្យអស់ពីខន្ធសន្តាន, មានសេចក្តីវិសេសជាងបកតិឧបោសថ និងបដិជាគរឧបោសថ ។

## ៩– វិធីដែលឧបាសកឧបាសិកាត្រូវរក្សាសីល

ស.– កាលបើដល់ថ្ងៃជិតនឹងរក្សានូវឧបោសថសីល គឺថ្ងៃមុន ១ ថ្ងៃ ដែលដឹងប្រាកដថាព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះ តើឧបាសក ឧបាសិកាគប្បីប្រតិបត្តិដូចម្តេចខ្លះ? ។

ឆ.– ឧបាសកឧបាសិកា គប្បីប្រតិបត្តិដូច្នេះគឺ ត្រូវចាត់ចែងការងារ ដែលគួរនឹងចាត់ចែង មានអាហារជាដើម ឲ្យហើយក្នុងថ្ងៃនោះមុន តែកុំ

ចាត់ចែងការងារដែលមិនប្រកបដោយធម៌ ដែលខ្លួនជាឧបាសកឧបាសិកា មិនគួរទឹងចាត់ចែងនោះឡើយ ។

ស – លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថកាល ត្រូវរក្សានូវឧបោសថសីល តើឧបាសកឧបាសិកាត្រូវប្រតិបត្តិដូចម្តេចខ្លះទៀត ? ។

ច – ឧបាសកឧបាសិកា ត្រូវក្រោកឡើងអំពីព្រលឹម ហើយខ្ទម្ទាត់ជំរះជ្រះឲ្យស្អាត រួចហើយសមាទានឧបោសថសីលក្នុងវេលានោះភ្លាម តែបើសមាទានពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីលក្នុង ១ ថ្ងៃ ១ យប់នោះ ដោយបញ្ចេញវាចាអធិដ្ឋានថា: អជ្ជ ឧបោសថោ តិមញ្ច រត្តិំ តិមញ្ច ទិវសំ ឧបោសថិកោ ភវិស្សាមិ (ប្រែថា) "ថ្ងៃនេះ ជាថ្ងៃត្រូវរក្សានូវឧបោសថសីល ខ្លួនអាត្មាអញទឹងជាអ្នករក្សានូវឧបោសថសីលអស់ថ្ងៃនេះនឹងយប់នេះ" ។ លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនាវៀរចាកសីលភេទ គឺហេតុដែលជាទីចំណាយនៃសីលនោះៗ ឲ្យគ្រប់សិក្ខាបទទាំង ៨, តអំពីពេលនោះមក ក៏គប្បីសមាទាននូវឧបោសថសីលអំពីបុគ្គលដទៃមានភិក្ខុជាដើម តាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើងប្រមាណពេញពន្លឺធំ ទើបបានសមាទាន ក៏ឈ្មោះថាបានសមាទានដោយប្រពៃ ឈ្មោះថាបានរក្សានូវឧបោសថសីលពេញកាលកំណត់ ១ ថ្ងៃ ១ យប់ ដោយបរិបូណ៌មិនខ្វះខាត ទាំងវិរតិចេតនាសោតក៏កើតក្នុងគ្រប់គ្រាន់ក្នុងសន្តាន ក៏គង់បាននូវផលានិសង្សច្រើនដូចគ្នា ។

ស– ឧបាសកឧបាសិកា ដែលបានទទួលសមាទាននូវឧបោសថសីលក្នុងថ្ងៃឧបោសថកាលនោះរួចហើយ បើចង់ឲ្យបានផលានិសង្សក្នុងថ្ងៃនោះយប់នោះ ត្រូវប្រតិបត្តិដូចម្ដេច ? ។

ឆ– ត្រូវប្រតិបត្តិ គឺសង្រួមកាយនិងវាចា ឲ្យបានសមគួររៀបរយតាមពុទ្ធានុញ្ញាតទុកមក ។

ស– ការសង្រួមកាយនិងវាចា ឲ្យបានសមគួរនោះ តើត្រូវធ្វើដូចម្ដេច ?

ឆ– ការដែលសង្រួមកាយឲ្យបានសមគួរនោះ គឺត្រូវលះបង់នូវការងារទាំងឡាយ មានការភ្ជួរស្រែនិងចំការជាដើម ដែលជាការនាំឲ្យសៅហ្មងដល់ព្រហ្មចរិយសីល ដែលខ្លួនបានទទួលសមាទានហើយក្នុងថ្ងៃនោះយប់នោះ; ឯការសង្រួមវាចាឲ្យបានសមគួរនោះ គឺត្រូវលះបង់នូវតិរច្ឆានកថា ២៨ យ៉ាងចេញ ហើយគួរពោលនូវពាក្យដែលនាំឲ្យកើតសង្វេគ ឬពោលអំពីកថាវត្ថុ ១០ ប្រការវិញ យ៉ាងនេះឈ្មោះថាសង្រួមកាយនិងវាចាឲ្យបានសមគួររៀបរយតាមពុទ្ធានុញ្ញាត ។

ស– ពាក្យថា តិរច្ឆានកថា នោះប្រែថាដូចម្ដេច ? ដែលថាមាន ២៨ យ៉ាងនោះតើអ្វីខ្លះ ?

ឆ– ប្រែថា "សំដីឥតប្រយោជន៍ ឬសំដីដែលនិយាយទទឹងផ្លូវនឹងសំដីដែលមានប្រយោជន៍" ឬប្រែថា "សំដីដែលទទឹងក្នុងដំណើរដែលទៅកាន់ឋានសួគ៌ ឋាននិព្វាន" ដែលថាមាន ២៨[1] យ៉ាងនោះគឺ

១ ន័យខ្លះថា មាន ២៧ យ៉ាង, ខ្លះថាមាន ៣២ យ៉ាង ។

១_ រាជកថា និយាយអំពីស្តេច

២_ ចោរកថា និយាយអំពីចោរ

៣_ មហាមត្តកថា និយាយអំពីអមាត្យធំៗ

៤_ សេនាកថា និយាយអំពីសេនាទាហាន

៥_ ភយកថា និយាយអំពីហេតុដែលនាំឲ្យភ័យ

៦_ យុទ្ធកថា និយាយអំពីចម្បាំង

៧_ អន្នកថា និយាយអំពីបាយម្ហូបចំណី

៨_ បានកថា និយាយអំពីទឹកផឹក

៩_ វត្ថកថា និយាយអំពីសំពត់

១០_ សយនកថា និយាយអំពីទីដេក

១១_ មាលាកថា និយាយអំពីផ្កាកម្រង

១២_ គន្ធកថា និយាយអំពីគ្រឿងក្រអូប

១៣_ ញាតិកថា និយាយអំពីញាតិ

១៤_ យានកថា និយាយអំពីយាន (គ្រឿងជិះ)

១៥_ គាមកថា និយាយអំពីស្រុក

១៦_ និគមកថា និយាយអំពីនិគម

១៧_ នគរកថា និយាយអំពីនគរ

១៨– ជនបទកថា និយាយអំពីជនបទ

១៩– ឥត្ថីកថា និយាយអំពីស្ត្រី

២០– បុរិសកថា និយាយអំពីបុរស

២១– សូរកថា និយាយអំពីជនដែលក្លៀវក្លា

២២– វិសិខាកថា និយាយអំពីច្រកផ្លូវ ឬផ្លូវបែក

២៣– កុម្ភដ្ឋានកថា និយាយអំពីកំពង់ទឹក

២៤– បុព្វបេតកថា និយាយអំពីញាតិដែលបែកឋានទៅកាន់បរលោកហើយ

២៥– នានត្តកថា និយាយអំពីពាក្យដែលឥតប្រយោជន៍មានសភាពផ្សេងៗ

២៦– លោកក្ខាយិកកថា និយាយអំពីលោក

២៧– សមុទ្ទក្ខាយិកកថា និយាយអំពីរឿងជីកសមុទ្រ

២៨– ឥតិ ភវាភវកថា និយាយអំពីសេចក្តីចំរើននឹងមិនចំរើន ដូចេះខ្លះ ដូចោះខ្លះ ។

ស – ពាក្យថា កថាវត្ថុ នោះប្រែថា ដូចម្តេច? ដែលថា ១០ ប្រការនោះ តើអ្វីខ្លះ?

ឆ – ប្រែថា "ពាក្យ ឬរឿងដែលគួរនិយាយ"; ដែលថា ១០ ប្រការនោះគឺ

១–អប្បិច្ឆកថា និយាយនាំឲ្យមានសេចក្តីប្រាថ្នាតិច

២–សន្តុដ្ឋិកថា និយាយនាំឲ្យមានសេចក្តីសន្តោស

៣–បវិវេកកថា និយាយនាំឲ្យស្ងាត់កាយស្ងាត់ចិត្ត

៤–អសំសគ្គកថា និយាយនាំមិនឲ្យជាប់ជំពាក់ដោយបក្សពួក

៥–វិរិយារម្ភកថា និយាយដឹកនាំឲ្យមានព្យាយាម

៦–សីលកថា និយាយដឹកនាំឲ្យតាំងនៅក្នុងសីល

៧–សមាធិកថា និយាយដឹកនាំឲ្យមានសមាធិចិត្ត

៨–បញ្ញាកថា និយាយដឹកនាំឲ្យកើតប្រាជ្ញា

៩–វិមុត្តិកថា និយាយនាំធ្វើឲ្យចិត្តផុតចាកកិលេស

១០–វិមុត្តិញាណទស្សនកថា និយាយដឹកនាំឲ្យកើតសេចក្តីចេះដឹង នឹងសេចក្តីយល់ឃើញក្នុងវិមុត្តិ ។

ស. ឧបាសកឧបាសិកា បើបានសង្រួមកាយវាចាសមគួរហើយ ក្នុងថ្ងៃនោះយប់នោះ ត្រូវធ្វើអ្វីទៀត?

ឆ. ត្រូវស្តាប់ធម៌ទេសនា ឬធ្វើនូវធម្មសាកច្ឆា គឺសាកសួរអំពីធម៌អាថ៌ ។ បើមិនបានស្តាប់ធម៌ទេ ត្រូវសង្រួមចិត្តគឺតាំងចំរើននូវកម្មដ្ឋាន ក្នុងសមថកម្មដ្ឋាន ៤០ ប្រការ ត្រង់កម្មដ្ឋានណាមួយក៏បាន ប៉ុន្តែមុនដំបូង ត្រូវចំរើនមូលកម្មដ្ឋានគឺពុទ្ធានុស្សតិកម្មដ្ឋានជាមុនសិន ហើយសឹមឲ្យចំរើននូវកម្មដ្ឋានឯទៀតតទៅ តាមគួរដល់អធ្យាស្រ័យ ។

ស– មុននឹងចំរើននូវកម្មដ្ឋាននោះ ត្រូវពិចារណាអ្វីខ្លះ? ចូរអធិប្បាយឲ្យហូរហែមកផង?

ឆ– ត្រូវពិចារណានូវទោសនៃកាមគុណឲ្យឃើញច្បាស់ថា រូប សំឡេង ក្លិន រស សម្ផស្ស ទាំង៥នេះ ជារបស់រមែងឲ្យកើតទោសទុក្ខផ្សេងៗ ឬនឹងពិចារណានូវខន្ធ៥ ឲ្យឃើញថាជា អនិច្ចំ ទុក្ខំ អនត្តា គឺពិចារណាឲ្យឃើញថា រូបក្ខន្ធនេះ មិនទៀងមិនតាំងនៅឋិតថេរ តែងវិនាសទៅដោយហេតុផ្សេងៗ មានវិនាសដោយចំហាយក្តៅនឹងត្រជាក់ជាដើម, រូបនេះរមែងនាំមកនូវសេចក្តីទុក្ខព្រួយ; រូបនេះរមែងបែកធ្លាយជាធម្មតា រកខ្លឹមសារគ្មានសោះឡើយ ទាំងវេទនាខន្ធ សញ្ញាខន្ធ សំខារក្ខន្ធសោតទៀត ក៏ជាអនិច្ចំ ទុក្ខំ អនត្តា ដូចគ្នានឹងរូបក្ខន្ធនេះដែរៗ ម្យ៉ាងទៀត ត្រូវពិចារណាធម៌ជាទីសង្វេគថា ជនទាំងឡាយដែលកើតមកក្នុងលោកនេះ រកទីពឹងពំនាក់ឲ្យមាំមួនពុំមានទេ សុទ្ធតែជាអ្នកកំព្រាម្នាក់ឯង មានមាតាបិតា ស្វាមីបុត្រភរិយា មិត្រសម្លាញ់ ទ្រព្យសម្បត្តិទាំងប៉ុន្មានក៏ទុកដូចជាគ្មាន ព្រោះថាជនទាំងឡាយមានមាតាបិតាជាដើមនោះ មិនអាចនឹងបែកនូវសេចក្តីសុខទុក្ខឲ្យដល់គ្នានឹងគ្នាបានឡើយ, មិនអាចនឹងជួយការពារ ឬជូនដំណើរគ្នាទៅក្នុងកាលដែលមរណសង្គ្រាមមកដល់ចំពោះរូបទីមួយៗ នោះបានឡើយ; ពេលដែលមរណសង្គ្រាមមកដល់ខ្លួន សត្វទាំងអស់ក៏ជាអ្នកឥតមានគ្នីគ្នាទេ បើប្រទះបានសេចក្តីទុក្ខដែលកើតអំពីអកុសលកម្ម ដែលខ្លួនធ្វើហើយក្នុងកាលមុនស្លាប់នោះ ក៏ត្រូវតែទទួលយកនូវសេចក្តីទុក្ខនោះដោយឥតបរិហារ ឬបើប្រទះ

បានសេចក្តីសុខដែលជាផលនៃកុសលកម្ម ដែលខ្លួនបានធ្វើល្អទុកមក ហើយក្នុងពេលមុនស្លាប់នោះ ក៏ត្រូវទទួលយកនូវសេចក្តីសុខនោះចំពោះតែខ្លួនមួយប៉ុណ្ណោះ ទោះខ្លួនមានទ្រព្យសម្បត្តិក្នុងលោកនេះតិចច្រើនប៉ុន្មានៗ ក៏មិនអាចនឹងនាំយកទៅផងបាន ។ ឧបាសកឧបាសិកា កាលបើបានពិចារណាឃើញយ៉ាងនេះហើយ ក៏នឹងមានចិត្តទន់ទៅកាន់ពុទ្ធគុណធម្មគុណសង្ឃគុណ បើឃើញថាចិត្តរបស់ខ្លួនទន់ទៅកាន់គុណព្រះរត្នត្រ័យហើយ គប្បីបរិកម្មនូវព្រះនាមរបស់ព្រះសម្ពុទ្ធជាម្ចាស់ទាំង ១០ ព្រះនាម មានអរហំជាដើម ឲ្យបានកើតសេចក្តីជះថ្លាក្នុងព្រះនាមទាំងនោះ ហើយគប្បីលើកឡើងនូវព្រះនាមនោះមកភាវនា គឺថាយកគុណទាំងនោះមករំពឹងតែក្នុងចិត្តម្យ៉ាង មិនបាច់បញ្ចេញពាក្យឲ្យលាន់ឮឡើយ ។

ស— វិធីដែលនឹងភាវនាពុទ្ធគុណនោះមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ— មាន ៣ យ៉ាងគឺ

១— ឲ្យភាវនាថា ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ល។ ពុទ្ធោ ភគវា ហើយត្រឡប់មកតាំងភាវនាពីខាងដើមទៅទៀត ភាវនាយ៉ាងនេះ ទោះ ១ រយចប់ ឬ ១ ពាន់ចប់ក៏បាន ។

២— នឹងភាវនាថា សោ ភគវា ឥតិបិ អរហំ, សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ ។ល។ សោ ភគវា ឥតិបិ ភគវា ហើយត្រឡប់មកភាវនាតាំងពីខាងដើមទៅទៀត យ៉ាងនេះបាន ១ រយចប់ឬ ១ ពាន់ចប់ក៏បាន ។

៣— នឹងភាវនាតែ ១ បទៗ ដូចភាវនាថា អរហំៗ ឬថា សម្មា-

សម្ពុទ្ធោ ។ ល ។ ពុទ្ធោ ឬថា ភគវា ដូច្នេះក៏បាន ភាវនាយ៉ាងនេះគង់ ១ បទ ។ នោះ បាន ១ រយចប់ក្តី ១ ពាន់ចប់ក្តីក៏បាន តាមពេញចិត្តរបស់ខ្លួន តែត្រូវភាវនាឲ្យដឹងសេចក្តីក្នុងពុទ្ធគុណនោះផង ។

ស– ចុះទីសេនាសនៈដែលឧបាសកឧបាសិកា នឹងអង្គុយបំពេននោះ គប្បីរកទីដូចម្តេច? គប្បីរកពេលដូចម្តេច?

ឆ– គប្បីរកទីឲ្យសមគួរ ឲ្យស្ងាត់ ទាំងពេលវេលាក៏ត្រូវឲ្យស្ងប់ស្ងាត់ចាក់សូរស័ព្ទសម្លេងទាំងពួងកុំឲ្យលាន់ឮគឹកកងដើម្បីនឹងធ្វើអារម្មណ៍ឲ្យតាំងនៅនឹងល្អ ។

ស– កាលបើឧបាសកឧបាសិកា បានភាវនារំពឹងដល់ពុទ្ធគុណដូច្នេះហើយ តើនឹងអាចឲ្យកើតធម៌អ្វី?

ឆ– អាចឲ្យកើតត្រឹមបីតិ ៥ យ៉ាងណាមួយ ។

ស– បីតិ ប្រែថាដូចម្តេច? ដែលថាមាន ៥ យ៉ាងនោះអ្វីខ្លះ?

ឆ– ប្រែថា ''សេចក្តីត្រេកអរ ឬសេចក្តីរីករាយផ្អែតក្នុងចិត្ត; ដែលថាមាន ៥ យ៉ាងនោះគឺ

១– ខុទ្ទកា បីតិ សេចក្តីត្រេកអរព្រឺរោមព្រឺស្បែក;

២– ខណិកា បីតិ សេចក្តីត្រេកអរប្រាកដដូចជាផ្លេកបន្ទោរ

៣– ឱក្កន្តិកា បីតិ សេចក្តីត្រេកអរមានអាការប្រាកដ ដូចជារលកទឹកបោកផ្ទប់មកត្រូវ;

៤– ឧព្វេង្គា បីតិ សេចក្តីត្រេកអរខ្លាំង អាចញ៉ាំងកាយឲ្យអណ្តែតឡើង;

៥– ផរណា បីតិ សេចក្ដីត្រេកអរធ្វើឲ្យត្រជាក់ផ្សាយផ្សាយទៅក្នុងកាយ ។

ស– បីតិទាំង ៥ យ៉ាងនេះ បីតិណាមួយដែលកើតឡើងដោយអំណាចការនាចំរើនពុទ្ធគុណ ដែលជាមូលកម្មដ្ឋានយ៉ាងនេះហើយ តើនឹងបានផលានិសង្សអាចឲ្យសម្រេចគុណវិសេសអ្វីតទៅទៀត? ព្រោះអ្វី?

ឆ– អាចឲ្យបានសម្រេចតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចនឹងឲ្យសម្រេចដល់អប្បនាឈាន គឺបឋមជ្ឈានបានឡើយ ព្រោះពុទ្ធ-គុណនេះ ជាគុណជ្រាលជ្រៅអនេកអនន្តពន់ពេកណាស់ អ្នកដែលចំរើននោះមិនអាចនឹងពិចារណាឲ្យយល់សព្វគ្រប់ទៅបាន ។

១០– វិបត្តិនៃឧបាសក

ស– វិបត្តិ (ធម្មជាតិដល់នូវសេចក្ដីវិនាស, សេចក្ដីអន្តរាយ) របស់ឧបាសក តើដូចម្ដេច?

ឆ– សីលវិបត្តិ សេចក្ដីវិនាសនៃសីល និង អាជីវវិបត្តិ សេចក្ដីវិនាសនៃការចិញ្ចឹមជីវិតត្រឹមត្រូវ នេះហៅថា វិបត្តិរបស់ឧបាសក ។ ន័យមួយទៀត ការមិនជឿគុណព្រះរត្នត្រ័យ ១, ភាពដែលទ្រុស្តសីល ១, ការជឿមង្គលភ្ញាក់ផ្អើល ១, សេចក្ដីប្រកាន់ជឿមង្គល មានទិដ្ឋមង្គលជាដើម មិនប្រកាន់ជឿកម្ម ១, ការស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពុទ្ធសាសនានេះ ហើយធ្វើនូវកុសលកម្មមានទានជាដើម ចំពោះទក្ខិណេយ្យបុគ្គលខាងក្រៅសាសនានោះជាមុនបង្អស់ ១, ធម៌ទាំង ៥ យ៉ាងនេះ ក៏ហៅថា វិបត្តិរបស់ឧបាសកដែរ ។

ស– បើឧបាសកណា ប្រកបដោយវិបត្តិដូចបានពោលមកហើយនេះ ឧបាសកនោះ ឲ្យឈ្មោះថាជាឧបាសកអ្វី ?

ឆ– ឲ្យឈ្មោះថា ឧបាសកចណ្ឌាល គឺឧបាសក ដូចជាមនុស្សចណ្ឌាល ឬថាឧបាសកកាចចំពោះសាសនាផង ឈ្មោះថា ឧបាសកប្បដិមល: ឧបាសកជាមន្ទិលចំពោះសាសនាផង ឈ្មោះថា ឧបាសកប្បដិកិដ្ឋ: ឧបាសកណាមកអាក្រក់ជាទីបំផុត ឬឧបាសកដែលអ្នកប្រាជ្ញទាំងឡាយលោកតិះដៀលផង ។

## ១១– សម្បត្តិនៃឧបាសក

ស– សម្បត្តិ (ការបរិបូណ៌ដោយសេចក្ដីល្អ) របស់ឧបាសក តើដូចម្ដេច ?

ឆ– សីលសម្បទា ការបរិបូណ៌ដោយសីល អាជីវសម្បទា ការបរិបូណ៌ដោយការចិញ្ចឹមជីវិតត្រឹមត្រូវ ហៅថា សម្បត្តិនៃឧបាសក ។

ន័យមួយទៀត ធម៌ ៥ យ៉ាងគឺ សទ្ធោ ហោតិ ឧបាសកមានសេចក្ដីជឿជាក់ច្បាស់ក្នុងព្រះរត្នត្រ័យ ១ សីលវា ហោតិ ឧបាសកមានសីល ១ ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនប្រកបដោយមង្គលភ្ញាក់ផ្អើល ១ កម្មំ បច្ចេតិ នោ មង្គលំ ឧបាសកប្រកាន់ជឿនូវកម្ម មិនប្រកាន់ជឿនូវមង្គល ១ ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពុទ្ធសាសនាឡើយ ហើយធ្វើនូវកុសលកម្មមានទានជា

ដើមបំពោះទក្ខិណេយ្យបុគ្គលក្នុងពុទ្ធសាសនានេះជាមុនបង្អស់ ១ ទាំង ៥ នេះ កំហៅថា សម្បត្តិរបស់ឧបាសកដែរ ។

ស– ឧបាសកណា ប្រកបដោយសម្បត្តិ ៥ យ៉ាងនេះហើយ ឧបាសកនោះនឹងឲ្យឈ្មោះថា ឧបាសកអ្វីខ្លះ ?

ឆ– ឲ្យឈ្មោះថា ឧបាសករតនៈ ឧបាសកដូចជារតនវត្ថុមានកែវជាដើមផង ឈ្មោះថា ឧបាសកបទុមៈ ឧបាសកដូចជាផ្កាឈូកក្រហមផង ឈ្មោះថា ឧបាសកបុណ្ឌរីក ឧបាសកដូចជាផ្កាឈូកសផង ។

ស - ធម៌សម្រាប់ពួកឧបាសកឧបាសិការក្សានឹងប្រតិបត្តិ មានចំនួនតែត្រឹមដែលបានរៀបរៀងមកប៉ុណ្ណោះទេ ឬមានផ្សេងពីនេះទៅទៀត ?

ឆ– មិនមែនមានត្រឹមតែប៉ុណ្ណោះទេ មានច្រើនជាងនេះជាអនេក ដូចគុណរបស់ឧបាសក ១០ យ៉ាង, កម្មបថ ១០, កម្មបថ ៤០ នឹងធម៌ដទៃ ៗ ទៀតជាច្រើន តែក្នុងទីនេះ មិនបានដកស្រង់មករៀបរៀងឲ្យសព្វគ្រប់ទេ សូមមើលច្បាប់ឯទៀតជាជំនួយផងចុះ ។

ចប់ ប្រជុំធម៌ឧបាសក ដោយសង្ខេប

## សុភាសិតដែលគួរពិចារណា

| | |
|---|---|
| បេះមិនឈ្នះបង់ | ត្រង់មិនឈ្នះទាល់ |
| កល់មិនឈ្នះគិត | ឫទ្ធិមិនឈ្នះភេគ |
| ណោកមិនឈ្នះណាញ | ទាញមិនឈ្នះទៅ |
| នៅមិនឈ្នះនាង | ភាងមិនឈ្នះភាគ |
| ណាកមិនឈ្នះណោភ | ល្មោភមិនឈ្នះល្មម |
| ព្រមមិនឈ្នះព្រេង | លេងមិនឈ្នះមែន ។ |

# ទោសនៃសុរា

ព្រឹទ្ធបាលទោ ជា - ប៊ូរ រៀបរៀង

—▪—

## កាព្យពាក្យ ៩

ផ្គុំហត្ថាជាតំណាងតាំងបទុម
ចិត្តបរិសុទ្ធលំអុតកាយថ្វាយបង្គំ
ដល់ប្រជុំឧត្តមថ្លៃត្រៃរតនា ។
សូមតេជះព្រះរិជិតឫទ្ធិបញ្ចង់
ជួយតម្រង់ផ្ចង់តម្រូវផ្លូវវាចា
សូមបរិយាយពាយសេចក្តីពីសុរា
ដែលព្រះពុទ្ធម្កុដលោកាខាខាំងឃាត់ ។
មិនឲ្យសេពក្រេបជញ្ជក់ក្លក្យសោះឡើយ
តែផឹកហើយស្បើយបញ្ញាក្លាពាក្យមាត់
បុកក្អេងក្អាងយ៉ាងគ្រាន់បើដើរសើយលាត់
ខាងធាក់ទាត់ស្ទាត់ឃ្លានពានគ្មានគេដល់ ។
ពេលកើតខ្ញាសអាសអាកាស ពាសភូមិឋាន
ញាតិសន្តានបានទុក្ខព្រួយជួយរវល់
ស្តីរំលឹកនឹករំលែកចែកយោបល់
ឲ្យគិតដល់ផលចង្រៃនៃសុរា ។
ត្រឡប់ជាករកខឹងនឹងព្រៀងលាន

ដែលគេមានសន្តានចិត្តសិទ្ធមេត្តា
ជួយជាស់គៀនក្រើនស្មារតីនៃអាត្មា
ដើរខុសមគ្គផ្ទាក់កាយាការហើនហៃ ។
ចូលចិត្តស្ត្រីអ្នកអែបអបប្រែបប្រឡោះ
ឡើងដំនោរដោរបំណាប់ឆាប់ត្រូវក្រៃ
បបួលក្លែមក្លែមភៅហារផ្ការដើនដៃ
ចាយកាសប្រាក់ហាក់វិស័យសេដ្ឋីធំ ។
អស់ប្រាក់ហើយស្បើយសំដីស្ដីមួយ ៗ
នៃអាបេកេចិកពួយកុំបារម្ភ (១)
ត្រង់ប្រាក់កាសមិនផ្ដាសសោះមនុស្សយ៉ាងខ្ញុំ
ដូចដីនស្រាប់ផ្ទាប់ចាយធំពុំឲ្យថោក ។
លុះថៃក្រោយដោយគេទារជាញឹកញាប់
មុខស្រពោនទុនស្រពាបផាប់ទុក្ខសោក
នាំប្រពន្ធធន់មិនបានខានយល់យោគ
ស្ដីកំបោកបោកកំចាយខ្លាយដំណោះ ។
ប្រពន្ធគាប់ផ្ទាប់កោតក្រែងរឯងប្ដី
ផល់ហួសណាស់ឈ្នះទ្រាំអីស្ដីទៃគោះ
ខ្ទួនប្រែឡោតក្រោធប្រឡំខំឈ្លោះ
គ្មានពិគ្រោះទោះខុសត្រូវទៅបំពាន ។

---

១ ពាក្យចិន ប្រែថា ថែមមួយកែវ ។

បះស្រីណាចិន្តាស្រាលកាលមួយម៉ោ
មិនឈ្នះទ្រាំទាំក្តីក្តៅទៅសន្តាន
ប្តឹងទៅក្រមសុំជំរះលះលែងប្រាណ
ទាល់តែខានបានរួមរ័ក្សស្ង័គ្រស្នេហា ។
អ្នកប្រមឹកកុំប្រមាណបានសប្បាយ
ទឹកស្រវឹងនឹងឲ្យកាយខ្លាយសុខា
បង្កើតរោគយោគកង្វល់ដល់មរណា
ពីព្រោះធាតុជាតិសុរាជាថ្នាំពុល ។
កុំស្មានថាស្រាជាថ្នាំនាំក្លាហាន
ធ្វើឲ្យប្រាណមានបញ្ញាក្លាយោបល់
ឲ្យក្លាដែរតែក្លាល្ងើយឡើយហួសផល
បានកង្វល់ដល់ទោសទុក្ខគុកខ្នោះឃ្នាង ។
ប្រាណក៏ស្អុយហុយអសោចដូចខ្មោចឆ្កែ
ក្អែកល្អក់ស្មៃបែរចំគេគេដើររេង
ឯដំណើរដើរទ្រេតទ្រោតលោតយកកង
ជួនរមួលជួលបង្គ្រាងស្រទាងផ្ងារ ។
រៀងសង្វាត់បាត់សម្ងំខំបិទបាំង
តែផឹកជ្រលផ្តុលជោគខ្លាំងតាំងពេហារ
ប្រឹងសំដែងវែងសំដីដោយទំផ្ចារ
ទាល់បែកការបាររឿងនោះសុសក្មួមហាន ។

ចូលជំនុំប្រជុំជនទទ់សិរី
ទោះពាក្យអ្វីស្ដីទៅតាមស្នាមលំអាន
គង់តែគេបែរខ្នងឲ្យដោយគិតស្មាន
ជឿថាប្រាណបានតែប្រាជ្ញអំណាចស្រា ។
គ្រាក្រទ័លស្គាល់អ្នកមានធនធានស្តុក
ទៅខ្ចីបុលរុលត្រកមុខថ្លៃធ្នារ
អង្វរគេគេមិនឲ្យដោយជឿថា
អ្នកប្រមឹកផឹកសុរាណាបេះសង ។
ម្ល៉ោះហើយទ្រាំពាំក្តីក្រតកូនទៅ
ត្រូវគេដៅម៉ៅផល់ពង្សវង្សផៅផង
ថាពូជនោះលុះល្បែងស្រាក្អាកក្អួង
មិនត្រូវប៉ងបងជាមិត្តស្និទ្ធមេត្រី ។
ទ្រព្យក៏អស់យសក៏អាប់យ៉ាប់ទាំងគ្រប់
គួរតែឈប់គប់សុរាការអប្រិយ
សាងជីវិតគិតផ្ចិតផ្ចង់អង្គជាថ្មី
កបសិរីល្បីកេរ្តិ៍ឈ្មោះយសថ្កើងអើយ !

ជិត់មរចន

បទកាកគតិ

ស្រានាំខូចប្រាណ ស្រាបហ៊ានហួសហាន ស្រាបានខូចឈ្មោះ
ស្រានាំហិនទ្រព្យ ស្រាធ្លាប់ឲ្យល្ងោះ ស្រាបាត់បិត្តស្មោះ ស្រាកោះចូលគុក

ផា - ប៉ូរ

## ផ្នែកអក្សរសាស្ត្រ

# សេចក្ដីសុខ និង សេចក្ដីចំរើន

# របស់ប្រទេសតែងប្រព្រឹត្តទៅជាមួយនឹងវប្បធម៌

លោក វ៉ាយ-ប៊ុក រៀបរៀង

---

១.— អ្វីដែលហៅថា វប្បធម៌? វប្បធម៌ជាភាសាបាលី ប្រែថា: "ការសាប, ការព្រោះ, ការបណ្ដុះពូជ" ។ សំដៅយកការសាបព្រោះនូវវិជ្ជាទាំងផ្លូវលោកទាំងផ្លូវធម៌ ហៅថា វប្បធម៌ ។

ប្រទេសនីមួយ ៗ ត្រូវតែពឹងអាស្រ័យលើវប្បធម៌ គឺវិជ្ជាផ្លូវលោកនិងវិជ្ជាផ្លូវធម៌ ទើបមានវឌ្ឍនភាពតទៅអនាគតបាន ។ វិជ្ជាទាំងពីរនេះ ឲ្យតម្លៃដល់មនុស្ស គឺមនុស្សដែលមានសេចក្ដីអង់អាចក្នុងប្រជុំជន ក្នុងមហាសន្និបាត ដោយសារមានវប្បធម៌, ពោលគឺចេះវិជ្ជានោះឯង ។ មនុស្សណាដែលមានវិជ្ជា, មនុស្សនោះគេហៅថា បណ្ឌិត ឬអ្នកប្រាជ្ញ ។ ប្រទេសនីមួយ ៗ ដែលនឹងចំរើនទៅបាន មកអំពីបណ្ឌិត, អ្នកប្រាជ្ញ, អ្នកមានវិជ្ជាដែលចេះពិចារណារិះរកមធ្យោបាយផ្សេង ៗ ដើម្បីនឹងដោះស្រាយនូវបញ្ហាប្រទេសដែលមានសភាពស្មុគស្មាញ ដូចជាប្រទេសកម្ពុជាយើង ដែលបានឡើងទៅកាន់ឯករាជ្យ ក៏អាស្រ័យមានព្រះមហាបុរស គឺសម្ដេចព្រះឧបយុវរាជ នរោត្ដម-សីហនុ ។

បើពោលតាមលោកសារីយេដឺគ្រិស្តង់ (Charier de Christan) ថា: វប្បធម៌ បានដល់លំនាំនៃប្រាជ្ញា គឺការហាត់ស្ទាត់ជំនាញនូវវត្ថុធាតុ

ដែលនាំឲ្យកើតប្រាជ្ញា ដោយយកការហាត់តាមក្បួនសិក្សាជាមូលដ្ឋាន គឺសម្បទាដែលនាំឲ្យយល់នូវវត្ថុទាំងអស់ ដែលជាលក្ខណៈនៃប្រាជ្ញាដ៏មុះមុត ។

លោកអក្សរសាស្ត្របណ្ឌិតបារាំង ឈ្មោះ "ឡឺសាស" (Le Sage) បានសរសេរទុកក្នុងសៀវភៅ "គិលប្លាសដឺសង់ទិយ៉ាន" ថា: "វប្បធម៌ជាគ្រឿងប្រដាប់សាកល" ព្រោះថាវប្បធម៌មិនមែនសំដៅយកព្រឹត្តិការណ៍ដែលមានមកដោយភាគ ៗ ទេ គឺសរុបយកព្រឹត្តិការណ៍ទាំងអស់មកជាក្បួនមួយ ដែលគ្មានហេតុការណ៍ខាងក្រៅសោះឡើយ ។ ដូចក្នុងទស្សនវិជ្ជាលោក "ដេសកាត្រ" ពោលថា គំនិតនីមួយ ៗ មានន័យដូចគំនិតឯទៀត ៗ, ហើយគំនិតទាំងអស់បានផ្ដិតពណ៌សម្បុរឲ្យគំនិតនីមួយ ៗ គឺថា: "ទាំងអស់មានក្នុងមួយ មួយមាននៅក្នុងទាំងអស់" ។

តាមពាក្យលោកបែន-វ៉ែន-តេង អធិការសិក្សាក្រសួងសិក្សាធិការជាតិ ទីក្រុងណាំងកាំងថា: "ការសិក្សានិងវប្បធម៌មានហេតុមានបច្ច័យទាក់ទងគ្នា ព្រោះថាការចំរើននៃវប្បធម៌របស់ប្រជារាស្ត្រនីមួយ ៗ គឺមកពីថ្នាក់នឹងជម្រៅនៃការសិក្សាប្រជារាស្ត្រនោះ ៗ ដែលមានអារ្យធម៌របស់ខ្លួនជាមូលដ្ឋាន ។ តាមគោលការណ៍នេះ ការសិក្សានិងវប្បធម៌បំបែកញែកចេញពីគ្នាមិនដាច់" ។ ដោយហេតុនេះហើយបានជាថា: "ការសិក្សាត្រូវប្រស្រ័យនឹងវប្បធម៌ ៗ ត្រូវប្រស្រ័យនឹងការសិក្សា" ។

វប្បធម៌ដែលមានន័យជាច្រើនបែបច្រើនយ៉ាងនេះ សរុបសេចក្ដីមក គឺវិជ្ជាផ្លូវលោកនិងវិជ្ជាផ្លូវធម៌នោះឯង ។

២.— ចុះវិជ្ជាផ្លូវលោកមានប៉ុន្មានយ៉ាង?

វិជ្ជាផ្លូវលោក, បើតាមលោកគរឹឯកខ្មែរឈ្មោះឧកញ៉ាសុត្តន្តប្រីជាឥន្ទ បានថ្លែងក្នុងសៀវភៅ ""លោកនីតិបករណៈ"" ថា: មាន ១៨ យ៉ាងគឺ

សិល្បសាស្ត្រទាំងឡាយដប់ប្រាំបី   ក្នុងបាលីលោកចែកមាតិកា
សុតិគឺមន្តស្តាប់ភាសា   សម្មុតិជាចេះធម្មសាស្ត្រជាក់
សង្ខ្យាគឺចេះលេខបូកគុណហា   យោគា គឺចេះការគាប់ចាំងផ្ទាក់
នីតិ គឺនីតិសារគ្រោលគុណ   វិសេសការដាក់ទាយជោគជ័យ ។
គន្ធព្វា ចេះក្បួនច្រៀងរាំស្អាត   គណិកា ចេះផ្ទាត់ដោយម្រាមដៃ
ធនុភេទ ចេះមន្តធ្នូសិល្បសៃ   បូរណា ចេះលៃលកព៌ា ។
តិកិច្ឆា ចេះពេទ្យរក្សារោគ   ឥតិហាសា យោគចេះការព្យា
ជោតិ គឺចេះត្រៃវេទ្យា   សព្ទមាយា គឺចេះព្យូហ៍កងទ័ព ។
ឆន្ទតិ គឺចេះឆន្ទតិសាស្ត្រ   កេតុ គឺធ្វៀវធ្លាសផ្លូវសត្វាជាប់
មន្តា គឺចេះមន្តរម្ងាប់   សទ្ទា គឺចេះផ្គាប់ចិត្តអ្នកស្តាប់ ។
សិល្បសាស្ត្រទាំង ១៨ យោគ   មានក្នុងឥធលោក ។ ប្រដាប់
តែងតាំងទុកឲ្យអ្នកផងគ្រាប់   រៀនជាច្បាប់សម្រាប់ការលោកិយ ។

វិជ្ជាផ្លូវលោក, បើញែកតាមបណ្ឌិតសម័យថ្មី មានដោយសង្ខេប ២០ យ៉ាងគឺ:

| | | |
|---|---|---|
| ១ – | បរមត្ថវិជ្ជា | Métaphysique |
| ២ – | ទស្សនវិជ្ជា | Phylosophie |
| ៣ – | ចិត្តវិជ្ជា | Psychologie |
| ៤ – | វិទ្យាសាស្ត្រ | Sciences |
| ៥ – | ធម្មសាស្ត្រ | Jurisprudence, droit |
| ៦ – | គណិតសាស្ត្រ | Mathématiques |
| ៧ – | អក្សរសាស្ត្រ | Littérature |
| ៨ – | ប្រវត្តិសាស្ត្រ | Histoire |
| ៩ – | ភូមិសាស្ត្រ | Géographie |
| ១០ – | ធរណីសាស្ត្រ | Géologie |
| ១១ – | រណសាស្ត្រ | Art militaire |
| ១២ – | សិល្បសាស្ត្រ | Beaux arts |
| ១៣ – | ឧទកសាស្ត្រ | Océanographie |
| ១៤ – | ទំនៀមទម្លាប់ប្រពៃណីវិជ្ជា | Ethnologie |
| ១៥ – | សមជ្ជវិជ្ជា | Musique |
| ១៦ – | ឧតុនិយមវិជ្ជា | Météorologie |
| ១៧ – | តារាសាស្ត្រ | Astronomie |
| ១៨ – | ហោរាសាស្ត្រ | Astrologie |
| ១៩ – | នយោបាយ | Politique |
| ២០ – | គរុវិជ្ជា | Pédagogie |

បើចែកមួយបែបទៀត មាន ១០ យ៉ាង គឺ

១ – វិជ្ជានយោបាយ

២ – „ សេដ្ឋកិច្ច

៣ – „ ហិរញ្ញវត្ថុ

៤ – „ សិក្សា

៥ – „ សាធារណការនិងទូរគមនាគមន៍

៦ – „ ទាហាន

៧ – „ សុខភាពនិងអនាម័យ

៨ – „ តុលាការ

៩ – „ ឃោសនា

១០ – „ គ្រប់គ្រងប្រទេស ។

មនុស្សណាដែលមានវិជ្ជាម្ភៃយ៉ាង ឬ ១០ យ៉ាង ឬ វិជ្ជាណាមួយ គេហៅថា បណ្ឌិត ។

៣.– ចុះវិជ្ជាទាំងដប់ដែលរាប់ក្រោយបង្អស់នេះ ឲ្យសុខឲ្យចំរើនដល់ប្រទេសយ៉ាងណាខ្លះ?

ក) វិជ្ជានយោបាយ បុគ្គលអ្នកមានវិជ្ជាខាងនយោបាយ បេះរិះរកនូវមធ្យោបាយគ្រប់យ៉ាង ដើម្បីនឹងធ្វើដំណើរការប្រទេសជាតិមាតុភូមិឲ្យបានសុខស្រួលទៅតាមសន្តិភាព ។ បើតាមពិត គឺនាយករដ្ឋមន្ត្រីនេះឯងជាមេនយោបាយប្រទេស ។ ប្រទេសដែលឡើងទៅកាន់វឌ្ឍនភាព ឬចុះទៅកាន់វិនាសកម្ម ក៏មកពីនាយករដ្ឋមន្ត្រី, ប្រៀប

ដូចនាយកាច់ចង្កូតនាវា ត្រូវតែតស៊ូនឹងរលកព្យុះសង្ឃរា ទើបនាវាទៅដល់ពាមពោលគឺសន្តិភាពបាន ។ អ្នកនយោបាយបែបនេះគេហៅថាអ្នកនយោបាយឯក, អ្នកនយោបាយជំនាញ, វីរបុរស, មហាបុរស ។ ប្រទេសកម្ពុជាយើងក្នុងសម័យនេះ មានតែសម្តេចព្រះឧបយុវរាជនរោត្តមសីហនុនេះឯង ជាអគ្គបុរសនយោបាយ ព្រះអង្គប្រកបដោយព្រះប្រាជ្ញាដ៏ឈ្លាសវៃ, មានព្រះបដិភាណគួរឲ្យស្ញប់ស្ញែង ទ្រង់បានដឹកនាំប្រទេសកម្ពុជាទៅកាន់ឯករាជ្យពេញលក្ខណៈ និងឲ្យចូលជាសមាជិកនៃអង្គការសហប្រជាជាតិ ដោយគ្មានលោហិតហូរមួយតំណក់សោះ បានជាប្រជារាស្ត្រខ្មែរលើកតំកើងព្រះអង្គ ថ្វាយព្រះបរមនាមថា: “ព្រះមហាវីរក្សត្រិយ៍, ព្រះបិតាឯករាជ្យនៃប្រទេសកម្ពុជា” ។

យ៉ាងដូចម្តេចដែលហៅថា នយោបាយ? តើនយោបាយមានប៉ុន្មានយ៉ាង?

មុននឹងពណ៌នាអំពីនយោបាយ សូមលើកយកសេចក្តីប្រៀបមកពោលមុន :

មានអ្នកដំណើរម្នាក់ មានប្រាក់ ១០.០០០ រៀល ដើរតាមផ្លូវមួយ, ផ្លូវនោះមានព្រៃខ្លា, រួចទៅដល់ស្ទឹងមួយមានក្រពើ, មានផ្លូវតទៅទៀតមានចោរពួនស្ទាក់នៅក្នំមួយ, រួចទើបបានទៅដល់ភូមិដែលខ្លួនបំរុងនឹងទៅ ។ បើអ្នកដំណើរនោះ បានធ្វើដំណើរទៅហើយ បានរួចពីមាត់ខ្លា, មាត់ក្រពើ, ផុតពីកណ្តាប់ដៃចោរបាន គេហៅថាជាអ្នកមេនយោបាយឯក ។ ព្រោះហេតុនេះ នយោបាយនោះ បានដល់វិជ្ជាចេះ

ប្រែកប្រែទៅតាមកាលៈទេសៈ ដូចអ្នកដំណើរខាងលើ, អ្នកធ្វើនយោបាយលុះត្រាតែចេះវិជ្ជាលក្ខណៈខ្លា, ចរិយាក្រពើ, កិរិយាចោរ ហើយវៃទៅតាមមធ្យោបាយផ្សេង ៗ ឲ្យផុតពីកណ្ដាប់ដៃបច្ចាមិត្តទាំងអស់, ទើបហៅថាជាអ្នកចេះនយោបាយ, ជាមេនយោបាយយ៉ាងឆ្នើម ។

ប្រទេសនីមួយៗ ត្រូវមាននាយករដ្ឋមន្ត្រីជាមេនយោបាយ ចេះប៉ិនប្រសប់ត្រួតត្រាប្រទេស ឲ្យប្រជារាស្ត្របាននៅសេចក្ដីសុខស្រួល, ធ្វើឲ្យប្រទេសសម្បូណ៌ដោយភោគទ្រព្យ, ដឹកនាំប្រទេសឲ្យមានកិត្តិស័ព្ទល្បីល្បាញទៅដល់មហាប្រទេសទាំងឡាយ ។ នយោបាយនេះឯងជាវប្បធម៌ដែលអាចឲ្យសុខ-ចំរើនដល់ប្រទេសបាន ។

ខ) វិជ្ជាសេដ្ឋកិច្ច ជាវិជ្ជាមួយដែលធ្វើមនុស្សឲ្យចេះធ្វើក្សេត្រកម្ម, កសិកម្ម, ពាណិជ្ជកម្ម, ឧស្សាហកម្ម ដែលអាចរចនាប្រ-ទេសឲ្យមានភោគទ្រព្យសម្បត្តិសម្បូណ៌ ធ្វើឲ្យប្រជារាស្ត្រទៅជាកុដុម្ពិក, គហបតី, សេដ្ឋី ៗ វិជ្ជានេះឯងហើយដែលធ្វើឲ្យមហាប្រទេស សហរដ្ឋអាមេរិក, ប្រទេសហ្គ្រង់ប្រិតាញ, ប្រទេសបារាំង, ប្រទេសរុស្ស៊ី, ប្រទេសចិន, ប្រទេសជប៉ុន ជាដើម មានតម្លៃ មានសមត្ថភាព មានកិត្តិសព្ទខ្ចរខ្ចាយខ្ចួទៅពេញសកលលោក ។

គ) វិជ្ជាហិរញ្ញវត្ថុ ជាវិជ្ជាមួយដែលអាចត្រួតត្រាប្រាក់ចំណូលចំណាយក្នុងប្រទេស, យកប្រាក់នោះទៅធ្វើជាប្រយោជន៍

សាធារណៈ ចំពោះជាតិមាតុភូមិ បេះពណ៌នាអំពីក្បួនធ្វើបញ្ជីសព្វគ្រប់, ថវិកាជាតិ, គម្រោងនាគារ, វិធានការណ៍ខាងរូបិយប័ណ្ណជាដើម ។

ឃ) វិជ្ជាសិក្សា អាចឲ្យប្រជាកស្ត្របេះដឹងនូវវិជ្ជាគ្រប់យ៉ាង ទាំងវិជ្ជាលោកវិជ្ជាធម៌, អាចឲ្យបត្តប្រទេសឲ្យសម្បូណ៌ដោយអ្នកបេះដឹងច្រើន ទៅជាវរជន ។ វរជនទេះឯង ជាអ្នកជួយដោះស្រាយបញ្ហាប្រទេសដែលចុះក្នុងស្ថានការណ៍ជុនជាប ឲ្យបានសន្តិភាព ។ វិជ្ជាខាងផ្លូវធម៌ជាផ្នែកប្រមុះរបស់វិជ្ជាខាងផ្លូវលោក ។ ប្រទេស, បើមានតែវិជ្ជាផ្លូវធម៌ គ្មានវិជ្ជាផ្លូវលោក ប្រជាកស្ត្រនឹងទៅជាអ្នកស្លូតបូត, ប្រទេសដទៃនឹងមកកំភ្លើញ, គំរាម យកធ្វើជាអាណានិគម ។ ប្រទេស, បើមានតែវិជ្ជាលោក គ្មានវិជ្ជាធម៌ ប្រជាកស្ត្រនឹងទៅជាអ្នកកាចពាលសាមាន្យ, ក្តៅឆេះគ្មានទឹកលត់ ។ ព្រោះហេតុដូចនេះ វិជ្ជាផ្លូវលោក ផ្លូវធម៌ទាំងពីរ ត្រូវមានក្នុងប្រទេសនីមួយៗ ដើម្បីនឹងលៃលកតាមគួរការ តាមស្ថានការណ៍នឹងគួរនៃប្រទេស តាមពេលវេលា ។

ង) វិជ្ជាសាធារណការ និង ទូរគមនាគមន៍ អាចឲ្យបត្តប្រទេសឲ្យមានអាកាសយាន អាយស្ម័យយាន, ផ្លូវថ្នល់, រថី, ស្ពាន, គេហដ្ឋាន, អណ្ដូងទឹក ទៅតាមសេចក្តីត្រូវការ នឹងតាមកាលៈទេសៈ, ឲ្យមានប្រៃសណីយ៍, ទូរលេខ, ទូរស័ព្ទ, បញ្ជូនដំណឹងដល់គ្នានឹងគ្នាបាន នឹងផ្សាយវិទ្យុដែលជាសំឡេងប្រទេស ឲ្យនាំកិត្តិស័ព្ទដ៏ល្អទៅច្រាប់បរទេស ។

ច) វិជ្ជាឃោសនា ជាវិជ្ជាដឹកនាំដំណឹងទៅផ្សាយ គ្រប់និគម ជនបទ, ខេត្ត, ស្រុក, ឃុំ ឲ្យប្រជារាស្ត្របានជ្រាបនូវអត្ថរសនៃកិច្ចការ ទាំងឡាយរបស់រដ្ឋ ។

ឆ) វិជ្ជាទាហាន ឬរណវិជ្ជា ជាវិជ្ជាសម្រាប់ការពារប្រទេស កុំ ឲ្យបច្ចាមិត្តចូលមកលុកលុយបាន; វិជ្ជាក្បួនទ័ពជើងគោក, ជើងទឹក និងជើងអាកាស, នេះជាកំពែងគាំពារឲ្យប្រជារាស្ត្របានសុខស្រួល, ប្រកបរបរចិញ្ចឹមជីវិតបានដោយងាយ, ធ្វើគមនាគមន៍មិនមានភ័យកិត និងចោរកម្ម . . . (ល) ។

ជ) វិជ្ជាសុខភាព និងអនាម័យ ដែលហៅថាវេជ្ជវិជ្ជា ជាវិជ្ជាថែ ទាំព្យាបាលពេលអ្នកមានអាពាធ, ឲ្យឱសថ, ផ្សាយក្បួនប្រសូតបុត្រ, ការកវប្បកម្ម, បោសច្រាសសំអាតគេហដ្ឋាន ទីលំនៅ, សំអាតខ្លួន ប្រាណ . . . (ល) ។ បើប្រជារាស្ត្រមានសុខភាពបរិបូណ៌ហើយ និងអាចបំពេញករណីយកិច្ចជាពលរដ្ឋបានពេញកម្លាំង, ប្រទេសនឹង បានចំរើនជាមិនខាន ។

ឈ) វិជ្ជាតុលាការ សម្រាប់ឲ្យប្រជារាស្ត្រណាមិនប្រព្រឹត្ត តាមច្បាប់របស់រដ្ឋ ត្រូវទទួលទណ្ឌកម្មឲ្យរាងចាល, ឲ្យគូក្តីទាំងសងខាង មានផ្លូវតក៉ជំនុំជំរះក្តីទាំងឡាយ, សម្រេចក្តីចេញសាលក្រមកាត់ទោស ដាក់គុក ពិន័យលក់ជាដើម ។ បើគ្មានតុលាការ, មនុស្សនឹងអាង

កម្លាំងបាយ, អ្នកណាពូកែជាល់គប់ អ្នកនោះនឹងទៅជាចៅហ្វាយគេជាម្ចាស់គេ ។

ញ) វិជ្ជាគ្រប់គ្រងប្រទេស ជាវិជ្ជាសម្រាប់ឲ្យចេះរបៀបគ្រប់គ្រងមនុស្សឲ្យបានសុខស្រួល, ឲ្យមានសន្តិភាព, ឲ្យប្រកបការរកទទួលទានបានដោយសេរីជាដើម ។

ក្រៅពីនេះ, នៅមានវិជ្ជានៃការអប់រំមូលដ្ឋាន ដែលមានបុគ្គលជាសស្ត្រាចារ្យជំនាញទៅពន្យល់ប្រជាកស្ត្រប្រុស ស្រី ឲ្យចេះនូវសុខភាព, អនាម័យ, របៀបរករបរទទួលទាន, របៀបជីកអណ្តូងទឹក . . . (ល) ។

នៅមានវិជ្ជាជាច្រើនទៀត ដូចជាវិជ្ជាហាត់ប្រាណដែលអប់រំរូបកាយ ឲ្យមានពលភាព, សុខភាព, វិជ្ជាខាងសាសនា មានពុទ្ធសាសនា, គ្រិស្តសាសនា, ព្រហ្មញ្ញសាសនាជាដើម នឹងលទ្ធិឯទៀត ដែលពោលអំពីសីលធម៌ បង្ហាញនូវវិធីប្រតិបត្តិឲ្យបានសុខស្រួល បន្តិលផ្លូវទាប, កណ្តាល, ខ្ពស់ ដែលយើងទាំងអស់គ្នាត្រូវដើរ ដើម្បីនឹងទៅកាន់សុគមង្គលតាំងពីលោកនេះ រហូតដល់លោកខាងមុខ, ពីសុខជាន់ទាប គឺកាមិសសុខ ដែលជាសុខលាយឡំដោយទុក្ខក្នុងលោក រហូតដល់សុខជាន់ខ្ពស់ គឺនិរាមិសសុខ ដែលជាសុខដ៏ឧត្តម, សុខក្នុងព្រះនិព្វាន ។

ការបណ្តុះវិជ្ជាទាំងអស់នេះ ហៅថា វប្បធម៌ ។ នេះ ជាអរិយធម៌ទៀតដ៏ប្រសើរ, ជាគេនៈដ៏វិសេសក្នុងលោក អាចឲ្យសុខ-ឲ្យចំរើនដល់

ប្រទេសជាតិមាតុភូមិបាន ដូចលោកសុត្តន្តប្រីជា ឥន្ទ បានពោលទុកក្នុង "លោកនីតិបករណ:" ថា:

"នាកាលកើតកលិយុគយុទ្ធនា ព្រះរាជាត្រូវការអ្នកក្លាហាន,
នាកាលកើតព្យាធិយាយីប្រាណ ទ្រង់ចង់បានពេទ្យបេះមន្តសុទ្ធា ។
នាកាលពេលបរិភោគអាហារឆ្ងាញ់ ចង់បានមិត្តសំឡាញ់មកភោគ្គា,
នាកាលកើតកិច្ចអាថ៌ប្រស្នា សឹងប្រាថ្នាក្រាជ្ញអាចដោះស្រាយ" ។

បើព្រះមហាក្សត្រិយ៍ មានបណ្ឌិតខាងវប្បធម៌គ្រប់ប្រភេទដូច្នេះ ប្រទេសជាតិមាតុភូមិ នឹងបានសេចក្តីសុខ-ចំរើន ព្រោះបណ្ឌិតទាំងនេះ អាចជួយជ្រោមជ្រែងព្រះមហាក្សត្រិយ៍ ក្នុងការដោះស្រាយបញ្ហាប្រទេស ដែលកើតមានឡើងភ្លាម ៗ បាន ។ វប្បធម៌នេះ មានគុណានុភាពជា អនេកប្បការ ព្រោះហេតុនោះ ការរចនាប្រទេសជាតិមាតុភូមិ ត្រូវតែរចនាវប្បធម៌ជាមូលដ្ឋាន ។

វប្បធម៌នេះឯង បើស្ថិតនៅលើបុរសឬស្ត្រីណា អាចធ្វើបុរសស្ត្រីនោះឲ្យបានតម្លៃ មានកិត្តិសព្ទល្បីល្បាញ, ទៅណាមកណាទេវតានឹងមនុស្សទាំងឡាយតែងគោរពបូជា ។ វប្បធម៌នេះ ក្នុងពេលដែលប្រទេសធ្លាក់ក្នុងអាសន្នកម្ម អាចជួយទ្រទ្រង់ប្រទេសឲ្យរួចផុតពាកឧបទ្រព, ឲ្យរួចអំពីវិនាសកម្ម ឲ្យបានសេចក្តីសុខ-ចំរើនជាកិយេក្រាភាពតទៅ ។ ប្រទេសណាសម្បូណ៌ដោយវប្បធម៌, ប្រទេសនោះមានបណ្ឌិត, អ្នកប្រាជ្ញប្រើទុកជាព្រះរាជទីប្រឹក្សានៃព្រះមហាក្សត្រិយ៍, ដើម្បីនឹងធ្វើនយោបាយខាងក្នុងប្រទេសនឹងខាងក្រៅប្រទេស ឲ្យស្របទៅតាមនយោបាយ

នៃមហាប្រទេសទាំងឡាយ ជាហេតុឲ្យកើតសេចក្តីសុខ-ចំរើនក្នុងលោក សន្និវាសតទៅអនាគត ។ ប្រទេសកម្ពុជាបានឯករាជ្យ ប្រកបដោយកេតនភ័ណ្ឌគ្រប់យ៉ាង ហើយបានចូលជាសមាជិកនៃអង្គការសហប្រជា-ជាតិអប់រំនូវវប្បធម៌ដែលជាប្រទីបសម្រាប់បំភ្លឺមាគ៌ានយោបាយ ណែនាំនាវា គឺប្រទេសកម្ពុជានេះ ទៅកាន់វឌ្ឍនភាព, សម្បូណ៌ភាព, សន្តិភាព សមទៅតាមព្រះរាជបំណងនៃសម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ។ សេចក្តីសុខ-ចំរើននៃប្រទេសកម្ពុជា ស្ថិតនៅត្រង់ការអប់រំនូវវប្បធម៌ ។ បើជនជាតិខ្មែរមានវប្បធម៌ហើយ ឈ្មោះថាមានបណ្ឌិតច្រើន ដែលគេទុកជាបុប្ផាតែងផ្សាយក្លិនក្រអូបទៅគ្រប់ទិសានុទិស ។ បណ្ឌិតវប្បធម៌ជាសសរកន្ទោង ដែលគាំទ្រគេហដ្ឋានជាតិគឺប្រទេសកម្ពុជា ការពារកំដៅថ្ងៃ, ទឹកភ្លៀង, ខ្យល់ព្យុះសង្ឃ្រា, រោគាគ្រប់យ៉ាង បានសេចក្តីសុខ-ចំរើនដល់ប្រជារាស្ត្រទាំងអស់ ។ បើប្រជារាស្ត្របានសុខហើយ ទើបធ្វើការជាប្រយោជន៍ជាតិ, សាសនា, មហាក្សត្រិយ៍, ឲ្យបានល្អលាស់ចំរើនតទៅបាន ។ វប្បធម៌, បណ្ឌិតទុកជាកំពែងកែវមណីជោតិ សម្រាប់ការពារជាតិ, សាសនា, មហាក្សត្រិយ៍, វប្បធម៌ជាជីវិតនៃមាតុភូមិ ត្រូវតែប្រជាជនខ្មែរព្យាយាមអប់រំ ប្រឹងប្រែងសិក្សាឲ្យបានទាន់កាលសម័យ ដើម្បីនឹងទៅរួមប្រជុំ ដើម្បីសន្តិភាពជាតិ និងសន្តិភាពលោកជាអវសាន ។

## ពេជ្រព្រះភាជា

## លោក ស៊ុន-ហ៊ាន ប្រែរៀបរៀង
## លោក យូរ-អ៊ុន ពិនិត្យកែសម្រួល

(តម៉ក)

ថ្ងៃមួយ, បុទ្ធិស័ត្វទៅផ្ទះលោកនន្ទិដើម្បីសុំដែនសេចក្ដីស្និទ្ធស្នាលនឹងនាងកាញ្ញាឲ្យរឹតតែខ្លាំងឡើង ព្រោះគេចង់នៅជិតកាញ្ញា ចង់មើលផ្ទៃមុខដែលប្រកបដោយលំអ និង ចង់ស្ដាប់ពាក្យរបស់ស្ត្រីក្រមុំដែលមានសម្លេងពីរោះគួរឲ្យចង់ស្ដាប់, ឥឡូវនេះ បុទ្ធិស័ត្វស្និទ្ធស្នាលនឹងកាញ្ញាលើសដើម បុទ្ធិស័ត្វពេញចិត្តយកចិត្តស្ត្រីក្រមុំ កាលដឹងថានាងត្រូវការអ្វីឬចូលចិត្តអ្វី ក៏គេបំពេញបំណងនាងភ្លាម, តាមពិត កាញ្ញាជាស្រីចិត្តទន់ចូលចិត្តថ្វាយបង្គំព្រះ, បុទ្ធិស័ត្វកាលមករកនាង គេច្រើននាំផ្កាឈើស្រស់ៗមកផ្ញើកាញ្ញាឲ្យនាងនាំទៅបូជាព្រះ ហើយគេទាំងពីរនាក់ចូលទៅនៅក្នុងបន្ទប់ព្រះជាមួយគ្នា, បុទ្ធិស័ត្វពេញចិត្តនឹងការថ្វាយបង្គំព្រះរបស់កាញ្ញា ក្នុងខណៈដែលនាងថ្វាយបង្គំព្រះដោយបញ្ចង្គប្រតិស្ឋាន ។

បុទ្ធិស័ត្វអត់ទ្រាំសរសើរនាងពុំបាន ទើបនិយាយនឹងនាងថា:

–"កាញ្ញ៉ នាងជាស្ត្រីល្អគ្រប់យ៉ាង ខ្ញុំសូមសរសើរតាមសេចក្ដីពិត"។

–"មិនមែនទេ បងបុទ្ធ៍ ! កាញ្ញ៉មិនមែនជាមនុស្សស្រស់ល្អ កាញ្ញ៉ជាមនុស្សអភ័ព្វ" នាងតបដោយញញឹមទៅរកបុទ្ធិស័ត្វរួចក្រៀមមុខវិញ ។

បុទ្ធិស័ត្យទើបឆ្លើកល់និយាយនឹងនាងថា :

- " កាញ៉! ខ្ញុំមិននិយាយពីល្អពាងកាយនាងតែម្យ៉ាងទេ ខ្ញុំនិយាយពីល្អដួងចិត្តនាងផង ហើយខ្ញុំមិនបាននិយាយពីសេចក្ដីអភ័ព្វរបស់នាងឡើយ ព្រោះអភ័ព្វជារបស់ធម្មតានៃមនុស្ស" ។

- " មិននិយាយម្ដេចបាន បងបុទ្ធ ! កាញ៉នៅមិនទាន់ស្គាល់សេចក្ដីសុខពិតនៅឡើយ ទោះបីកាញ៉មានមនុស្សសរសើរថាកាញ៉ល្អស្រស់ថាកាញ៉ជាកូនស្រីមានពូជ ១ រូប កាញ៉ក៏មិនពេញចិត្តស្មើនឹងកាញ៉មានឪពុកមានម្ដាយនិងបងនៅស្មើមុខនឹងគេទេ ដូច្នេះហើយដែលកាញ៉រែងដំហរថាកាញ៉ជាអ្នកអភ័ព្វ" ។

កងចិត្តបុទ្ធិស័ត្យពេញពោរទៅដោយសេចក្ដីអាណិតអាសូរ ចំពោះកាញ៉នាដែលប្រាប់អំពីការដឹងខ្លួនរបស់នាង ។ មែនហើយ វគដែលមនុស្សពេលគ្នាតែងប្រាថ្នាគឺសេចក្ដីសុខ, ឯការមានឪពុកដែលស្រឡាញ់កូន មានម្ដាយដែលដឹងចិត្តកូន នឹងមានបងដែលស្រឡាញ់ប្អូនដូចនាងកាញ៉នាប្រាថ្នា ជាសេចក្ដីសុខមួយយ៉ាងរបស់នាង ដែលនាងបានយកចិត្តទុកដាក់ដល់ជាទីបំផុត ប្លែកអំពីបុទ្ធិស័ត្យ ដែលបិតាមាតារបស់គេនៅមាន ហើយមានបងប្អូនមនុស្សបំរើរហូតដល់ទ្រព្យសម្បត្តិគេមិនមានទុក្ខអ្វី គេក៏ព្យាយាមលួងលោមទាញយកសេចក្ដីទុក្ខរបស់នាងឲ្យអស់ទៅ ចង់ឃើញនាងមានសេចក្ដីសប្បាយ គេទើបនឹករកពាក្យដែលប្រកបដោយសេចក្ដីពិតមកពោលដាស់តឿននាងថា ៖

-" កាញ់ ! នាងជាមនុស្សដែលខ្ញុំអាណិតខ្លាំងណាស់ ចាប់តាំងអំពីខ្ញុំដែលបានដឹងបានឃើញមកដល់ឥឡូវនេះ, សេចក្ដីទុក្ខរបស់នាងទាំងប៉ុន្មាន សឹងជ្រែកជ្រាបពេញក្នុងចិត្តរបស់ខ្ញុំ តើជឿទេ កាញ់ !" ។

កាញ្ចនាបានស្ដាប់បុទ្ធិស័ក្យនិយាយហើយ នាងស្រស់មុខបន្តិចនិយាយតបថា :

-"ទេទេ មិនជឿទេ ! ព្រោះសេចក្ដីទុក្ខរបស់មនុស្សម្នាក់នឹងបែងចែកឲ្យទៅមនុស្សម្នាក់ទៀតមិនបានជាដាច់ខាត" ។

-"បាន កាញ់ ! បើកាញ់ដឹងចិត្តខ្ញុំ ឃើញចិត្តខ្ញុំពិត ៗ នាងនឹងអាចដឹងបានថា ខ្ញុំមានទុក្ខរួមផងនឹងនាងប្រាកដ តែនេះប្រហែលនាងមិនឃើញ នាងឃើញតែខាងក្រៅ, ស្អុះ នាងគិតមើល ! ពេលណាដែលនាងប្រាប់ខ្ញុំថា នាងមានទុក្ខ, ខ្ញុំក៏កើតញាប់ញ័រក្នុងចិត្ត, នាងជឿថាខ្ញុំទទួលយកចំណែកនៃសេចក្ដីទុក្ខរបស់នាង ហើយកើតទុក្ខជាមួយនឹងនាងផងឬទេ ?" ។

-"កាញ់ជឿពាក្យបងបុទ្ធិឯងខ្លះដែរ បើនិយាយបំពោះត្រង់ដែលបងឃើញកាញ់កើតទុក្ខបងក៏ទុក្ខផង ស្ដីតែកាញ់មិនមានទុក្ខ កាលឃើញគេមានទុក្ខ កាញ់ក៏កើតទុក្ខដែរ ដូចឃើញសុនខឬឆ្មាអត់បាយកាញ់អាណិតអាសូរក៏ណាស់ កាញ់ក៏នឹកដល់ខ្លួនរបស់ខ្លួនឯង ប្រៀបធៀបខ្លួននឹងសត្វ ក៏មិនមានចំណែកអ្វីដែលប្លែកគ្នាទេ ខុសគ្នាតែនិយាយប្រាប់យើងមិនបាន បើជានិយាយបានវិញ ក៏គង់ប្រាប់យើង ក៏គង់

និយាយនឹងយើង សុំតែដែលកាត្រូវការ កាញ្ចមិនព្រមឲ្យសត្វបិញ្ចឹមក្នុងផ្ទះ គឺសុនខនឹងឆ្មាត្រូវអត់អាហារ ក៏ព្រោះហេតុនេះឯង ” ។

បុទ្ធិស័ត្យពេញចិត្តនឹងការណ៍ ដែលខ្លួនបានណែនាំឲ្យកាញ្ចនាសោយនូវសេចក្តីទុក្ខខ្លះ ទើបបបួលនាងទៅអង្គុយក្រោមទ្រូងព្រះវិញ ។ កាលអង្គុយចុះរៀបរយហើយ បុទ្ធិស័ត្យទើបសួរនាងថា :

– “ កាញ្ច ! ដូចម្តេចមិនព្យាយាមធ្វើចិត្តឲ្យសប្បាយរីករាយខ្លះទៅ ? ខ្ញុំបានស្តាប់សំដីរបស់នាងហើយ ខ្ញុំស្មានថា នាងមានគំនិតត្រូវ ល្មមនឹងជាស់តឿនចិត្តខ្លួនឯងបាន ព្រោះបើយើងព្យាយាមគិតថាសេចក្តីទុក្ខនេះជារបស់ធម្មតា តែយើងនឹងបំបាត់របស់ធម្មតានោះមិនបាន កាលបើគិតយ៉ាងនេះ យើងគង់ធូរស្រាលក្នុងចិត្តខ្លះពុំខាន ” ។

“ បុទ្ធិស័ត្យ ! កាញ្ចខំគិតយ៉ាងដែលបងនិយាយណាស់ដែរ តែមិនរសាត់បាត់ទុក្ខព្រយសោះ ត្រឡប់ជាកើតខ្លាំងក្លាឡើងវិញ មិនតែប៉ុណ្ណោះខ្ញុំគិតថា ឥពុកនឹងបងខ្ញុំបានទទួលការស្រឡាញ់ក្តីអំពីព្រះពជាតាំងពីដើមរហូតមក, តែឥឡូវនេះបែរទៅជាព្រះពជាធ្វើទោសយ៉ាងធ្ងន់វិញ កាញ្ចគិតឃើញថាគឺទោសបាបគ្រោះនឹងបាបកម្ម អំពីបុព្វជាតិតាមផ្តល់ឲ្យផល នេះឯងដែលជាសេចក្តីគិតចុងក្រោយបំផុតរបស់ខ្ញុំ ដើម្បីលួងលោមចិត្តខ្លួនឯង ឲ្យរសាយអំពីសេចក្តីសៅហ្មង ” កាញ្ចនាកាលនិយាយបានត្រឹមនេះ នាងត្រឡប់មានមុខស្រងូតស្រងាត់ទៀត, សេចក្តីរីករាយដែលផ្តើមបញ្ចាំងឡើងបន្តិចនោះក៏រលត់ដូចពន្លឺភ្លើង ក្នុងរលេង

រលោងដោយទឹកភ្នែកហើយស្រក់ចុះមក, នាងជប់មុខយំអណ្តឺតអណ្តក មិនស្កាងសោះ នាងអង្គុយបណ្តោយឲ្យទឹកភ្នែកស្រក់ចុះតាមចិត្ត ។

— "ត្រូវធ្វើស្មារតីឲ្យរឹង នាង! កាលបើនាងគិតដល់ធម្មតាមិនបាត់ទុក្ខព្រួយទេ នាងត្រូវគិតឲ្យជ្រៅទៅមុខទៀតថា វត្ថុនេះកើតមានដល់យើងហើយ ហើយយើងដឹងថាវាបានកើតហើយ យើងត្រូវមានល្បិចនឹកមួយបែបទៀតថា របស់ណាដែលកើតមានដល់យើង, របស់នោះមកជាសុខផងមកជាទុក្ខផង ដូច្នេះ នាងត្រូវតាំងស្មារតីឲ្យរឹង កុំបណ្តោយទៅតាមអារម្មណ៍ជាទុក្ខនេះឡើយ" បុទ្ធិសត្យរំលឹកនាងកាញ្ចនា ។

នាងកាញ្ចនាមានទឹកភ្នែកកំពុងហូរ កាលស្តាប់ពាក្យរំលឹកនេះហើយក៏បាត់ស្រក់ រង្វង់ភ្នែកនាងក៏ជ្រះថ្លាឡើង ហើយពោលតបថា :

— "និយាយទៅទៀត បងបុទ្ធ! ខ្ញុំចង់ស្តាប់បងបុទ្ធឯងនិយាយណាស់ ខ្ញុំគិតថា ខ្លួនខ្ញុំនឹងត្រូវស្លាប់ ដោយសារសេចក្តីវេទនាចិត្តនេះ តែឥឡូវនេះខ្ញុំនឹកថាខ្ញុំមិនស្លាប់វិញទេ ព្រោះបានស្តាប់ពាក្យបងឯង ដូច្នេះសូមបងនិយាយទៅទៀតណា" ។

បុទ្ធិសត្យមានចិត្តរីករាយលើសលុប គេកំពុងតែគិតចង់ប្រាប់នាងកាញ្ចនាថា "គេនិយាយនេះដោយសេចក្តីស្រឡាញ់, ម្ចាស់នៃសេចក្តីស្រឡាញ់ គាបដាស់តឿនកាញ្ចនាថា កុំឲ្យនៅក្នុងអំណាចទុក្ខវេទនា, តែខ្លួនគេដាស់តឿនខ្លួនឯងថា កុំឲ្យនៅក្រោមអំណាចនៃសេចក្តីស្រឡាញ់មិនបាន" កាលកំពុងគិតយ៉ាងនេះក៏ភ្ញាក់មាត់ថា :

— "កាញ្ចន៍ ដែលខ្ញុំធ្វើយ៉ាងនេះ គឺធ្វើដើម្បីគិតដោះស្រាយទុរសេចក្តី

វេទនាចិត្តរបស់នាង នឹងលួងលោមនាងឲ្យបាត់ទុក្ខព្រួយ តែខ្ញុំធ្វើនេះព្រោះខ្ញុំស្រឡាញ់នាង" សម្ដីរបស់គេបួតចេញមកយ៉ាងនេះ ដោយមិនដឹងខ្លួន ; ពាក្យសារភាពថាស្រឡាញ់ពួស្សរស្រាលៗ ស្ទើរតែនាងកាញ្ចនាស្ដាប់មិនឮ ។

នាងកាញ្ចនាលុះស្ដាប់ឮហើយក៏ញាប់ញ័ររន្ធត់ស្លុតចិត្ត តែត្រឡប់ជាមិនសូវជឿពាក្យនោះប៉ុន្មានវិញ ទើបសួរថា:

"អ្វីទៅបងបុទ្ធិ ! ស្រឡាញ់ៗ...ដែលបងនិយាយអម្បាញ់មិញ..." កាញ្ចនាមិនអាចនិយាយអ្វីបានទៀត ។

"បាទ ! បងស្រឡាញ់អូនឯង, ចុះអូនប្រាប់បងបានទេ តើអូនស្រឡាញ់បងដែរឬយ៉ាងណា" បុទ្ធិស័ក្យសួរដោយសំឡេងថ្នមស្រាលៗ មានទឹកមុខលាយចំរុះអរនឹងភ័យ មានវង្វង់ក្ដៅកសំឡឹងចំនាង ។

នាងកាញ្ចនាដាក់មុខចុះនៅស្ងៀមមិនតបពាក្យវិញ ដោយស្លុតចិត្តជ្រួតចំទើបមានគម្រោះនិយាយបែបនេះជាដំបូង ។

* * *

— ៣ —

"លោកបាលិតជាទីស្រឡាញ់ ! ឥឡូវនេះលោកបានស្គាល់ឈ្មោះខ្ញុំដ៏ពិតប្រាកដហើយ ព្រមទាំងបានស្គាល់ត្រកូលរបស់ខ្ញុំទៀត ទីបំផុតលោកបានដឹងថា ខ្ញុំស្រឡាញ់នូវកូនក្រមុំលោកនន្ទិ ដែលមានចិត្តប្រែប្រួលព្រមដោយគុណធម៌ តែយើងទាំង២នាក់ស្រឡាញ់គ្នាតែក្នុងចិត្តចំណែកកាយ យើងមិនទាន់ប៉ះពាល់គ្នាទេ ។ លោកបាលិតជាទី

ស្រឡាញ់ ! សូមលោកជ្រាបថា ថ្ងៃក្រោយមក លោកឧទ្ទិទឹងសុរពល បានទទួលការដោះលែងអំពីឃុំឃាំង, រាប់ជាវេលាដែលនៅក្នុងឃុំឃាំង អស់ ៤ ខែ, ការណ៍ដែលរួចទោសនេះ ដោយព្រះរាជាទ្រង់មានសេចក្ដី ករុណាគិតអាសូរខ្លាំង ទើបទ្រង់ត្រាស់បញ្ជាឲ្យអមាត្យឧទ្ទិទឹងសុរពលឲ្យ ត្រឡប់មកនៅក្នុងផ្ទះ, តែរដ្ឋមន្ត្រីបានវិនិច្ឆ័យទោសរបស់អមាត្យទឹងបុត្រ ថាឲ្យដកយសស័ក្តិទឹងតំណែងរាជការ ។ តើលោកជឿឬទេ ថាកាល ឧទ្ទិអមាត្យចេញចាកគុកហើយក្នុងថ្ងៃនោះ ក៏ស្រាប់តែបាត់អំពីផ្ទះ ទាំង សុរពលទឹងនាងកាញ្ចនាក៏បាត់ទៅជាមួយគ្នា មិនមានអ្នកណាដឹងឬជួប ឃើញឡើយ, ខ្ញុំកាលបានដំណឹងថា លោកឧទ្ទិរួចអំពីឃុំឃាំង ក៏បាន ទៅសួរនាំលោកយ៉ាងរហ័សរហួនក្នុងថ្ងៃនោះ តែថ្ងៃណាស់ទៅហើយ ទើបខ្ញុំទៅដល់ ខ្ញុំជួបតែយាយបំរើម្នាក់ដែលស្មោះត្រង់របស់លោកឧទ្ទិ កំពុងយំទួញរៀបរាប់នៅជណ្ដើរផ្ទះ" បុទ្ធិស័ត្យនិយាយ ។

— " យី ! លោកឧទ្ទិទឹងបុត្រទៅបាត់អំពីផ្ទះ ? " អមាត្យបាលិត សួរបញ្ជាក់ដោយទឹកផ្ទៃក្នុងចិត្ត ។

— " បាទ ! ទៅបាត់, រហូតមកដល់ឥឡូវនេះ ខ្ញុំមិនទាន់បាន ជួបនឹង អ្នកណាម្នាក់ ក្នុងបណ្ដាមនុស្សទាំង ៣ នាក់នោះនៅឡើយ, លោកគិត មើលចុះ តើខ្ញុំមានសេចក្ដីទុក្ខលំបាកចិត្តយ៉ាងណាទៅ ចំពោះការ ការឡោះអាល័យនាងកាញ្ចនា" បុទ្ធិស័ត្យតបវិញ ។

អមាត្យបាលិតស្ដាប់រឿងរ៉ាវ ដែលមាណពនិយាយមកទាំងអស់នេះ ក៏នឹកអស្ចារ្យក្នុងចិត្តថា " ដែលអញមកនេះ ត្រឹមតែដើម្បីនឹងស៊ើបរក

អ្នកមានសេចក្ដីឈ្លាសវៃតាមបញ្ញាព្រះរាជា  តែត្រឡប់មកបានស្ដាប់ឯរឿងរ៉ាវរបស់មនុស្សម្នាក់ក្នុងនគរ ១ ដែលជារឿងពិតវិញ, អ្នកនិយាយបានអានដល់សេចក្ដីចេះដឹង ប្រកបដោយគុណធម៌យ៉ាងជ្រាលជ្រៅរបស់បុគ្គលទាំងអស់នោះ  តែដែលបានពោលមកហើយចំពោះអមាត្យនន្ទ, លោកនេះប្រហែលមានសេចក្ដីខូចចិត្តយ៉ាងខ្លាំង  ទើបនាំបុគ្គលបរត់ទៅនៅទីដទៃ,  បុគ្គលដែលគួរអាណិតអាសូរនេះ ទោះទៅទិសណា  នៅកន្លែងណា  ក្រុងណាហើយបានទទួលសេចក្ដីសុខទុក្ខត្រឹមណា  ក៏ជាការកម្រនឹងស្មានត្រូវ,  ឯសេចក្ដីស្រឡាញ់រវាងកូនស្រីលោកនន្ទនឹងមាណពបុទ្ធិស័ត្យ  ក៏ជាសេចក្ដីស្រឡាញ់បរិសុទ្ធមិនមានសៅហ្មងដោយខុសបវេណីឡើយ" អមាត្យបាលិតលុះគិតមកដល់ត្រឹមនេះ ទើបដឹងថាវេលារាត្រីកាលយប់ជ្រៅណាស់ហើយ  ទើបតឿនបុទ្ធិស័ត្យថា:

— "បុទ្ធិស័ត្យ! លោកគួរខំរម្ងាប់ចិត្តនឹងខំធ្វើចិត្តឲ្យជាសុខ រង់ចាំមួយថ្ងៃពីរថ្ងៃទៀត  ក្រែងលោកនឹងបានជួបស្ត្រីក្រមុំជាគូសង្សារនោះ ព្រោះវេលានេះយប់ជ្រៅណាស់ហើយ  គួរយើងនាំគ្នាសម្រាកទៅ"។

— "អញ្ជើញលោកទៅសម្រានមុនចុះ  ខ្ញុំសូមអង្គុយនៅត្រង់នេះមួយស្របក់សិន"  មាណពបុទ្ធិស័ត្យអង្គុយនៅម្នាក់ឯងត្រង់ទីនោះ  គេអង្គុយនឹកដល់ជីវិតគេដែលកន្លងទៅហើយ  ចាប់តាំងអំពីគេបានចេញដើរផ្សូវចាកក្រុងរាជគ្រឹះទៅគប់ប្រកល្ហក  ដើម្បីស្វះស្វែងរកនាងកាញ្ចនាជាគូស្នេហាប៉ុណ្ណោះ  ដោយមិនអាល័យស្រុក  មិនអាល័យបិតាគេទេ កាលគេទៅលាបិតាគេ  បានជម្រាបថា  គេមិនមានសេចក្ដី

សុខតាំងអំពីនាងកាញ្ចនាទៅបាត់ បិតាគេក៏មិនទទឹងទាស់ ព្រោះគាត់ស្រឡាញ់គេជាងកូនឯទៀត ព្រមទាំងបណ្ដោយឲ្យគេបានត្រាច់ទៅតាមចិត្ត ព្រោះឃើញគេស៊ូមិនបានដេកមិនលក់ ព្រមទាំងគាត់ចេញប្រាក់ឲ្យគេជាតម្លៃចាយវាយក្នុងការដើរផ្លូវ អំពីក្រុងរាជគ្រឹះទៀតផង គេអង្គុយលើខ្នងសេះស្ពាយដាវជិះសេះឈប់សម្រាកជារឿយៗ បើបានជួបប្រទះស្រុកណា ផ្ទះណា ដែលជិតនៅក្បែរផ្លូវគេតែងសួរថា "បានឃើញតាចាស់នឹងបុត្របុត្រស្រីដើរមកតាមផ្លូវនេះដែរឬ?" គ្រប់ស្រុកនឹងគ្រប់ផ្ទះដែលគេទៅសួរក មិនមានអ្នកណាម្នាក់ប្រាប់ថា "បានឃើញ" សោះ បុត្តិស័ក្យបណ្ដោយចិត្តឲ្យអណ្ដែតទៅតាមសេចក្ដីគិតទាំងនោះ ជួនចិត្តគេជួបជាទឹកចង់កាត់អាល័យនាងកាញ្ចនាឲ្យបាន, ជួនជាវេលានោះខ្យល់ក្នុងព្រៃកំពុងបក់បួលមកម្ដងៗ, ធ្វើឲ្យព្រះចន្ទបញ្ចេញពន្លឺភ្លឺ ដែលជាខែខាងខ្នើតជិតបូណ៌ទៅខាងនោះហើយ បុត្តិសត្យមើលខែដែលជ្រេជិតនឹងលិចបាំងជ្រុងលោក ទើបចិត្តគេចាប់ភ្លឹករលឹកដល់បិតាដែលគេចេញចោលមកយូរណាស់ហើយ រហូតដល់នឹកឃើញពាក្យដែលបិតាគេពោលនឹងគេថា 'បុត្តិ! ឪពុកចង់ឲ្យកូនឯងមានសេចក្ដីសុខណាស់, ឥឡូវនេះឪពុកជរាណាស់ហើយ បើឯងមានសេចក្ដីសុខចំរើនទាន់ឪពុកនៅរស់ ឪពុកនឹងស្លាប់ដោយបិទភ្នែកជិត ទៅក៏ទៅចុះកូន! បើឯងត្រូវការនឹងតាមរកវត្ថុនោះ ដោយសំគាល់ឃើញថាជាគូព្រេងកូនឯងហើយ, ឪពុកនឹងបួងសួងសូមឲ្យសេចក្ដីប្រាថ្នារបស់កូនឯងសម្រេចសមដូចបំណង ឪពុកសូមអំណោយពរឲ្យគុណព្រះជួយគ្រប់គ្រងរក្សា

កូនឯង" រូបបិតាគេស្ទាបក្បាលគេ កាលគេឱនក្បាលក្រាបក្បែរជើងរបស់ឪពុក ។

ពីមុនមកបុទ្ធិសត្យមិនធ្លាប់គិតដល់ផ្ទះសោះ ទើបតែកើតមានគំនិតលើកនេះជាគ្រាដំបូង រាប់អំពីបានចេញចាកផ្ទះមក, មនុស្សគ្រប់គ្នាដែលឃ្លាតអំពីផ្ទះតែងគិតដល់ផ្ទះ មិនថាផ្ទះនោះធំឬតូចយ៉ាងណាទេ, ការចេញចោលមកយូរៗគេនឹងត្រូវគិតដល់ផ្ទះដែលគេធ្លាប់នៅជានិច្ច, បុទ្ធិស័ត្យទើបចុះសម្រេចចិត្តយ៉ាងដាច់ខាតថា ខ្លួនត្រូវត្រឡប់ទៅរកបិតាយ៉ាងរហ័សវិញ, គេបាននឹកត្រេកអរក្នុងការប្រថុយយកជីវិតរបស់គេ ជួយដោះជីវិតសត្វដែលកំពុងទទួលគ្រោះកម្ម ដោយពិធីបូជាយញ្ញរបស់ព្រះរាជា លុះគិតដល់ត្រឹមនេះ គេក្រោកចាកទីអង្គុយដើរមកកាន់គ្រែដេក ចាប់យកធូបមកដុត ហើយដោតចុះក្នុងជើងធូបដែលនៅត្រង់ក្បាលដំណេក រួចអង្គុយប្រណម្យដៃអធិដ្ឋានក្នុងចិត្តរំឭកគុណនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, ដោយអំណាចនៃសេចក្តីមេត្តាដែលគេបានធ្វើមកក្នុងការជួយដោះជីវិតសត្វជាច្រើន សូមឱ្យគេបានជួបនឹងនាងកាញ្ចនា, ហើយគេក៏ដេកលើគ្រែ មិនយូរប៉ុន្មាន មាណពបុទ្ធិស័ត្យក៏ដេកលក់ស្កប់ ។

(នៅមានតទៅទៀត)

# រឿងសាមកុក

## កណ្ឌទី ២៥

ឧកញ៉ាវិបុលរាជសេនា ង្វៀ-ហ៊ង ប្រែរៀបរៀង

(តមក)

---

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នករាជការផ្លាស់បើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសន្តានស្នេហាជាតិ ។ |

គួនអ៊ូទីងស៊ុនខៀនក៏ដេកលក់ទៅមួយស្របក់ ស្រាប់តែឮស្នូរសំឡេងសេះ នឹងមាត់មនុស្សស្រែក ក៏ភ័យភ្ញាក់ឡើង ។ គួនអ៊ូក៏ស្រែកហៅទាហាន ដែលរក្សាសេះ, ទាហានទាំងនោះក៏ដេកលក់ស្ងៀមមិនដឹងខ្លួនសោះ ។ គួនអ៊ូនឹងស៊ុនខៀន ក៏ក្រោកកាន់ក្របីចុះទៅមើល ស្រាប់តែឃើញបក្ខពួកបងប្អូននឹងអ្នកស្រុកលើកគ្នាមកដេរកូនគួសៀងដែលដួលនៅទីនោះ ។ គួនអ៊ូក៏សួរពួកនោះថា ហេតុម្តេចបានជាកូនគួសៀងមកដួលនៅផ្ទះ? ។ ពួកនោះក៏ឆ្លើយថា អាដែងនេះវាអាក្រក់ណាស់ វាឃើញសេះរបស់លោកល្អ វាលបចូលមកនឹងលួចយកទៅ សេះនោះក៏ធាក់វាដួលនៅទីនេះ ខ្ញុំបានឮសំឡេងស្រែក បានជាបបួលគ្នាមកមើល ។ គួនអ៊ូបានស្តាប់ដូច្នោះខឹងណាស់ ទើបនិយាយថា វានេះអាក្រក់ណាស់ បង្អង់ឲ្យវាដឹងខ្លួនភ្ញាក់ឡើងនឹងធ្វើទោសវាជាទម្ងន់ ។

គ្រូសៀនបានឮសំឡេងអឺងកងក៏ភ័យភ្ញាក់ឡើង ស្ទុះចុះទៅមើលឃើញកូនរបស់ខ្លួនដួលសន្លប់ដូច្នោះ ឮអ្នកស្រុកនិងបងប្អូននិយាយរឿងរ៉ាវឲ្យស្តាប់ គ្រូសៀនក៏គំនាប់អង្វរគួនអ៊ូថា សូមឲ្យលោកអាណិតខ្ញុំម្តងចុះ កូនខ្ញុំនេះវាអាក្រក់ណាស់ ខ្ញុំក៏បានដំរាបរឿងវាឲ្យលោកជ្រាបមកពីមុនរួចហើយ ដែលវាធ្វើខុសដូច្នេះ ខ្ញុំនឹងបានចូលគំនិតជាមួយនឹងវាក៏ទេ ម្តាយវាមានចិត្តស្រឡាញ់វា ព្រោះកូនតែមួយ សូមឲ្យលោកអាណិតអាសូរខ្ញុំ លើកទោសដែលវាធ្វើខុសនោះឲ្យបានចុះ ។ គួនអ៊ូថា "ដែលអ្នកប្រាប់អំពីទុក្ខអ្នកដល់ខ្ញុំនោះ ក៏ដូចពាក្យអ្នកជាប្រាកដ ទោសរបស់វាខ្ញុំក៏ព្រមលើកទោសឲ្យអ្នកហើយ" ទើបបង្គាប់ទាហានឲ្យគេក្រាសេះទុកឲ្យល្អ ហើយក៏នាំស៊ុនខៀនឡើងមកដេកវិញ ។

លុះព្រឹកឡើង គ្រូសៀននឹងភរិយាចេញមកគំនាប់គួនអ៊ូហើយថា កូនខ្ញុំធ្វើខុសហើយលោកអនុញ្ញាតលើកទោសចេញនោះ គុណរបស់លោករកទីបំផុតគ្មានឡើយ ។ គួនអ៊ូឆ្លើយថា អ្នកចូរហៅឲ្យវាចេញមកជួបនឹងខ្ញុំ ៗ នឹងជួយស្តីប្រដៅ ។ គ្រូសៀនឆ្លើយថា កាលពីយប់មិញវាភ្ញាក់ដឹងខ្លួនហើយ ក៏នាំពួកគៀនវេះគេចទៅឯណាបាត់ទៅហើយ ។ គួនអ៊ូបានស្តាប់ហើយ ក៏លាគ្រូសៀននាំបងថ្លៃនឹងស៊ុនខៀនចេញពីផ្ទះនោះទៅចម្ងាយផ្លូវប្រហែល ៣០០ សិន ( ១២ គ.ម. ) ទទួលក្រឡេកឃើញកូនគ្រូសៀននោះជិះសេះនាំមេចោរម្នាក់ជួតក្បាលសំពត់លឿង ជិះសេះកាន់ទួនលើកពួកកៀនប្រហែល ១០០ ជាងនាក់ ចុះពីលើភ្នំមកស្ទាក់ទទឹងផ្លូវ មេចោរនោះក៏ស្រែកហៅគួនអ៊ូថា ខ្លួនយើងឈ្មោះ

ហ៊ុយង្ហួនសៀវផា ទាហានទៀវកុក ខ្លួននឹងទៅណា ទើបអាចហ៊ាននាំគ្នា ចូលដែនយើងមក បើខ្លួនស្រឡាញ់ជីវិត ចូរយកសេះដែលជិះនោះមក ឲ្យយើងៗ នឹងលែងឲ្យទៅ ។ គួនអ៊ូបានស្ដាប់ដូច្នោះក៏អស់សំណើច ហើយថា ខ្លួនជាទាហានទៀវកុកជាចោរនោះធ្លាប់បានឮឈ្មោះឡៅតី, គួនអ៊ូ, ទៀវហ៊ុយដែរឬទេ? ។

ហ៊ុយង្ហួនសៀវឆ្លើយថា ខ្ញុំមិនដឹងទេ គ្រាន់តែឮឈ្មោះ តែគួនអ៊ូនោះ ឮគេថាមុខក្រហមពុកមាត់វែង មានថ្វីដៃខ្លាំងពូកែណាស់, ចុះអ្នកឯងនេះឈ្មោះអ្វី? ។ គួនអ៊ូក៏ស្រាយយកថង់ដែលព្យួរទ្រពុកមាត់នោះ ចេញមកឲ្យហ៊ុយង្ហួនសៀវមើល ។ ហ៊ុយង្ហួនសៀវឃើញច្បាស់ដូច្នោះ ក៏ដឹងថាប្រាកដជាគួនអ៊ូ ទើបលោតចុះពីលើសេះហើយបោះទួនចេញពីដៃ នាំកូនគួសៀងចូលទៅលុតជង្គង់គំនាប់គួនអ៊ូហើយថា "ខ្ញុំបាទមិនដឹងសោះ, ដែលខ្ញុំបាទបាននិយាយមើលងាយទ្រគោះប្រមាថដល់លោកនោះ សូមឲ្យលោកអភ័យទោសខ្ញុំបាទចុះ ព្រោះខ្លួនខ្ញុំបាទនេះតាំងតែពីទៀវកុកស្លាប់ទៅកាលណា ក៏នាំពួកកៀនមកធ្វើជាចោរនៅក្នុងទីភ្នំនេះ, ដែលខ្ញុំបាទបានគិតមកប្រឹងនឹងប្រទូសរ៉ាយលោកគ្រានេះ ព្រោះកូនគួសៀងបបួលនាំមក" ហើយក៏ពណ៌នារឿងរ៉ាវដែលកូនគួសៀងនាំគិតប្រទូសរ៉ាយនោះឲ្យគួនអ៊ូស្ដាប់គ្រប់ប្រការ ។ កូនគួសៀងក៏លុតជង្គង់អង្វរថា ខ្ញុំបាទខុសហើយ សូមឲ្យលោកអភ័យទោសចុះ ។

គួនអ៊ូថា ទោសខ្លួនខុសពីយប់មិញម្ដងហើយ យើងក៏លើកលែងមិនប្រកាន់ ឥឡូវខ្លួនមកគិតគប់គ្នាធ្វើយើងម្ដងទៀត បើយើងនឹងសម្លាប់

ចេញក៏បាន តែយើងគិតដល់ផ្លូវមេត្រីនឹងគួសៀង ឯទោសខ្លួនទាំង ២ គ្រានេះ យើងលើកទោសឲ្យ ដោយយល់ដល់គួសៀងជាបិតាឯង ។ កូនគួសៀងក៏មានសេចក្ដីត្រេកអរណាស់ ហើយលាគួនអ៊ូចេញទៅ ។ ហ៊ុយងួនសៀវនិយាយប្រាប់គួនអ៊ូថា កៀនខ្ញុំបាទម្នាក់ជាពួកអ្នកស្រុកឯលិចនៅធ្វើទាហានទៀវប៉ោ ឈ្មោះជីវធង រូបរាងខ្ពស់ធំមានកម្លាំងខ្លាំង ដែករបស់បានទម្ងន់ ១០ ហាប លុះទៀវប៉ោស្លាប់ទៅហើយ ជីវធងក៏ឃុំពួកកៀនមកធ្វើជាចោរនៅក្នុងដីវស័ន ផ្លូវអំពីនេះទៅប្រហែល ៣០០ សិន (១២ គ.ម.) ខ្ញុំបាទទៅមករកជីវធង ៗ តែងនិយាយចេញឈ្មោះលោកជារឿយ ៗ ហើយបបួលខ្ញុំបាទថា បើបានជួបនឹងលោកនឹងនាំខ្ញុំបាទមកនៅនឹងលោក ឥឡូវនេះជាភ័ព្វបុណ្យខ្ញុំបាទបានមកជួបនឹងលោកមុន ៗ គួនអ៊ូតបថា បានកើតជាប្រុសហើយនាំគ្នាមកធ្វើជាចោរនៅព្រៃដូច្នេះនរណានឹងរាប់អានថាល្អបាន ត្រូវបោលគំនិតអាក្រក់នោះចេញ ហើយនាំគ្នាទៅធ្វើស្រែចំការរកស៊ីក្នុងស្រុកជាប្រក្រតីប្រសើជាជាងនៅព្រៃ ៗ កាលកំពុងតែនិយាយគ្នានៅទីនោះ ស្រាប់តែគួនអ៊ូក្រឡេកទៅឃើញនាយចោរម្នាក់ជិះសេះនាំទាហានប្រហែល ១០០ ជាយ នាក់តម្រង់មក ៗ ហ៊ុយងួនសៀវ ក៏ជំរាបគួនអ៊ូថា ជីវធងមកពីនោះហើយ ៗ គួនអ៊ូឃើញរូបរាងជីវធងខ្ពស់ធំក៏សរសើរថា សមជាទាហាន ៗ ជីវធងមកជិតក្រឡេកឃើញគួនអ៊ូក៏មានអំណរណាស់ ចុះពីលើសេះបោះខ្លួនចេញហើយក៏ចូលមកលុតជង្គង់គំនាប់គួនអ៊ូ ៗ ក៏សួរថា ហេតុដូចម្ដេចបានជាអ្នកឯងស្គាល់ខ្ញុំរាប់អានខ្ញុំ ។

ជីវធេងឆ្លើយថា កាលដែលខ្ញុំបាទនៅនឹងទៀវពៅជាមេចោរនោះ បានដឹងថា លោកមានថ្មីដៃខ្លាំងពូកែនិងមានសតិបញ្ញា ខ្ញុំមានចិត្តប្រាថ្នាប្រុងនឹងមកនៅនឹងលោក តែជាសេចក្តីទញ់ទាល់គំនិត ព្រោះដ្បិតបានជាទៅនៅក្នុងអំណាចទៀវពៅហើយ លុះទៀវពៅស្លាប់ ខ្ញុំបាទក៏មកនៅធ្វើជាចោរព្រៃអាស្រ័យនៅក្នុងកុំផ្ទៅជីវស័ន ក៏បាននិយាយនឹងហ៊ុយង្ហួន សៀវគិតដល់លោកមិនដាច់ ឥឡូវបានមកជួបនឹងលោកហើយក៏ជាបុញ្ញលាភរបស់ខ្ញុំ ៗ សូមនៅធ្វើជាទាហានកាន់សែសេះតាមលោកចុះ ។

គួនអ៊ីបានស្តាប់ដូច្នោះ ក៏ពិគ្រោះមើលក្នុងពាក្យសំដីជីវធេងដែលនិយាយនោះ ក៏ឃើញដូចជាត្រង់សុចរិត ក៏ឲ្យមានចិត្តស្រឡាញ់អាណិតពន់ប្រមាណណាស់ទើបសួរថា: បើអ្នកចង់ទៅនៅនឹងយើង តើពួកកឿនរបស់អ្នកនោះនឹងជាម្តេចទៅវិញ? ។ ពួកកឿនជីវធេងបានឮដូច្នោះទាំងអស់គ្នា ក៏ចូលមកលុតជង្គង់គំនាប់គួនអ៊ីហើយថា យើងខ្ញុំទាំងអស់គ្នាសូមចូលទៅនៅនឹងលោកផង ។ គួនអ៊ីឮដូច្នោះ ក៏ចុះពីលើសេះទៅប្រាប់បងថ្លៃទាំងពីរ ។ នាងកាំហ៊ូយិនប្រាប់ថា តាំងពីយើងចេញពីស្រុកហ៊ូគោមក ក៏បានសេចក្តីទុក្ខព្រួយលំបាកពន់ពេកណាស់ ប្អូនក៏គ្មានទីកំគិតនឹងរកអ្នកឯណាជាពួកកឿនសោះ វេលានេះមកជុតទុក្ខភ័យហើយនឹងទទួលមនុស្សយកទៅប្រយោជន៍អ្វី មួយទៀត លៀវហ៊ូមេចោរនោះក៏មានគុណដល់បងបានអង្វរសុំមកជាមួយផង ប្អូនឯងក៏ថាជាចោរនឹងឲ្យជូនមកខ្លាចគេគរហានិន្ទាថាគប់នឹងចោរ វេលានេះបើប្អូនទៅទទួលជីវធេងវិញជាគួរឬមិនគួរយ៉ាងម្តេច ស្រេចនៅលើប្អូនគិតមើលទៅចុះ ។

គួនអ៊ីបានស្ដាប់ដូច្នោះ ក៏លោត្រឡប់ទឹកឃើញហើយនិយាយនឹងជីវចេងថា បងថ្លៃយើងទាំង ២ ជាធំ មិនព្រមឲ្យអ្នកទៅផងទេ អ្នកប្ដូរគ្រប់គ្រងរក្សាគ្នារង់ចាំនៅទីនេះសិនចុះ បើយើងទៅជួបនឹងឡៅពីជាបងយើងវេលាណា សឹមយើងត្រឡប់មកទទួលអ្នកយកទៅនៅជាមួយគ្នា ៗ ជីវចេងបានស្ដាប់ដូច្នោះ ក៏លុតជង្គង់គំនាប់ហើយថា ខ្លួនខ្ញុំបាទបានកើតមកជាតិទាហានបានប្រព្រឹត្តភ្លាត់ភ្លាំងទៅធ្វើជាពួកចោរ ឧបមាដូចជាបួលទៅនៅក្នុងទីងងឹត ឥឡូវមកជួបនឹងលោកដូចបានមកឃើញទីដែលភ្លឺស្វាង ទោះបីបងថ្លៃលោកយល់ឃើញថា ពួកខ្ញុំបាទជាពួកចោរមិនគួរនឹងយកទៅ តែពួកកឿនទាំងអស់នោះខ្ញុំបាទនឹងឲ្យនៅនឹងហ៊ុយជួនសៀវចុះ ឯខ្លួនខ្ញុំបាទមួយ នឹងសូមកាន់សែសេះតាមលោកទៅ ទំរាំតែអស់ជីវិត សូមឲ្យលោកអាណិតចុះ ៗ

គួនអ៊ីបានស្ដាប់ដូច្នោះហើយក៏មានចិត្តអាណិតមេត្តា ទើបវិលសាយកសេចក្ដីនោះទៅជំរាបអង្គរបងថ្លៃទៀត ៗ នាងកាំហ៊ូយនិងថា បើគេនឹងចង់ទៅតែមួយនាក់ពីរនាក់ ក៏ទៅចុះ ៗ គួនអ៊ីក៏វិលមកប្រាប់ជីវចេងវិញតាមពាក្យបងថ្លៃ ៗ ហ៊ុយជួនសៀវឮហើយក៏ថា ខ្ញុំបាទសូមទៅផងបានជា ២ នាក់នឹងជីវចេង ៗ ឆ្លើយថា បើអ្នកទៅផងហើយ តើពួកកឿនរបស់យើងនឹងបាននរណាត្រួតត្រារក្សា នឹងមិនខ្ចាត់ខ្ចាយទៅទេឬ? អ្នកប្ដូរនៅគ្រប់គ្រងរក្សាពួកកឿនសិនចុះ ចាំយើងទៅនឹងគួនអ៊ី បើបានទីកន្លែងសំណាក់ហើយ នឹងវិលត្រឡប់មកទទួលអ្នកនឹងពួកកឿនទាំងអស់នាំ

យកទៅ ។ ហើយនួនសៀវយល់ឃើញត្រូវ ក៏លាគួនអ៊ូត្រឡប់នាំពួកម៉ាកទៅនៅកន្លែងដែលធ្លាប់នៅនោះវិញ ។

គួនអ៊ូក៏នាំបងថ្លៃនឹងស៊ុនទៀនជីវចេងដើរផ្លូវទៅបាន ៣ ថ្ងៃ ស្រាប់តែក្រឡេកមើលទៅឃើញកំពែងល្វើងក្តិធំ ១ គួនអ៊ូក៏សួរអ្នកស្រុកនោះថា ស្រុកនេះឈ្មោះអ្វី នរណាទៅរក្សា? ។ ពួកអ្នកស្រុកនោះប្រាប់ថាឈ្មោះស្រុកកៅសៀ មានទាហានម្នាក់ឈ្មោះទៀវហ៊ុយមានថ្វីដៃខ្លាំងពូកែណាស់ បាននាំពួកកៀនប្រហែល ៥០ ប្លាយនាក់ចូលមកដេញចៅហ្វាយស្រុកនេះចេញ ទៀវហ៊ុយក៏នៅរក្សាស្រុកលុះដល់សព្វថ្ងៃ តែងតែបញ្ចុះបញ្ចូលមនុស្សម្រាមហាជនជាកម្លាំងបានប្រហែល ៥ ០០០ ប្លាយ ស្បៀងអាហារក៏បរិបូណ៌ឥតខ្វះ បណ្តាខេត្រចំណតូបធំទាំងពួងក៏កោតញញើតថ្វីដៃទៀវហ៊ុយ មិនមាននរណាអាចមកញាំញីបានឡើយ តាំងពីទៀវហ៊ុយមកឈររក្សាស្រុកនេះប្រហែលជាង ៥ ខែហើយ ។

គួនអ៊ូបានស្តាប់ដូច្នោះក៏សែនមានអំណរណាស់ ទើបនិយាយនឹងស៊ុនទៀនថា តាំងពីបែកខ្ចាត់ស្រុកជីចវមក យើងបងប្អូន ៣ នាក់ក៏ត្រាត់ប្រាសនិរាសគ្នា ឯឡេវពីនោះបានដឹងដំណឹងហើយ នៅតែទៀវហ៊ុយ ទើបនឹងបានដំណឹងក្នុងថ្ងៃនេះ អ្នកចូរស្រូតទៅប្រាប់ដល់ទៀវហ៊ុយឲ្យចេញមកទទួលបងថ្លៃទាំង ២ ជាប្រញាប់ចុះ ។ ស៊ុនទៀនទទួលពាក្យគួនអ៊ូហើយក៏លាចេញទៅ ។

(មានត)

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

(រឿងព្រេងតំណាល)

## លោកសមិន ម្ចៀនជម:តែង

## លោករ៉ាយ-ប៊ុក ក្រមការ ដើមខ្មែរប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទី ២៦

មានកាលមួយថ្ងៃ, ព្រះបាទភោជៈទ្រង់ស្ដេចចូលទៅជិតបល្ល័ង្កទិព្វ, រូបទេពនិម្មិតទីម្ភៃប្រាំមួយ ក៏ក្រាបបង្គំទូលថាៈ "បពិត្រព្រះបាទភោជៈ មានតែព្រះបាទវិក្រមាទិត្យមួយព្រះអង្គទេ ដែលមានគុណធម៌អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន, សូមចាំទ្រង់ព្រះសណ្ដាប់, ខ្ញុំព្រះអង្គនឹងក្រាបបង្គំទូលអំពីព្រះរាជគុណធម៌ នៃព្រះបាទវិក្រមាទិត្យ ដូចតទៅនេះ: ។

មានមួយថ្ងៃ, ព្រះបាទវិក្រមាទិត្យទ្រង់ស្ដេចយាងក្រសាលក្នុងព្រះរាជអាណាចក្រ ស្ដេចទៅដល់បូជនិយដ្ឋាននៃនាងទេវីតាមួយជាស្ថានដែលមានសភាពសប្បាយរីករាយខុសប្លែកពីទីដទៃ ដែលទ្រង់ធ្លាប់ឃើញ ។ ក្នុងពេលនោះ មានបុគ្គលម្នាក់មកកាន់ទីនោះ ។ ក្រោយដែលបានចូលទៅក្រាបបង្គំគាល់ព្រះមហាក្សត្រិយ៍ បុរសនោះក៏ពោលពាក្យហូរដូចទឹក ។ ព្រះមហាក្សត្រិយ៍ ទ្រង់ព្រះសណ្ដាប់នូវវាចាបុរសនោះ ទ្រង់ព្រះតម្រិះក្នុងព្រះរាជហឫទ័យថាៈ "បុគ្គលនេះប្រហែលជាកាចណាស់, បើមិនដូច្នោះទេម្ដេចក៏និយាយច្រើនម្ល៉េះ? តាមធម្មតាមនុស្ស

សប្បុរសមិនអាចពោលពាក្យច្រើនដូច្នេះឡើយ, បុគ្គលនេះពោលសុទ្ធតែពាក្យឥតប្រយោជន៍; បើដូច្នេះ មនុស្សនោះជាមនុស្សពាលសាមាន្យយ៉ាងក្រៃលែង, មិនដែលមានបុគ្គលណាមានវណ្ណៈល្អនិយាយស្រែកខ្លាំង ៗ ដូចជាសត្វស្វាកណ្ដុរឥតអាក់ទេ, ហើយវាចាបុរសនោះគ្មានខ្លឹមសារអ្វីសោះ, ដោយហេតុនេះហើយ គួរយល់ថាមនុស្សនោះគ្មានតម្លៃសោះ" ។ ព្រះមហាក្សត្រិយ៍លុះទ្រង់ព្រះតម្រិះដូច្នេះហើយ, ទ្រង់មិនមានព្រះរាជឧង្ការទៅកាន់បុរសនោះឡើយ ។ បុរសនោះឋិតនៅមួយស្របក់, ក៏ក្រាបបង្គំលាទ្រង់វិលទៅគេហដ្ឋានវិញ ។

ដល់ថ្ងៃស្អែក, បុគ្គលដដែលនោះស្លៀកពាក់ខោអាវកណ្ដាប មុខស្រងូតស្រងាត់ ចូលមកក្រាបបង្គំគាល់ព្រះបាទវិក្រមាទិត្យម្ដងទៀត ។ ព្រះអង្គទ្រង់ទតទៅយល់បុរសនោះហើយ ទ្រង់មានព្រះបន្ទូលសួរថា: "ប្អូនអ្នកនិយាយមកមើល, តើហេតុដូចម្ដេច ពីម្សិលមិញអ្នកអញ្ជើញមកកាន់ទីនេះស្លៀកខោពាក់អាវល្អ ឥឡូវនេះ ម្ដេចក៏អ្នកស្លៀកខោ ពាក់អាវកណ្ដាបដូច្នេះ?" ។ បុគ្គលនោះក្រាបបង្គំទូលថា: "បពិត្រព្រះមហារាជ, សូមទ្រង់ព្រះមេត្តាប្រោស; ទូលព្រះបង្គំជាអ្នកលេងល្បែងស៊ីសង ឥឡូវនេះទូលព្រះបង្គំខាតលិចលង់អស់ទ្រព្យសម្បត្តិរលីងគ្មានសល់, ទូលព្រះបង្គំនៅតែខោអាវកណ្ដាបប៉ុណ្ណេះឯង"។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់ទូលវាចាបុរសនោះហើយ ទ្រង់ព្រះសម្រួលហើយក៏មានព្រះបន្ទូលថា: "ល្អហើយ នេះឯងជាផ្លូវវិនាសនៃអ្នកលេងល្បែងស៊ីសង, ព្រោះបុគ្គលដែលស្វែងរកកោតទ្រព្យដោយល្បែងស៊ីសង, បុគ្គល

ដែលស្វែងរកកិត្តិយសដោយដាក់ខ្លួនឲ្យអ្នកដទៃប្រើប្រាស់តាមត្រូវការ, បុរសដែលស្វែងរកសេចក្ដីសប្បាយដោយធ្វើជាសូមយាចក, បុគ្គលទាំងអស់នោះជាមនុស្សពាលអាប់ឥតប្រាជ្ញ ត្រូវទទួលនូវសេចក្ដីវិនាសក្នុងអនាគតមិនខាន" ។ បុរសនោះកាលបានស្ដាប់នូវព្រះបន្ទូលរបស់សីហនាទនៃព្រះមហាក្សត្រិយ៍ ក៏ក្រាបបង្គំទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស, ការដែលទ្រង់រិះគន់ចំពោះទូលព្រះបង្គំជាការត្រូវហើយ, តែទ្រង់មិនដែលជួបប្រទះនូវសេចក្ដីសប្បាយម្ដងសោះ ក្នុងការលេងបៀក្លុក, ទ្រង់ដូចជាបុរសក្រៀវពោលពាក្យតិះដៀល ចំពោះបុគ្គលដែលត្រេកត្រអាលនឹងស្ត្រីក្មេងហើយស្អាត" ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលតបវិញថា: "ឱអ្នកលេងល្បែងស៊ីសង, អ្នកឯងកើតទុក្ខលំបាកពន់ប្រមាណដោយព្រះឥស្សរដាក់ទណ្ឌកម្មចំពោះអ្នក ព្រោះហេតុដូច្នេះ, បានជាយើងពោលពាក្យប្រស្រ័យពក់ទាក់ទៅរកអ្នក ដើម្បីនឹងជួយស្រោចស្រង់អ្នកពីហាយនភាព ដូចជាកល្យាណមិត្ត ។ អ្នកឯងក៏ទ្រទ្រាំជាខ្លាំងណាស់ គឺជាទុក្ខយ៉ាងក្រៃលែង ដោយខ្លួនមានរូបជាមនុស្សជាតិ ហើយគ្មានចិត្តល្អបន្តិចបន្តួចសោះឡើយ គ្មានវិចារណញ្ញាណដ៏បរិសុទ្ធ, គ្មានគិតស្វែងរកមធ្យោបាយដ៏សុចរិត, គ្មានព្យាយាមល្អ, គ្មានសកម្មភាព ប្រកបដោយសោកនវេទនាទេ ហើយគិតតែស្វែងរកសុភមង្គលដោយផ្លូវខុសគឺលេងល្បែងបៀក្លុក ដែលជាប្រភពនៃទុក្ខលំបាកគ្រប់យ៉ាង, មនុស្សប្រព្រឹត្តបែបនេះគឺបំផ្លាញជីវិតរបស់ខ្លួនទៅកាន់សេចក្ដីអន្តរាយពិតប្រាកដ" ។

អ្នកលេងល្បែងលុះបានស្តាប់នូវព្រះបន្ទូលព្រះមហាក្សត្រិយ៍ ក៏ក្រាបបង្គំទូលថា: "សូមទ្រង់ព្រះមេត្តាប្រោស, បើទ្រង់មានព្រះរាជបំណងចង់ជួយទូលព្រះបង្គំ សូមព្រះអង្គទ្រង់ប្តេជ្ញាថា ទ្រង់នឹងបំពេញសកម្មភាពអ្វីមួយដែលទូលព្រះបង្គំសូមឲ្យទ្រង់បំពេញ ហើយទូលព្រះបង្គំនឹងធ្វើកិច្ចសន្យាចំពោះទ្រង់ថា នឹងឈប់លេងល្បែងស៊ីសងតទៅ" ។ ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលតបថា: "បើតាំងពីថ្ងៃនេះតទៅ, អ្នកឯងលែងលេងល្បែងស៊ីសង យើងនឹងបំពេញសកម្មភាពជាយ៉ាងម៉ឺងម៉ាត់ ហើយយើងហ៊ានសន្យាថាយើងនឹងធ្វើតាមមិនឲ្យឃ្លៀងឃ្លាតឡើយ" ។

ដល់ព្រះមហាក្សត្រិយ៍ ទ្រង់បានធ្វើសេចក្តីថ្លែងការណ៍ដូច្នេះហើយ អ្នកលេងល្បែងស៊ីសងក៏ក្រាបបង្គំទូលថា: "បពិត្រព្រះសម្មតិទេព, សូមទ្រង់ព្រះសណ្តាប់ នៅលើកំពូលភ្នំសិនេរុ មានបូជនីយដ្ឋាននាងទេវធីតា នាមព្រះនាង មនស្សិទ្ធិ (Manassiddhi) ។ នៅខាងលើបូជនីយដ្ឋាននោះ មានដបកែវធ្វើដោយសុវណ្ណបវរណ ។ នៅក្នុងដបកែវនោះ គេដាក់ទឹកនៃគង្គាមហាមេឃ (ឬហៅថាទឹកអនោតត្តស្រះ) ។ អ្នកណាមួយអាចនឹងទៅយកទឹកដែលដាក់ក្នុងដបកែវនោះបាន, ធ្វើការគោរពចំពោះនាងទេវធីតា បានកាត់ក្បាលរបស់ខ្លួនបូជាយញ្ញ, អ្នកនោះនឹងបានសម្រេចនូវការទាំងឡាយពីនាងទេវធីតាសព្វគ្រប់ប្រការ ។ តែជាកិច្ចលំបាកនឹងធ្វើពន់ពេក, បើទ្រង់បំពេញព្រះរាជសកម្មភាពនេះបានគ្រប់សព្វ, ទូលព្រះបង្គំនឹងលះបង់នូវអំពើអបាយមុខនេះ ជាប្រាកដ" ។

ដល់អ្នកលេងល្បែងស៊ីសងនេះ បានក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ ។ ទ្រង់ព្រះសុពណ៌ណិបាទុកពិសិដ្ឋ ឡើងទៅលើកំពូលកំសិនេរុសំដែងគារវភាពចំពោះព្រះនាងមនស្សិទ្ធី, ហើយទ្រង់ព្រះខ័ននៅព្រះហស្ត, មានព្រះរាជបំណងចង់កាត់ព្រះសិរ ។ គ្រងពេលនោះ ព្រះនាងមនស្សិទ្ធី ក៏បង្ហាញរូបព្រះនាងឲ្យទ្រង់ទតឃើញហើយក្រាបបង្គំទូលថាសូមព្រះអង្គទទួលយកវត្ថុនេះ, បើទ្រង់មានព្រះរាជបំណងយ៉ាងណា ៗ ទ្រង់នឹងបានសម្រេចដោយសារវត្ថុនេះ'' ។ ព្រះអង្គទទួលវត្ថុនោះពីនាងទេវធីតាហើយ ទ្រង់ប្រទាននៅអ្នកលេងល្បែងស៊ីសង ។ ទ្រង់ក៏បានធ្វើឲ្យអ្នកលេងល្បែងស៊ីសងនោះ លះបង់អំពើអកុសលអស់ចេញហើយទ្រង់ក៏ត្រឡប់ចូលកាន់រាជធានីវិញ ។

រូបទេពនិម្មិតទី ២៦ ទូលបន្ទូលថា: '' ឱព្រះបាទភោជ: បើទ្រង់មានព្រះចរិយាបែបនេះ ទ្រង់អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន'' ។

គ្រងពេលនោះ ព្រះបាទភោជ:ទ្រង់មានព្រះទ័យរួញរា ហើយទ្រង់យាងចេញពីបល្ល័ង្កទិព្វនោះទៅ ។

*

* *

( មានត )

# រឿងកូនភ្លោះ

## របស់លោក ស. ប៉. ម. ស. អៀយ

ចុះផ្សាយក្នុងទស្សនាវដ្ដី សេលេចស្យុង ខែតុលា ១៩៥២

អ្នកស្រី ពេជ្រ-សល់ ហៅ សារិះយ៉ាង ជាអ្នកប្រែ

---

យើងទាំងអស់គ្នា តែងធ្លាប់បានឃើញ ទឹងបានឮគេនិយាយអំពីកូនភ្លោះជាញឹកញយណាស់ហើយ ប៉ុន្តែគ្មានអ្នកណាមួយនឹងអាចឆ្លើយនូវបញ្ហាកូនភ្លោះដែលផុសសាច់ជាប់គ្នាពីត្រឹមទ្រូងដល់ពោះ ដូចខាងក្រោមនេះបានទេ :

– តើកុមារភ្លោះទាំងពីរនាក់នេះ ជាមនុស្សមានវិចារណញ្ញាណដាច់ពីគ្នា ឬជាប់ទាក់ទងគ្នា ?

– បើសិនជាកុមារមួយបានប្រព្រឹត្តឃាតកម្ម តើកុមារមួយទៀតមានការទាក់ទងជាមួយដែរ ឬ យ៉ាងណា ?

– អ្នកទាំងពីរនាក់ទឹកឃ្លាននឹងងុយដេកព្រមគ្នា ឬ?

– មានសន្តានចិត្តយ៉ាងម្តេចរវាងគ្នានឹងគ្នា ?

– បណ្តាជនទាំងពីរនេះ អ្នកណាត្រូវស្លាប់មុន? ស្លាប់ព្រោះអ្វី?

– តាមដែលលោកអ្នកបានដឹង តើមានស្រីមេម៉ាយប៉ុន្មាននាក់ដែលយកប្តីភ្លោះនោះ?

– ជនភ្លោះដែលស្លាប់ទៅនោះ មានកូនប៉ុន្មាននាក់?

រឿងនេះឃើញថាពិបាកនឹងដោះស្រាយណាស់ ៗ បើដូច្នេះ យើង

សូមលើកយករឿងកូនភ្លោះ ឈ្មោះ ចាំង និង អេង មកពណ៌នាជូន អស់លោកអ្នកអានស្តាប់ ដើម្បីនឹងវិនិច្ឆ័យ ដូចតទៅនេះ ៖

ចាំងនិងអេងជាកូនភ្លោះជាប់គ្នាពីទ្រូងរហូតដល់ពោះ ក្រោយមក គេហៅថា ចាំង-អេង-ប៊ុនកែរ (ព្រោះមានស្រីម្នាក់ឈ្មោះ ប៊ុនកែរ នៅក្រុងញូវយ៉ក មានចិត្តសប្បុរសបានទទួលយកកូនភ្លោះនោះទៅចិញ្ចឹម) ។ កូនភ្លោះនេះ កើតពី គ. ស. ១៨១១ ក្នុងភូមិនៃអ្នកនេសាទមួយ ដែលនៅមិនឆ្ងាយប៉ុន្មានពីក្រុងបាងកក ក្នុងប្រទេសសៀម ។ ឪពុកជាចិន សុទ្ធ តែម្តាយជាចិនកាត់សៀម ។ ចាំងមានកំពស់ ១ ម,៥៥ អេង ១ ម,៥៧ ។ ចាំងបានកល់កែងស្បែកជើងឲ្យខ្ពស់បន្តិច ដើម្បីឲ្យបាន កំពស់ស្មើនឹងអេង ។

បុរសទាំងពីរនាក់នេះ រកស៊ីចិញ្ចឹមទា យកពងលក់ ។ អ្នកជិតខាងកោតសរសើរចំពោះការប៉ិនប្រសប់ក្នុងការរកស៊ីរបស់ជនទាំង ២ នាក់នេះណាស់ ។ ជនទាំងពីរនេះនិយាយការគួរមួយ តែងនិយាយទាំងអស់គ្នា គឺមួយចាប់ផ្តើមនិយាយ មួយទៀតជាអ្នកបញ្ចប់សេចក្តី ។

ថ្ងៃមួយ នៅពេលដែលបុរសទាំងពីរនាក់បានអាយុ ១៨ ឆ្នាំ, មាន នាយកប៉ាល់ជាតិអាមេរិកាំងម្នាក់ បានចូលទៅបោះយុថ្កានៅកំពង់ផែ ក្រុងបាងកក ហើយបានជួបនឹងបុរសភ្លោះ ក៏លួចចាប់បុរសភ្លោះនោះ យកដាក់កប៉ាល់នាំទៅបូស្តុន ក្រោយមកទៀតគាត់នាំទៅប្រទេសអឺរ៉ុប ។ ជនភ្លោះទាំង ២ នាក់នេះបានដើរតែក្នុងកោះប្រិតានិកមួយប៉ុណ្ណោះ អស់រយៈផ្លូវចម្ងាយ ៤០០ គីឡូម៉ែត្រ ។ ក្នុងការធ្វើដំណើរនៃជនភ្លោះនេះ

មានជនជាតិអង់គ្លេសប្រហែលជាង ៣០០.០០០ នាក់ បានមកចោម រោមមើលនូវបុរសក្លោះនោះ ៗ សមាជិកនៃបណ្ឌិតសភាខាងសិល្ប-សាស្ត្រ (ខាងវះកាត់) បានហៅបុរសក្លោះនេះទៅពិសោធជាមួយ ៗ សមាជិកទាំងឡាយនៃបណ្ឌិតសភា ក្រោយពីបានលួចសង្កេតពិនិត្យមើលបុរសក្លោះនោះហើយ ក៏បញ្ចេញយោបល់ថា ធម្មជាតិដែលបង្កើតឡើងយ៉ាងនេះ ជាការចំឡែកអស្ចារ្យណាស់ ៗ ដែលយល់ថា ជាការប្លែកពីធម្មតានោះមិនខុសទេ ព្រោះបុរសក្លោះនោះមិនមែនគ្រាន់តែកើតមកម្តងពីរប៉ុណ្ណោះ គឺថែមទាំងកើតមកជាប់គ្នាទៀត ប៉ុន្តែគួរឲ្យអស្ចារ្យពេកណាស់ ព្រោះបុរសក្លោះជាប់គ្នានេះ អាចរត់ ហែលទឹកនិងដើរបានចម្ងាយចំនួន ១៥ គ.ម. ក្នុងមួយថ្ងៃ; លេងវាយកូនឃ្លី ហើយជាអ្នកចូលចិត្តទៅបរបាញ់សត្វផង ៗ ប៉ុន្តែដើរបានតែទន្ទឹមគ្នា ៗ កាលបើដេក ដេកយកមុខទល់គ្នា បើប្រែខ្លួនទៅមួយចំហៀងទៀត ទាល់តែត្រឡប់មួយជុំខ្លួនទើបប្រែបាន ៗ ការប្រែខ្លួនបែបនេះ បានទៅជាទម្លាប់យ៉ាងស្ទាត់ ដោយឥតទាំងភ្ញាក់ពីដេកទៀតផង ដូចយើងខ្លួនមួយដែរ ៗ រូបបុរសក្លោះនោះមិនមានអ្វីប្លែកពីយើង ឃើញប្លែកតែត្រង់ដុះសាច់មួយបន្ទះប្រវែង ៩ សង់ទីម៉ែត្រ ទទឹងទំហំ ២០ ស-ម ភ្ជាប់គ្នាពីម្នាក់ទៅម្នាក់តាំងពីត្រឹមចុងដង្ហើមទៅដល់ពោះដូចគ្នា ៗ

ចំពោះខាងក្នុងនៃសាច់មួយបន្ទះដែលដុះភ្ជាប់នេះ អ្នកជំនាញការខាងវិជ្ជាពេទ្យក្នុងសាកលលោកចេះតែមានមតិខ្វែងគ្នា ឃើញយល់ស្របគ្នាតែត្រង់ថា កាលណាកាត់ផ្តាច់សាច់នេះ ដើម្បីឲ្យបុរសទាំងពីរ

នៅជាប់ដោយខ្លួនពីគ្នានោះ មុខជាមានក្លាត់ដល់បង់ជីវិតម្នាក់ ៗ ពុំខាន ព្រោះគេបានយកម្ជុល ១ ទៅចាក់ចំកណ្ដាលបន្ទះសាច់នេះ ដើម្បីពិសោធន៍មើល គេឃើញបុរសក្មេះញោចខ្លួនទាំងពីរនាក់ ប៉ុន្តែលុះយកម្ជុលទៅចុចដើមបន្ទះសាច់ខាងស្ដាំ ឬ ខាងឆ្វេងវិញ គេឃើញមានការញោចតែអ្នកនៅជិត ឯអ្នកនៅឆ្ងាយមិនញោចទេ ។ កាលនៅពីកុមារក្មេងនេះបានកើតកញ្ជ្រិលនឹងកើតអុតព្រម ១ គ្នា ។ ប៉ុន្តែលុះក្មេងនេះចាស់រៀងខ្លួន ទៅជាប្រែផ្ទុកគ្នាទៅវិញ គឺម្នាក់ផឹកស្រា ម្នាក់ទៀតផឹកទឹកតែ ហើយបើកាលណាម្នាក់ស្រវឹង, អំណាចសុរានោះ គ្មានឲ្យផលមកដល់បុរសម្នាក់ទៀតទេ ។

ក្រោយពីបានធ្វើដំណើរទៅប្រទេសអឺរ៉ុបលើកដំបូងមក ចាំងនឹងអេងក៏បានត្រឡប់ចូលមកប្រទេសអាមេរិកវិញ ដោយគ្មានបានអ៊ីក្រៅអំពីការពិសោធន៍ទេ ។ កាលនោះ កប៉ាល់ដែលបានពន្ង់តចាំងនឹងអេងមក ក៏កៀសគេចខ្លួនពោលចាំងនឹងអេង ។ ប៉ុន្តែជនក្មេះទាំង ២ នាក់នេះបានស្គាល់គេជាច្រើននាក់ហើយ ជាពិសេសបំផុត គឺបានស្គាល់បារនុមដែលជាមេរបាំមួយនាក់លេងនៅទីផ្សារ ឬ នៅទីប្រជុំជនផ្សេង ១ ។ ចាំងនឹងអេងបានទៅរកស៊ីជាមួយនឹងបារនុមនេះ អស់រយៈវេលា ៥ ឆ្នាំ ប្រមូលប្រាក់បាន ៦០.០០០ ដុល្លា ។

យើងគ្មានឹកស្មានថា នឹងមានស្ត្រីណាម្នាក់មានចិត្តស្នេហាចំពោះរូបចាំងនឹងអេងនេះទេ ទាំងបុរសក្មេះសោតក៏យល់ដូច្នេះដែរ ប៉ុន្តែគួរឲ្យអស្ចារ្យណាស់ ស្រាប់តែមានស្រីក្រមុំម្នាក់ឈ្មោះ សូហ្វីយ៉ា ដែលជា

កូនអ្នកមានពូជអម្បូរម្នាក់នៅក្រុងឡុងដ្រ៍ បានជួបជនក្មោះនោះក៏កើតសេចក្តីស្នេហាយ៉ាងខ្លាំង ។ ចាំងនឹងអេងក៏ទៅជាស្រឡាំងកាំងទាំងពីរនាក់ ដោយពុំបានស្មានទុកជាមុនថា នឹងកើតមានការណ៍ដូច្នេះសោះ ។ ប៉ុន្តែគួរឲ្យអាសូរនាងកញ្ញាណាស់ ពុំយូរប៉ុន្មាន សេចក្តីស្នេហារបស់នាងបានជួបប្រទះនូវឧបសគ្គមួយធំដែលចៀសពុំផុត ព្រោះអ្នកជំនាញការខាងវិជ្ជាពេទ្យធំ ៗ នៅប្រទេសប្រុតានិកបានប្រាប់នាងថា ចាំងនឹងអេងនេះជាមនុស្សពីរនាក់ មិនមែនជាមនុស្សតែម្នាក់ហើយមានរូបពីរដូចជានាងស្មាននោះទេ ។ នាងឮដូច្នេះ ក៏ស្រងាកចិត្តដោយនឹកខ្លាចក្រែងមានរឿងព្រោះតែយកប្តីពីរ ដ្បិតថាតែកាលណារៀបការនៅជាមួយគ្នាទៅ មុខជានឹងទៅជាស្ត្រីមានប្តីពីរ ។

ដើម្បីនឹងសម្រាលទុក្ខ នាងក៏ទៅពឹងកវីនិពន្ធម្នាក់ឲ្យជួយតែងសេចក្តីជាសស្ការតីនាងជាពាក្យកាព្យឃ្លោង ដើម្បីបំភ្លេចចោលនូវសេចក្តីស្នេហារបស់នាង ។ កវីបណ្ឌិតនោះក៏បានទទួលព្រម លុះតែងរួចហើយក៏ប្រគល់ឲ្យមកនាង ។ ឯពាក្យកាព្យនោះ មានសេចក្តីប្រហែលគ្នានឹងកាព្យខាងក្រោមនេះ:

ធម្មតានារីមានភស្តា ពីរប្រាណទុក្ខាជាអនេក
ព្រោះកាលបើចូលរួមដំណេក នឹងប្តីដែលត្រេកក្នុងកាមស្នេគ្រ ៗ
ប្តីមួយរំជួលក្តៅក្តួលឆេះ ក្នុងទ្រូងស្មើរព្រះដោយអន់អាក់
ម្នោះហើយរករឿងវាយប្រំធាក់ នារីដល់ថ្នាក់ក្រំដាំឈាម ៗ

មួយទៀតបើបរើប្ដីមួយ    ប្ដីមួយប្រណែនប្រច័ណ្ឌភាម
ធ្វើឱ្យនាងមានទុក្ខរហាម    ឱអនិច្ចាកាមនារីអើយ! ។

កញ្ញាសុហ៊្វីយ៉ា កាលអានកំណាព្យនេះអស់វេលាជាច្រើនថ្ងៃទៅ ក៏បានបំភ្លេចក្នុងចិត្ត នូវសេចក្ដីប្រតិព័ទ្ធចំពោះបុរសភ្លោះនោះបាន ។

រឿងកូនភ្លោះដែលពោលមកខាងលើនេះ ជាបញ្ហាមួយដែលធ្វើឱ្យអ្នកប្រតិបត្តិច្បាប់តុលាការជាតិអាមេរិកាំង ខ្វល់ខ្វាយក្បាលជាក្រៃលែង ព្រោះមនុស្សភ្លោះនេះ តាមមតិពេទ្យថា ជាមនុស្សតែនាក់ពិត ប៉ុន្តែ តើអ្នកទាំងពីរនេះ មានអ្វីជាសំគាល់ថាជាមនុស្សផ្សេងពីគ្នា? បើអ្នកទាំងពីរធ្វើអ្វី ៗ ក៏ធ្វើជាមួយគ្នាជាដរាបរៀងមកតាំងតែពីតូចដល់ធំ ។ នៅទីបំផុត គេបានផ្សាយយ៉ាងពិតប្រាកដថា កូនភ្លោះនេះមានអំណាចនឹងចុះហត្ថលេខាលើកិច្ចសន្យា ឬលើសារលិខិតកម្មសិទ្ធិ ដោយពេញច្បាប់ ដាច់ដោយខ្លួនម្នាក់ ៗ ក៏បាន ជាមួយគ្នាដូចធ្វើជាសមាជិកក្រុមហ៊ុនក៏បាន ឬមួយម្នាក់ចុះហត្ថលេខាជំនួសម្នាក់ក៏បាន ប៉ុន្តែចំណែកធ្វើអាពាហ៍ពិពាហ៍វិញ ត្រូវដាច់ដោយឡែកពីគ្នា ហើយកូនរបស់ជនភ្លោះម្នាក់ៗ ក៏ត្រូវបានទទួលកេរ្តិ៍មត៌កដាច់ចំណែកពីគ្នាដែរ ។

ប៉ុន្តែ ចុះបើបណ្ដាជនភ្លោះទាំងពីរនេះ ជនម្នាក់បានប្រព្រឹត្តអំពើឃាតកម្ម តើម្នាក់ទៀតត្រូវចោទថាជាអ្នកសមគំនិតគ្នាដែរឬយ៉ាងណា? ចុះបើម្នាក់គ្មានធ្វើអំពើអាក្រក់ទេ តែម្នាក់ធ្វើ តើយកជនម្នាក់ដែលធ្វើនោះទៅដាក់គុកយ៉ាងដូចម្ដេច ដោយកុំឱ្យអ្នកគ្មានទោសទៅរងទុក្ខជា

មួយផង? អ្នកទាំងពីរនេះ ប្តីប្តូរគ្នាមិនបានទេ ព្រោះធ្វើអ្វីក៏ធ្វើជាមួយគ្នា គឺគោកៗទាំងពីរ ឃ្លានៗទាំងពីរ បរិភោគអាហារចំនួនប៉ុនគ្នា; បើម្នាក់ជក់បារី បរិភោគស្លា មួយទៀតក៏ធ្វើតាមគ្នាដែរ ។ មានមនុស្សជាច្រើននាក់បាននាំមនុស្សភ្លោះនោះ ឲ្យនិយាយអំពីរឿងផ្សេងៗគ្នាលមើល ប៉ុន្តែគ្មានអ្នកណាមួយធ្វើបានសោះ ព្រោះបុរសភ្លោះនោះ ទោះមានមតិប្លែកគ្នាយ៉ាងណាក៏ដោយ ក៏អ្នកទាំងពីរមិនអាចនិយាយរឿងពីរ ក្នុងពេលមួយជាមួយគ្នាឡើយ គឺអ្នកមួយនិយាយរឿងអ្វី អ្នកមួយបង្ហើយសេចក្តីនៃរឿងនោះ ។

គួរឲ្យអស្ចារ្យណាស់ ចាំងទីងអេងមិនសូវឃើញនិយាយគ្នាទេ ហើយក៏បានប្រាប់គេថា "ចាំបាច់និយាយប្រាប់គ្នាធ្វើអ្វី បើយើងយល់ដូចគ្នាទៅហើយ" ។ ហេតុដូច្នេះបានជាចាំងទីងអេង មិនដែលលេងល្បែងអ្វីដែលជាល្បែងដេញប្រជាគ្នាជាមួយគ្នាដូចជាល្បែងចត្រង្គជាដើមទេ ។ ក៏លេងល្បែងប៊ូកែណាស់ ប៉ុន្តែការដែលដឹងគំនិតគ្នាទៅវិញទៅមកហើយ ជាហេតុឲ្យអស់សប្បាយ ដូចយើងប្រើដៃស្តាំឲ្យលេងគ្នាល់ជាមួយនឹងដៃឆ្វេងដូច្នោះឯង ។ តែចំណែកខាងផ្លូវនយោបាយ បុរសភ្លោះមានយោបល់ប្លែកគ្នាទៅវិញ ព្រោះក្នុងឱកាសបោះឆ្នោត សមាជអាមេរិកាំង ក្នុង គ.ស. ១៨៤៧ បុរសភ្លោះ មិនយល់ស្របតាមគ្នាទេ បានបោះឆ្នោតឲ្យបេក្ខជនផ្សេងគ្នា ។

បុរសភ្លោះទាំងពីរនេះចេះនិយាយ ចេះសរសេរនឹងចេះមើលភាសាអង់គ្លេសបានសមគួរ មានសំលៀកបំពាក់តាមរបៀបអាមេរិកាំង ប៉ុន្តែ

ទុកសក់តាមរបៀបចិនបូរាណ គឺទុកសក់វែងប្រហែលមួយម៉ែត្រក្រងព័ទ្ធជុំវិញក្បាល ។ ចាំងនិងអេងជាមេកាស៊ីយ៉ាងស្ដុកស្ដម្ភ ។

ក្រោយមកទៀត មានស្រីក្រមុំពីរនាក់ជាបងប្អូននឹងគ្នា មានចិត្តប្រតិព័ទ្ធចំពោះរូបចាំងនិងអេង ។ ជនខ្លះដែលចាំតែរិះគន់ គេក៏នាំគ្នានិយាយថា ស្រីពីរនាក់នោះស្រឡាញ់ចាំងនិងអេង ព្រោះតែឃើញចាំងនិងអេងមានប្រាក់ ៦០.០០០ ដុល្លា ។ នៅថ្ងៃ១ មេសា ឆ្នាំ ១៨៤៣ ចាំងបានរៀបការជាមួយនឹងនាងអាដឺឡាអ៊ីជ-យៀត្ស, អេងរៀបការជាមួយនឹងនាង សារ៉ា-អាន នៅវិលគីស គូទី កូនស្រកការូលីន ប៉ែកខាងជើង ។ អ្នកផងនឹកថាមុខជាបានសុខនឹងគ្នាហើយ ព្រោះជនទាំងពីរគូសុទ្ធតែជាបងប្អូននឹងគ្នា ប៉ុន្តែមិនបានយូរប៉ុន្មានទៅជាកើតរឿងរ៉ាវទាស់ទែងខ្វែងគំនិតគ្នា ។ បងប្អូនស្រីទាំងពីរនាក់បេះតែអារចិត្តនឹងគ្នា ។ នៅទីបំផុត ចាំងនិងអេងក៏ព្រមព្រៀងគ្នាឲ្យសង់ផ្ទះពីរ ឆ្ងាយពីគ្នាចម្ងាយ ៩ គ. ម. សម្រាប់ឲ្យប្រពន្ធខ្លួននៅរៀងខ្លួន ហើយបុរសភ្លោះទាំងពីរទៅនៅជាមួយ ៣ ថ្ងៃម្នាក់ៗ ។

ក្នុងរវាង ៣០ ឆ្នាំដែលជនភ្លោះទាំងពីរនៅរួមរក្សជាមួយនឹងប្រពន្ធរៀងខ្លួន ទាំង ២ នាក់មានកូន ២២ នាក់ ហើយសុទ្ធតែមានប្រាជ្ញាឈ្លាសវៃ, គឺអេង មានកូនប្រុស ៧ កូនស្រី ៥ កូនទាំង ១២ នេះគ្មានវិកលវិការៈអ្វីទេ គឺដូចគេដូចឯងទាំងអស់ ។ ចាំងមានកូនស្រី ៧ មានកូនប្រុស ៣ ប៉ុន្តែបណ្ដាកូនទាំង ១០ នេះ មានកូនប្រុសមួយ ស្រីមួយ គថ្លង់ ។

ក្នុងពេលនោះ មានកើតចម្បាំងគ្នាឯងក្នុងសហរដ្ឋអាមេរិកខាងត្បូង ។

ចាំងនិងអេងជាពួកខាងត្បូង, លុះពួកខាងត្បូងច្បាំងចាញ់គេ ចាំងនិងអេង ក៏ត្រូវទទួលសេចក្ដីអន្តរាយជាមួយនឹងគេដែរ ហើយក៏ធ្លាក់ខ្លួនទៅជាក្រវិញ ៗ បុរសក្មេះមានសេចក្ដីវេទនាពេក ក៏បាននាំគ្នាទៅនៅក្រុងញូវយ៉ក ដើម្បីនឹងសន្សំប្រាក់កាស ដោយលេងរបាំទៀត ប៉ុន្តែជាវាសនាអាក្រក់ ដោយអ្នកស្រុកមិនអើពើនឹងមើលរបាំបុរសក្មេះទៀតឡើយ ៗ ជនក្មេះលុះឃើញពុំបានផល ក៏ត្រឡប់មកកាន់កន្លែងកាស៊ីដើមវិញ ហើយទៅមកចុះឡើងនឹងផ្ទះប្រពន្ធដូចពីមុន គឺ ៣ ថ្ងៃផ្ទះប្រពន្ធចាំង, ៣ ថ្ងៃផ្ទះប្រពន្ធអេង ៗ

តាមសេចក្ដីកត់ហេតុក្នុងសម័យនោះថា ចាំងនិងអេង បានជិះសេះដើរលេង ទទួលត្រូវក្ដៀងទទឹករងាពេក ហើយក៏ស្លាប់ទាំងពីរនាក់ទៅ ៗ មានអ្នកខ្លះទៀតនិយាយថា មកពីចាំងផឹកស្រាច្រើនពេក ៗ តែតាមសេចក្ដីពិតវិញថា ក្នុងឆ្នាំដែលចាំងនិងអេងបានអាយុ ៦៣ ឆ្នាំ គឺពីថ្ងៃសុក្រ ២៣ មករា គ. ស. ១៨៧៤ វេលាយប់ ចាំងនិងអេង នាំគ្នាចូលទៅដេកទាំងពីរនាក់ ៗ ហួសពេលអាធ្រាត្របន្តិច បុរសក្មេះទាំងពីរនាក់ក៏ក្រោកមកអង្គុយនៅលើកៅអីមួយនៅក្បែរភ្លើងដែលគេធ្វើសម្រាប់គាត់ ៗ អេងងងុយណាស់ ចង់ទៅដេកវិញ ប៉ុន្តែចាំងបេះតែត្អូញថាដេកមិនបានព្រោះតឹងទ្រូងណាស់ ៗ បុរសក្មេះជជែកគ្នា ពីរឿងដេកឬមិនដេក អេងជក់ខ្សៀរបណ្ដើរ ៗ ក្រោយបន្តិចមក អេងលត់ភ្លើងបារីហើយ ក៏ចូលទៅដេកទាំងពីរនាក់លក់ស្កប់ស្កល់ទៅ ៗ

គួរឲ្យព្រឺខ្លួនណាស់ លុះភ្លឺឡើងអេងក្រោកហើយឃើញចាំងប្លែកធម្មតា ក៏សួរទៅកូនខ្លួនថា "ម៉េចទៅឪពុកធំឯង កូន?" ។

កូនឆ្លើយថា: ត្រជាក់ខ្លួនស្រេង ប្រហែលគាត់ស្លាប់ហើយ ។ គ្រាន់តែឮពាក្យកូន អេងចេះតែយំ ហើយចេះតែបញ្ចេញអាការអន្ទះអន្ទែង ហើយហៅប្រពន្ធមកប្រាប់ថា "ការរស់នៅរបស់បងអស់ត្រឹមនេះហើយ" ថាតែប៉ុណ្ណេះគាត់ក៏ងាកមុខទៅរកបងដែលស្លាប់ដេកនៅស្ដូកស្ដឹងដោយមានសេចក្ដីតក់ស្លុតជាខ្លាំង ហើយស្រាប់តែធ្លាក់ព្រឹតៗ ដួលគេកន្ទ្រាក់ ។ ពីរម៉ោងក្រោយមក អេងក៏ស្លាប់ដែរ ដោយពីល្ងាច គ្មានឈឺអ្វីសោះ ។

សភាខាងវិជ្ជាពេទ្យបានបើកប្រជុំពិសេសមួយនៅហ្វីឡាដេលហ្វី ។ ការប្រជុំនេះ បានសម្រេចសេចក្ដីថា បើសិនជាកាត់មនុស្សភ្លោះដែលស្លាប់ឲ្យដាច់ចេញស្រឡះ អំពីមនុស្សភ្លោះដែលរស់ក៏នៅតែមិនបាន ។ ម្យ៉ាងទៀតថា ចាំងស្លាប់ដោយដាច់សរសៃក្បាល, ឯអេងដែលស្លាប់តាមគ្នាទៅដែរនោះ គេរកហេតុពុំឃើញសោះ ហើយគេក៏បានអនុម័តថា អេងស្លាប់ព្រោះខ្លាចពេក ។

# រឿងសៅរ៍សោយ

(សិរិសោរជាតក)

## ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ ប៊ុង-ប៉ម

## អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្រាយសាស្ត្រាស្លឹករឹត

(តចប់)

---

(១)(ពណ៌នាសរសើរព្រឹក្សព្រៃ-ហាត់ហានទោះនៃ បពិត្រលថ្មា ។
មឈ្លូតល្ហុតសេដា ដូរេនដូងស្វា មាក់ប្រាងអង្កាល់ ។
ត្រឡែតមាក់ដោកសង្ស័រ ខ្នោតផ្អាវក្រូចឆ្មារ ពោធិ៍សត្វសំសា ។
ក្រូចសើចចងសក់ផ្ដីកា មាក់ប្តូងទ្រទំអា- អូតទូរធ្មេញត្រី ។
គូលែនលែនតែនស្រឡី ឈាដផ្ទុះឫស្សី សាញប្រមាញនៃ ។
ស្រឡៅអំពែណាំងជ័យ អំបែងថ្ងៃនៃ ដកពរក្សាសផង ។
លោតលៀបថ្កូនទូរមេកង ប៉ប្រែកសំពេង ទូរសក់សីតា (២) ។
ទទឹមត្របែកហខា ស្វាយទូរដៃខ្លា ដើងចាបខ្ទុងហារ ។
កុមារពេជ្រជត្ថុះត្រកាល សោមអាគ្នេយ៍ឈ្វាល សាគុណគណនា ។
បញ្ចកក្ងាំពាក់ក្រឹស្នា ដើមចន្ទនា គគីរក្រូចព្រៃ ។
ពពេលផ្ទឹកស្បូក្រំនៃ កំណ្ណុំលូតលៃ ចំបក់ធ្លកផង ។
ស្រគំព្រីងព្រូសដើមដង ត្រាចខ្ទុងកកោះផង រលួសគរនៃ ។

---

១ តាំងពីវង់ក្រចកនេះទៅដល់វង់ក្រចកខាងចុង ខ្ញុំទុកតាមបែបគម្រាដើមទាំងអស់ ពុំមានកែប្រែឡើយ កែចំពោះតែអក្ខរាវិរុទ្ធៈបុណ្ណោះ ។ ២ អានថា សេដា ។

រំដួលផ្កុលស្រឡៅក្រៃ  ស្រមូវដេទៀនព្រៃ  ធ្វេញត្រីស្តៅខ្ចីន ។
ដើមដៃពោធិ៍បាយទ្រយឹង  ក្រខុបឪដើង  ប៉ប្រើសកន្ទ្រង ។
ត្រឡែកត្រឡាត់ក្ដុង  ខ្នុរបេងស្ដីផង  រលាយពោនម្កាក់ ។
គុយស្វាយទុំខ្ចីសឹងធ្លាក់  ពលផងសំណាក់  រើសស៊ីសប្បាយ ។
ទ្រមែងសីរ(១) មានផ្ទកពាយ  ទ្រមូងក្របក្រាយ  កន្ទុតស្វរកី ។
បន្តោតទន់តាវមូលី  មាក់ប៉ែនអន្តាដី  អម្ពិលពន្រែ ។
ធ្នាល់មានត្រពោសង្ស័រ  ពេគក្រហមស  ជ្រួយល្វាដៃខ្លា ។
កណ្ដាប់ចន្ទេរទ្រលស្វា  ព័ន្ធដើមរកា  ទ្ររស្វែងស្វាចផង ។
សាច់តាវព័ន្ធដើមផ្អែងហោង  ទំពាំងបាយជូរផង  ព័ន្ធដើមបុស្ស ។
វល្លិប្រែងព័ន្ធដើមល្វា  ទាំងដើមពញា  ភរព័ន្ធត្រសុំ ។
វល្លិយាវព័ន្ធដើមឪជុំ  វល្លិខ្ចូតព័ន្ធរុំ  ឈើគ្រលពាំងផ្ទង ។
ទន្ទាប់កៀរទ្រូវប្រក្រុង  តាត្រាវតៀងខ្ចុង  វល្លិប្រាក់ព័ន្ធពៅ ។
គ្រញូងញាខ្លាវថ្កុវខ្មៅ  វល្លិវើកឈើខ្ពៅ  វល្លិភយម្រោមធ្នារ ។
ដើមម្រេចពងខ្ចីទិគចារុំ  ព្រិចឃ្មាយក្រាសក្រាល  រលៀកដែកផង ។
កណ្ដាលផ្ទង់ល្វៀងហោង  ព្រះកំបាត់ផង  ព្រះទេហឹងផងណា ។
កែវកោតជយ័ជោតកញ្ញា  ចិត្រប៉ុស្សហោក  ក្រភញដីថ្ម ។
សម្បុរវល្លិងឈើអែមទ្រូវខ្ញី  យាគាមពារទី  ម្ទាងសិលា ។
កញ្ជានធ្លាមព័ឃ្មាយណា  យាហ៊ូនសោមផា  មហាហង្សគប្ប៊ូរ ។
អង្រែដែកពេជ្រដែកក្ដមាន  ទំលាយវត្តបាន  ត្បាល់ដែកសែនវែង ។

---

១ អានថា សេមន់ ។

ជ្រៃសោមដំបងផ្កាក្រៃ　ដង្កោកំងនៃ　អិនទ្រនេលណា ៗ
ដំឡូងក្ដាតក្ដួចប្រស់ស្វា　រំដេងដីសណា　ប្រទាលពន្ទៃ ៗ
ត្រចុកត្រចៀងខ្ញៃស្ត　ដីរខ្លាយស្លឹកគ្រៃ　ប្រស់រមៀតផង ៗ
កាកោកន្ទ្រាបន្ទុបហោង　ចិត្រមូលក្ជីងផង　ព្រះក្រាបសំកុង ៗ
បណ្ដូលពេជ្រន្ទូវបំពង់　ស្រមោចអន្ទង់　បំពង់កាំផង ៗ
ប្រកុងកន្ទួចអាលហោង　ក្អែកព្រាបព្រំផង　កញ្ឆើបាយដាច ៗ
វល្លិមាសតន្ទពាសដើមត្រាច　វល្លិប្រាក់សស្វាច　ឥតបើគណនា ៗ
ប្រដេញមាញទន្ទា　កប្បាសមគ្រែ　ម្រេចទន្សាយផង ៗ
ពក់ប្បាចម្ប៉ារំពេកហោង　ចំប៉ីក្ដាំងងាផង　បាយម៉ាតគាមទ្រាន់ ៗ
កាកែសបេកទេសត្រយុង　បុសនាគស្គុះស្គន់　ត្រកួនទួនស្រី ៗ
លណ្ដែមហាហង្សមាលដី　ស្រឡិតស្រឡី　ម្ទិះរួតលាហោង ៗ
ត្រាវត្រែងបែងម៉ែងប្រឹងផង　ក្រកញ្ច្រូកហោង　ប៉ប្រកលំពែងព្រះរាម ៗ
ស្បូវក្ដាំងត្រៀលទ្រាំងសំរង　ត្រប់នាឡិពុតលំញង　ត្រប់ខ្ទរកណ្ដាល
ចាត ៗ

ក្រមួចសង្ឃប្ចាំងក្រចាត់　កញ្ជ្រោកក្ដិចាត　លីងលាក់ម្រះព្រៅ ៗ
ព្រះឬដង្កោកំងឡូវ　លំពាន់ផ្ដៀកផ្ដៅ　កំពីងពួយហោង ៗ
ក្រសាំងទំហំខ្ទឹមផង　មេផាពាន់ហោង　រីកពេយក្រាសក្រៃ ៗ
អំពៅក្ដាមអំពៅព្រៃ　អំពៅខ្មៅនៃ　អំពៅបុសនាគ ៗ
អំពៅត្រែងគាមមហិមា)[១]　អស់ពលយោធា　រមនារីកពយ ៗ

---

១ តាំងពីវង់ក្រចកខាងដើមរហូតមកដល់ត្រង់ណេះ ខ្ញុំទុកតាមបែបចាស់ទាំងអស់ ។

រើសរើផ្លែឈើកយមាយ ខ្លះឃ្លុំខ្លះស្អាយ វែកកយគ្រប់គ្នា ។
ខ្លះណោនឡើងគោនម្នមា បេះឯផ្លែក - ពល់គ្នាទីទៃ ។
កញ្ច្រៀវខ្វារខ្វៀវក្រៀវក្រ ញាប់ញ័រខ្ញុំរព្រ រនៅត្រសប្បាយ ។
ម្រឹគានានាទាំងឡាយ ផ្អើលរត់ខ្វាត់ខ្វាយ ប្រកាយបពួគា ។
ក្បត្រក្បាន្ទក៏បានយាត្រា ទុកអស់ព្រឹក្សា បិន្ទាមនៅរម្យ ។
ទីទំបែនសំដែនថ្លែងអំ - ពីសត្វតូចធំ ខ្លះទំដោយដី ។
ទានទុកអស់សត្វបក្សី ហើរព្រាតឃ្លាតខ្ញី ផ្ទឹមផ្ទូរតូក ។
មានព្រមសោកសោមរេក ហើរចូលមូលគ្នា ជាប់ជាគូខ្ញី ។
បេកខ្ទុំបុះទំប៉ុ ចឹកពាំចំណី បែកកូនជូនទៅ ។
ទុកទ្រទំនាគាត្រៅ ស្រែកយំក្រង៉ ពានព្រឹព្រួច ។
ករវិកទំកឹកទ្រមួច ស្រែកយំគ្រលួច គួរកួចស្រណោះ ។
កេងកងទំត្រង់កកោះ ទំសោតលោតផ្លោះ ធ្ងន់ធ្ងៅទៅមក ។
ទទាទំនាដើមធ្លក មើលមកលលក រឆារឆ្មើយគ្នា ។
ពញាក់ក្រាបពាក់ពញា មានទាំងក្តាំងឆា ផ្កាក់ច្រើនក្រៃ ។
ពួកពលចេលគ្រប់ដៃ ខ្លះបេះដកម៉ៃ ថែថើបសប្បាយ ។
មានទាំងលាំងសាតស្វាតស្វាយ ពលក៏ប្រញាយ ប្រកាយជាទ់គ្នា ។
ខ្លះបេះប្រឡេះទន្សា មង្ឃុតពុទ្រា ជាន់គ្នាវកវី ។
ស្រីខ្លះប្រទះសូរគី នាំគ្នាមាម្ចី ឡើងបេះរញ៉ី ។
ស្រីខ្លះឡើងបេះនួនស្រី ខ្លះណោងពីដី រំលែកចែកគ្នា ។
ឈើព្រៃច្រើនក្រែមហិមា មិនដឹងនឹងជា គណនារាប់បាន ។

កូមីពោធី(១)សត្វសាន្ត　បីខែទើបបាន　ដល់ស្ថានបុរី ។
ថ្ងៃងពីទេវីពិសី　អនន្តតន់ស្រី　ឥតបីសុខា ។
នាងនៅមើលផ្លូវកស្តា　យូរខែហើយណា　ឧរាឥតស្បើយ ។
ជ្រាបថាកស្តាមកហើយ　ពុំអង់វង់ឡើយ　ត្រាណត្រើយឃ្លាតខ្លី ។
ទៅទទួលវរស្វាមី　នាងឧនសិរសី　ឧបបាទក្សត្រក្សាន្ត ។
កន្លែងនៃត្រលែងប្រមាណ　កណ្តាបខ្ចាបប្រាណ　កល្យាណទូលថា ៖
"បពិត្រទ្រង់ពុទ្ធិបេស្តា　ខ្ញុំម្ចាស់នេះណា　ជីវ៉ស្ទើរក្ស័យ ។
កាលទ្រង់ឃ្លាតបង់រាំងជ័យ　ខ្ញុំម្ចាស់នេះនៃ　សង្រៃក្រៃលន់ ។
សោយសោកអមោក្ខពេកពន់　ឧរាទុរន់　លើសលន់ប្រមាណ ។
ទើបបាត់អមាត្យគ្រប់ប្រាណ　ឲ្យរកក្សត្រក្សាន្ត　គ្រប់ឋានគ្មានសល់ ។
ជ្រៀតជ្រកការរករបល់　តែគ្មានបានយល់　ទសពលសោះឡើយ ។
នឹកថាក្សត្រាត្រាណត្រើយ　ប្រល័យក្ស័យហើយ　ព្រោះបាត់ស្ងាត់ឈឹង ។
ខ្ញុំម្ចាស់ព្រាត់ប្រាសទីពឹង　សោកយំពុំដឹង　ពំនឹងអ្នកណា ។
នេះហេតុតែកេទផលា　គុណបុណ្យជតា　រសនាប្អូនស្រី ។
ទើបបានចួបប្កានចក្រ　បមគពនវេតី　ដូចក្តីបំណង ។
បពិត្រទ្រង់ពុទ្ធិប្បាស់ប្បង　សូមទ្រង់គង់ត្រង់　រាស្ត្រផងគ្រប់កាយ ។
សូមបានសុខសាន្តសប្បាយ　ព្រះជន្មវែងឆ្ងាយ　ហ្មឺនឆ្នាំវស្សា ។
កុំបីមានក្តីទុក្ខា　បៀតបៀនចិន្តា　កាយាឡើយហោង" ។
សិរសៅស្រាស់ទៅវិញផ្គង　តាប់ផ្តើមដើមទង　ទំនងសេចក្តី ។

១ ពាក្យត្រូវគឺ ពោធិ, តែដែលដាក់ជាពោធីដូច្នេះ ដើម្បីតម្រូវទៅតាមសម្ពស្សពាក្យ ។

តាំងពីស្ដេចលីលាខ្មី  ចាកពជបុរី  ចាកស្រីកនិដ្ឋា ។
គោកយ៉ាកលំបាកខ្លាំងខ្លា  ជរាបលុះគ្រា  ចក្រាប្អូបប្អូន ។
ទឹងវត្ត័ន៍សុទត្តមាសស្ងួន  ហើយបាននឹមទួន  ជាស្ងួនគូគ្រង ។
មានបុត្រវិសុទ្ធទងវង  ហើយបានគ្រប់គ្រង  អចលរដ្ឋា ។
ទ្រង់បានព្រះខាន់ពេជ្រថ្លា  មកុដសោភណា  ទីងអាជានេយ្យ ។
ដែលស្ដេចកាលគ្រាប់ក្នុងព្រៃ  ត្រូវមនុស្សទីទៃ  ចោមវៃយកទៅ ។
ក៏បានវិញថ្កានគ្មាននៅ  ស្ដេចប្រាប់ស្រីពៅ  ឥតនៅសល់ឡើយ ។
ស្រេចថ្កានក្សត្រក្សាន្ត្រគ្រានត្រើយ  ត្រាស់ថា "ប្អូនណើយ  ចូរនាងប្រណិ
សុទត្តវរ័តន៍ក្សត្រី  មានគុណឥតបី  ទីងស្ដ័ឧបមា ។
បងបានរស់ពនជីវ៉ា  ព្រោះតែជីតា  មេត្តារូបបង ។
ចូរស្រីកុំបីមានហ្មង  រាប់អានគ្នាផង  ដូចញាតិជំស្និទ្ធ" ។
ត្រាស់ស្រេចសម្ដេចទ្រង់ឫទ្ធិ  ទ្រង់ប្រាប់ព្រាហ្មណ៍ព្រឹទ្ធ  បណ្ឌិតហោរា ។
មន្ត្រីសេនីយសេនា  ឲ្យរៀបសីមា  មហាបុរី ។
អភិសេកសម្ដេចចក្រី  ទីងពីរក្សត្រី  ជាថ្មីទៀតហោង ។
តាំងកន់អនន្តទងវង  ខាងស្ដាំជាម្ដង,  ឯល្អងពិសី ។
សុទត្តវរ័តន៍ក្សត្រី  កូធរចក្រី  តាំងខ្មីខាងឆ្វេង ។
មហោរីម្នាម្នីពាទ្ទង  ទ្វគ្រប់សព្ទភ្លេង  ត្រឹកត្រេងពេកក្រៃ ។
ពិធីចាប់ពីនោះនៃ  លុះប្រាំពីរថ្ងៃ  ទើបចប់សព្វគ្រប់ ។
មហាជនលើសលន់គ្មានឈប់  ដឹងជាចមកព  ត្រឡប់បុរី ។
ត្រេកអរសោទរឥតបី  នាំគ្នាឃ្មាតខ្មី  រញ៉ីសព្វទី ។

រៀបគ្រឿងធំឡើងផ្កាភ្ញី   បូជាភូមី   ជាទីស្នេហា ។
ថ្វាយតាមបវរថ្ងៃថ្វា   ឲ្យមានជន្នសា (១) ហ៊ឹនឆ្នាំជាម្ដង ។
ថ្ងៃពីពោធិ៍ច្បាស់ច្បង ឧក្ការសាសង ប្រឹងសេនា ។
ឲ្យសង់សំណាង់សាលា   ប្រាំមួយសោភណា ជាទីឲ្យទាន ។
ទ្រង់ចាយចំណាយធនធាន   ធ្វើបុណ្យស៊ីនូវទាន ពុំមានដាច់ឡើយ ។
ពួកស្មូមមកសូមគ្មានស្បើយ   ក្សត្រក្សាន្តត្រានត្រើយ ល្ហៃល្ហើយស្មោះសារ ។
គបគុណដោយបុណ្យបវរ   ទសពិធរាជធម៌   ប្រពៃថ្ងៃថ្វា ។
ព្រះអង្គស្តេចទ្រង់ឧស្សាហ៍   រក្សាសីលា   ជាប់ជាប្រក្រតី ។
ប្រឹតប្រៀនខ្ញុំនានប្រុស.ស្រី ពស្ដុតាសចក្រ បានក្ដីសុខសាន្ត ។
ស្រោចស្រង់មនុស្សផងគ្រប់ប្រាណ   ដោយក្ដីស្មោះស្មាន ពុំខានឡើយណា ។
ពស្ដុគ្រប់ទួសពុកាយា   សឹងស្ម័គ្ររក្សា   សីលាទីទៃ ។
បានសុខឥតទុក្ខឥតភ័យ ដោយបុណ្យជៀសជ័យ ភូវ័យអម្ចាស់ ។
បើប្រៀបផ្ទឹមធៀបឲ្យច្បាស់ ដូចព្រះពុទ្ធម្ចាស់ ទើបត្រាស់ជាថ្មី ។
ឯមនុស្សទាំងប្រុសទាំងស្រី   ឥតទុក្ខអ្វីៗ សប្បាយគ្រប់ប្រាណ ។
ថ្ងៃពីពោធិ៍សត្វសាន្ត   ធ្វើបុណ្យស៊ីនូវទាន ពុំមានលោះលា ។
លង់លុះដល់អស់ជន្មា   ទៅសោយសុខជា នាសួគ៌ាល័យ ។
ឯក្សត្រកិទ្ធតែជៀសជ័យ   បំណោរបវរ   កើតជាទេវទត្ត ។

---

១ អានថា ជន-នៈសា; ពាក្យត្រូវគឺជន្នវស្សា ។

បុរស ៤ នោះប្រាកដ សុទ្ធសឹងក្លាំងក្លាត់ ឃាត់ទៅអរិចិ ។
ទេវីសុទ្ធិវតី យោនយកមកខ្ញី ជាវិសាខា ។
អនន្តរតនគន់នោះណា ជាបតិព្វក មហាកិកុនី ។
សុខត្តរតនក្សត្រី កំណើតកើតខ្ញី ជាស្រីពិម្ពា ។
ឯបុត្រវិសុទ្ធសោភា យោនយកមកជា ព្រះរាហុលជាក់ ។
អស់ពលសកលសេវក ស្តេចសាមន្ត គ្រប់នាក់ប្រុសស្រី ។
ទាំងមហាសេនាសេនិយ អមាត្យមន្ត្រី សម័យនោះថ្លាត់ ។
ប្រាកដជាពុទ្ធបរិស័ទ្យ បានលុះបរមត្ថ តាមព្រះសាស្តា ។
ខ្លះនោះពុំលុះសច្ចា កំផ្ទើសម្មា- បដិបត្តិឥតឈោះ ។
ឯអន្តបមពន្យំពោះ សំសៅរអង្គនោះ កុំមោះសង្ស័យ ។
គឺច្បាស់ជាព្រះពុទ្ធថ្លៃ សាសនាទៅញ សត្វថ្លៃនេះហោង ។
សន្តោសទេសន៍ប្រោសសត្វផង រួចប្រាណបានធ្ងន់ រំលងទុក្ខភ័យ ។
ខ្លះកំឡើងសួគ៌ាល័យ ដោយបុណ្យបារមី ប្រែមប្រិយសុខុម ។
ឱ ៈ ឱ ! ពុទ្ធោ ! យើងខ្ញុំ អភ័ព្វពេកពុំ ទាន់អង្គទ្រង់ញាណ ។
ព្រះអង្គស្តេចទ្រង់និព្វាន ទុកតែធម្មយាន ជាទានខ្ញុំម្ចាស់ ។
យើងខ្ញុំពិតពុំទាន់ព្រះ គឺបានទាន់ច្បាស់ តែព្រះសាសនា ។
ពុំបានយល់ថ្នាកក្រា ពុំបានស្តាប់មហា- ទេសនាទៀតផង ។
ថ្វាថ្វីសំដែងវែងចង ពីព្រះច្បាស់ច្បង ចប់ហោងហើយណា ។
រឿងព័ររព្រះវេស្សន្តរ សូរេចគាថា ទិដ្ឋិគាឯវំ ។

---

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## បរិយាយពីវិធានការនៃក្រុមជំនុំ

នៅឆមាសទី ១ ឆ្នាំ ១៩៥៦

## លោក ប៉ាប-ពីន រៀបរៀង

---

នៅឆមាសទី១ឆ្នាំ១៩៥៦នេះ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានបើកទូកាសប្រឡងប្រជែងជ្រើសយកឯកសារទំនៀមទម្លាប់ខ្មែរ ១ រឿង ស្ដីពីទំនៀមសត្វផ្សេងៗ ដើម្បីប្រមូលឯកសារអារ្យធម៌ខ្មែរមករក្សាទុក ជាគោលចារឹកប្រទេសខ្មែរតទៅ ។

ក្រុមជំនុំបានទទួលឯកសាររឿងនេះជាច្រើន អំពីបេក្ខជនជាបព្វជិតខ្លះ គ្រហស្ថខ្លះ ដែលជាអ្នកចេះដឹងបានសរសេរមកដាក់ប្រឡង ហើយក្រុមជំនុំបានជួបជុំពិនិត្យឯកសារទាំងនោះទៅ ឃើញបានលទ្ធផលដូចតទៅនេះ ៖

— លោក គង់-ចន្ទន: នៅផ្សារព្រៃទទឹង ឃុំព្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម បានជាប់លេខ ១ ត្រូវបានរង្វាន់ ៤០០៛,០០ ;

— នាង អៀង-សុវណ្ណនារី នៅផ្ទះលេខ ១០ មហាវិថីព្រះបាទនរោត្តម ក្រុងភ្នំពេញ បានជាប់លេខ ៣ ត្រូវបានរង្វាន់ ២០០៛,០០ ;

— លោក ទេព-រស់ នៅឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ បានជាប់លេខ ៣ ត្រូវបានរង្វាន់ ២០០៛,០០ ;

— លោក អៀង-សៀង នៅផ្ទះលេខ ៧៨ វិថីព្រះអង្គយុគន្ធរ ក្រុងភ្នំពេញ បានជាប់លេខ ៤ ត្រូវបានរង្វាន់ ១០០៛,០០ ;

លោក ឡឹ ភ៉ន នៅឃុំកក្កុង តំបន់តានី ស្រុកបន្ទាយមាស ខេត្តកំពត បានជាប់លេខ ៤ ត្រូវបានរង្វាន់ ១០០៛,០០ ។

ក្រៅពីការប្រឡង, នៅឆមាសទី ១ ឆ្នាំ ១៩៥៦ នេះ ក្រុមជំនុំ បានទទួលឯកសារទំនៀមទម្លាប់ជាច្រើនទៀត អំពីសមាជិកឆ្លើយឆ្លង ដែលយកចិត្តទុកដាក់ជួយឈឺឆ្អាលកិច្ចការរបស់ក្រុមជំនុំ ហើយដែលស្គាល់ប្រយោជន៍នៃការថែរក្សាទំនៀមទម្លាប់របស់ជាតិ បានធ្វើអំណោយមក ។ ក្រុមជំនុំអរគុណយ៉ាងខ្ពស់ចំពោះអំណោយនេះ សូមថ្លែងប្រកាសនាមអស់លោកជាសមាជិកទាំងនោះ ដូចតទៅ ៖

— ព្រះតេជព្រះគុណ ព្រហ្ម-គង់ មេគណ ខេត្តកំពង់ធំ បានឲ្យឯកសារ ១ រឿង ស្តីពីទង់ក្រតើ នឹងទង់ព្រលឹង ;

— លោក ម៉ម-នេត អាចារ្យវត្តសន្ទុកក្រៅ ឃុំក្រកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ បានឲ្យឯកសារ ១ រឿង ស្តីពីពិធីលើកពសី;

— លោក ខឹម-មាស នៅភូមិគួប ឃុំក្រាំងស្វាយ ស្រុកឈូក ខេត្តកំពត បានឲ្យឯកសារ ២ រឿង ស្តីពីគ្រឿងតំណាង ១ ពិធីលើកពសី ១ ;

— លោក វង្ស-ណែត នៅភូមិអង្គចេក ឃុំកក្កុង(តំបន់តានី) ស្រុកទូកមាស ខេត្តកំពត បានឲ្យឯកសារ ២ រឿង ស្តីពីគ្រឿងតំណាង ១ ពិធីលើកពសី ១ ;

— លោក សុខ-ព្រហ្ម នៅភូមិព្រែកគុយ ឃុំលាយបូរ ស្រុក

ត្រាកក់ ខេត្តតាកែវ បានឲ្យឯកសារ ២ រឿង ស្ដីពីគ្រឿងតំណាង ១ ពីធីលើកកសី ១ ;

- លោកអាចារ្យ សួន-វង្ស នៅឃុំព្រែកក្មៅ ស្រុកពញាឮ ខេត្តកណ្ដាល បានឲ្យឯកសារ ១ រឿង ស្ដីពីធម៌សូត្រលើកកសី;

- លោក ម៉ាយ-សារិន គង់គ្រូខេត្ត នៅមន្ទីរឃោសនាការ ស្រុកឆ្លូង ខេត្តក្រចេះ បានឲ្យឯកសារ ១ រឿង ស្ដីពីសត្វ;

- លោក ដួង-ហាវ នៅភូមិត្រពាំងឈូក ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប បានឲ្យឯកសារ ២ រឿង ស្ដីពីរឿងព្រេងក្រពើ ១ រឿងព្រេងពាក់ទងនឹងភូមិស្រុក ១ ;

- លោក កិត្ត ចាយ-សាំងអ៊ី គង់វត្តពោធិ៍ជ័យ (រអាងក្រោម) ឃុំរអាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម បានឲ្យឯកសារ ១ រឿង ស្ដីពីត្រី ;

- លោក ខៀវ-ភ៉ន នៅឃុំក្នុកក្នុង ស្រុកបន្ទាយមាស ខេត្តកំពត បានឲ្យឯកសារ ១ រឿង ស្ដីពីសត្វផ្សេងៗ ;

- លោក កែវ-ហង្ស អតីតចាងហ្វាង នៅឃុំស្នួល ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម បានឲ្យឯកសារ ១ រឿង ស្ដីពីសត្វផ្សេងៗ ;

- លោកគ្រូ ចាប-ចន្ទ គង់វត្តក្ដីក្រៅ ឃុំខ្នារស ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម បានឲ្យឯកសារ ១ រឿង ស្ដីពីសត្វផ្សេងៗ ;

- លោក គីម-ម៉ាន នៅឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្ដាល បានឲ្យឯកសារ ១ រឿង ស្ដីពីសត្វផ្សេងៗ ;

- លោកស្រី - អ៊ូ ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានឲ្យឯកសារ ២ រឿង ស្តីពីសត្វជាប្រផ្នូលល្អអាក្រក់ ១ ត្រីកូនរឿងព្រេង ១ ;

- លោក អៀង - សឿង នៅផ្ទះលេខ ៧៨ វិថីព្រះអង្គយុគន្ធរ ក្រុងភ្នំពេញ បានឲ្យឯកសារ ១ រឿង ស្តីពីសត្វ ;

- នាង អៀង - សុវណ្ណនារី នៅផ្ទះលេខ ១០ មហាវិថីព្រះបាទនរោត្តម ភ្នំពេញ បានឲ្យឯកសារ ១ រឿង ស្តីពីសត្វផ្សេង ។ ;

- លោកប៉ាង - ខាត់ ធ្វើការនៅរោងពុម្ពអ៊ុក - ម៉ុកុល ក្រុងភ្នំពេញ បានឲ្យឯកសារ ១ រឿង ស្តីពីត្រីកូនរឿងព្រេង ;

- លោក ទេព - រស់ នៅឃុំលំចង់ ស្រុកសំរោង ខេត្តតាកែវ បានឲ្យឯកសារ ១ រឿង ស្តីពីសត្វផ្សេង ។ ។

អស់លោកទាំងពីរក្រុមដូចរាយនាមខាងលើ ដែលបានសរសេរឯកសារទៅដាក់ប្រឡងក្តី ទៅធ្វើអំណោយក្តី ក្នុងឆមាសទី ១ ឆ្នាំ ១៩៥៦ នេះឈ្មោះថាបានជួយឧបត្ថម្ភកិច្ចការរបស់ក្រុមជំនុំទំនៀមទម្លាប់ ដែលកំពុងស្រាវជ្រាវរកទំនៀមទម្លាប់ខ្មែរ ហើយដែលជាឧត្តមកិច្ចញុំាងប្រទេសជាតិឲ្យចំរើនឲ្យឋិតថេរគង់វង្សអស់កាលជាអង្វែងតទៅ ។

នៅទីបញ្ចប់, ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ សូមអំពាវនាវអស់លោកអ្នកជាបេក្ខជន ដែលធ្លាប់បានសរសេរឯកសារទំនៀមទម្លាប់ប្រឡងរួចមកហើយ សូមឲ្យសរសេរប្រឡងទៀត និងអស់លោកអ្នកជាសមាជិកផ្ញើជូនដែលធ្លាប់បានសរសេរឯកសារធ្វើអំណោយរួចហើយ ក៏សូមឲ្យ

សរសេរធ្វើអំណោយទៀត ។ ចំណែកអស់លោកអ្នកដែលមិនធ្លាប់ជាបេក្ខជន ឬជាសមាជិកឆ្លើយឆ្លងទេ បើបានឃើញបានជ្រាបប្រកាសប្រឡងបីក្នុងឆមាសទី ២ ឆ្នាំ ១៩៥៦ នេះ ដែលក្រុមជំនុំទំនៀមទម្លាប់បានចែកផ្សាយនោះ ហើយបើបានឆ្លៀតឱកាសសរសេរឯកសារតាមសំនួរក្នុងប្រកាសនោះ ទៅដាក់ប្រឡង ឬទៅធ្វើអំណោយ ដោយប្រាថ្នានឹងជួយទំនុកបម្រុងកិច្ចការស្រាវជ្រាវរកឯកសារទំនៀមទម្លាប់តទៅ នោះក្រុមជំនុំសូមទទួលអំណរគុណយ៉ាងខ្ពស់ទុកជាមុន ។

## ពាក្យអំពាវនាវ

សព្វថ្ងៃនេះកម្ពុជរដ្ឋ កំពុងត្រូវកត់ត្រូវរក្សា
ទំនៀមទម្លាប់ជាតិខេមរា សព្វយ៉ាងមិនថាទំនៀមអ្វី ។
ឲ្យតែទំនៀមជាតិខ្មែរយើង ដែលកើតមានឡើងនៅទឹកដី
កម្ពុជរដ្ឋទោះចាស់ថ្មី ក៏ត្រូវឃ្នាតខ្ទីកត់រៀបរាប់ ។
ហេតុនេះអស់លោកវិញ្ញូជន ដែលមានចិត្តធ្ងន់ក្នុងទម្លាប់
ទំនៀមជាតិខ្មែរដែលខ្មែរធ្លាប់ កាន់ជាប់ជាយូរអង្វែងឆ្ងាយ ។
សូមឆ្លៀតឱកាសសរសេរតែង ឯកសារចារចែងថ្លែងបរិយាយ
ទំនៀមទម្លាប់ខ្មែរទាំងឡាយ អធិប្បាយប្រាប់ដើមកំណើតផង ។
តាមគោលសំនួរដែលពួកក្រុម ជំនុំបានសួរជាទំនង
នៅក្នុងប្រកាសការប្រឡង ប្រាំមួយខែម្តងជាទម្លាប់ ។
ឯកសារលោកណាល្អគ្រប់គ្រាន់ នឹងបានរង្វាន់យ៉ាងគួរគាប់
តាមលេខខ្ពស់ទាបដែលបានជាប់ ជាភ័ព្វនៃអ្នកនិពន្ធអើយ ។

បាប-ពិន

# កំណត់ជីវប្រវត្តិការណ៍

## មន្ទីរពេទ្យព្រះសង្ឃ

## បានកើតឡើងនៅខែត្រតាកែវ

ពុទ្ធសាសនបណ្ឌិត្យ

(ត—ចប់)

---

ទោះក្នុងសម័យពីបុរាណក្តី បច្ចុប្បន្ននេះក្តី បច្ច័យបួន ជាមធ្យោបាយលៀងជីវិតព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ឲ្យប្រព្រឹត្តទៅបានស្រួលក្នុងព្រហ្មចរិយធម៌ សមដូចពាក្យដែលលោកទាំងមូលបបួលគ្នានិយមថា ជីវភាពខ្ពង់ខ្ពស់ ។

ពិភពលោកក្នុងបច្ចុប្បន្នកាលនេះ កំពុងខំប្រឹងកសាងជីវភាពប្រជាជនឲ្យរស់នៅដោយស្រួល ដោយផ្តល់ឲ្យមាន ៖ ១– គ្រឿងស្លៀកពាក់, ២– អាហារបរិភោគ, ៣– ទីលំនៅ ៤– ឱសថកែរោគ; ទាំងបួនប្រការនេះ ឲ្យមានបរិបូណ៌យ៉ាងណា ក្នុងព្រះពុទ្ធសាសនាទាយកទាយិកា ក៏មានភារៈផ្តល់បច្ច័យទាំង ៤ គឺ ១– ចីវរ, ២– បិណ្ឌបាត, ៣– សេនាសនៈ, ៤– ភេសជ្ជ; ប្រគេនដល់ព្រះសង្ឃយ៉ាងនោះដែរ ព្រោះមនុស្សលោកដែលនឹងរស់នៅបាន ក៏ដោយអាស្រ័យបច្ច័យទាំង ៤ នេះឯង បើខ្វះខាតបច្ច័យណាមួយហើយមនុស្សក្នុងពិភពលោក មិនអាចរស់នៅបានទេ បានសេចក្តីថា បើមានតែគ្រឿងស្លៀកពាក់គ្មានអាហារ គ្មានទីលំនៅ គ្មានឱសថកែរោគទេ មនុស្សរស់នៅមិនបាន, មានតែគ្រឿង

ស្បៀកពាក់និងអាហារ តែខ្វះខាតទីលំនៅខ្វះឱសថកែរោគ មនុស្សរស់នៅមិនបានដែរ មានតែគ្រឿងស្លៀកពាក់អាហារនិងទីលំនៅ ហើយគ្មានឱសថកែរោគ មនុស្សក៏រស់នៅមិនបានទៀត ព្រោះមនុស្សយើងរមែងមានរោគតាមជាប់និច្ចជាសត្រូវធំ សម្រាប់បំផ្លាញសេចក្ដីសុខ បើមិនបានសុខភាពហើយ គេមនុស្សធ្វើសេចក្ដីចំរើនឲ្យលោកដូចម្ដេចបាន ។

ព្រះពុទ្ធការសិតបានត្រាស់មួយកន្លែងថា: "ការមិនមានរោគ ជាលាភមួយយ៉ាងធំរបស់មនុស្ស" ។ ប៉ុន្តែការស្វែងរកបច្ច័យទាំង ៤ ដើម្បីយកមកលៀងជីវិតនេះមិនមែនគ្រាន់តែសម្រាប់ឲ្យរស់នៅប៉ុណ្ណោះទេ គឺថាកាលបើរស់នៅស្រួលហើយ ត្រូវបំពេញប្រយោជន៍ខ្លួននិងប្រយោជន៍សង្គមជាតិ ព្រមទាំងបំពេញកុសលធម៌ដទៃទៀត មានសីលធម៌ជាដើម ដើម្បីសេចក្ដីសុខធំមួយរបស់ទាំងអស់គ្នា និងដើម្បីកសាងខ្លួនឲ្យទៅជាអារ្យជន, កាលបើប្រទេសណាមានអារ្យជនបរិបូណ៌ហើយ ប្រទេសនោះក៏បាននាមថា អារ្យប្រទេស ដោយពិតប្រាកដ ។

មន្ទីរពេទ្យបាលអាពាធព្រះសង្ឃនេះកសាងឡើងសម្រាប់ផ្ដល់បច្ច័យទី ៤ គឺថ្នាំកែរោគបំពោះព្រះសង្ឃទូទៅ ដើម្បីឲ្យពុទ្ធសមណៈរស់នៅបានដោយសុខស្រួលមានអនាម័យល្អ មានឱកាសរៀនសូត្របំពេញសមណធម៌ ព្រហ្មចរិយធម៌ ហើយនិងពង្រីកព្រះពុទ្ធសាសនាឲ្យផ្សាយទូទៅពេញសាកលលោក ឲ្យពិភពលោកបានទទួលក្រេបរសជាតិសន្តិភាពពិត តាមព្រះពុទ្ធសាសនា ព្រមទាំងជួយប្រៀនប្រដៅជន

រួមជាតិយើង ឲ្យជាសម្មាទិដ្ឋិ តាំងនៅក្នុងចរិយាដ៏ខ្ពង់ខ្ពស់ សមជាអារ្យពលរដ្ឋមានវិន័យដ៏ប្រសើរ ។

ខ្ញុំព្រះករុណា ‑ ខ្ញុំ សូមឆ្លៀតយកឱកាសនេះ ថ្លែងសេចក្ដីសរសើរ និងសេចក្ដីត្រេកអរចំពោះគណៈកម្មាធិការ ចាត់ការកសាងមន្ទីរគិលាន-សង្គ្រោះចំពោះព្រះសង្ឃក្នុងខេត្តតាកែវនេះ ចំពោះបរិស័ទទាំងឡាយក្នុងខេត្ត ដែលបានរួបរួមកម្លាំងសទ្ធាគ្នាយ៉ាងមុឹងម៉ាត់ ក្នុងការកសាងមន្ទីរចែកសេចក្ដីសុខដល់ព្រះសង្ឃឲ្យបានកើតឡើងនេះ ។ នៅក្នុងខេត្តនៃព្រះរាជអាណាចក្រកម្ពុជា ក្រៅអំពីសៀមរាបនិងរាជធានីចេញ ពុំទាន់មានខេត្តណាមួយបានកសាងមន្ទីរព្យាបាលរោគព្រះសង្ឃឲ្យបានកើតដូចខេត្តតាកែវនេះទេ ។ អំពើកុសលយ៉ាងសុក្រិតនេះសន្មតថាពុទ្ធបរិស័ទខេត្តតាកែវបានរកឃើញផ្លូវល្អ ហើយអាចសង្ឃឹមថា អំពើល្អដ៏ថ្លៃថ្លានេះមុខជានឹងសាយភាយទៅប្រតិស្ឋាននៅខេត្តដទៃ ៗ ក្នុងកាលអនាគតដ៏ឆាប់នេះជាពុំខាន ។

ការកសាងដូច្នេះនេះ លុះត្រាតែមាននយោបាយយល់ត្រូវទើបធ្វើទៅកើត ហើយនយោបាយនេះស្របទៅតាមនយោបាយនៃព្រះរាជ-រដ្ឋាភិបាល ដែលមានព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង និង សម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះឧបយុវរាជ ជាប្រមុខ ដែលព្រះអង្គតែងមានព្រះរាជបំណងជានិច្ច ចង់បំបាត់អាពាធព្រះសង្ឃ និងរោគាព្យាធិប្រជាជនរបស់ព្រះអង្គ ព្រោះថាជម្ងឺប្រជាជនក៏គឺជម្ងឺព្រះអង្គ ។

អ្នកមានជម្ងឺគឺអ្នកមានទុក្ខ មន្ទីរព្យាបាលព្រះសង្ឃ ជាមន្ទីររម្ងាប់

កេត រម្ងាប់ទុក្ខ ជាមេបុណ្យមួយដ៏ធំសម្រាប់អ្នកប្រាថ្នាបុណ្យ សមដូចព្រះតម្រាស់ព្រះសម្ពុទ្ធថា "អ្នកព្យាបាលព្រះសង្ឃឈ្មោះថាព្យាបាលតថាគត" សេចក្ដីនេះបញ្ជាក់ថា យើងបានបំរើព្រះបរមសម្មាសម្ពុទ្ធគ្រប់ៗគ្នា បានអានិសង្សច្រើនអនេកអនន្ត ដែលស្របនឹងព្រះពុទ្ធដីកាមួយព្រះទស្សទៀតថា "អ្នកមានប្រាជ្ញាជាអ្នកឲ្យសេចក្ដីសុខគេ ត្រូវមានសេចក្ដីសុខមកដល់ខ្លួនវិញ" ។

ទីបំផុត ខ្ញុំព្រះករុណា ខ្ញុំ សូមបួងសួងគុណព្រះរតនត្រ័យ សូមមេត្តាប្រោសអភិបាលរក្សាព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្ដេចព្រះមហាក្សត្រិយានី នឹងសម្ដេចព្រះឧបយុវរាជ ព្រមទាំងអស់លោក អ្នកជាពុទ្ធបរិស័ទ គណៈកម្មាធិការ កសាងមន្ទីរព្យាបាលព្រះសង្ឃនេះ ដោយកម្លាំងទ្រព្យក្ដីកម្លាំងកាយក្ដី សូមឲ្យបានសេចក្ដីសុខសួស្ដីសិរីវឌ្ឍន៍ ប្រាសចាកទុក្ខភេទភ័យគ្រប់ប្រការ សមតាមសេចក្ដីប្រាថ្នាកុំបីឃ្លាត ! ។

*

* *

## សុន្ទរកថាព្រះអាចារ្យសោម - ស៊ឹម

បន្ទាប់មកភិក្ខុសោម - ស៊ឹម អាចារ្យបង្រៀនបាលី វត្តសីហរតនារាម (តាកែវ) ថ្លែងសុន្ទរកថាតំណាងព្រះតេជព្រះគុណ ព្រះមង្គលទេព្វលោកវង្ស មេគណខេត្តតាកែវ មានសេចក្ដីដូចតទៅនេះ៖

សូមថ្វាយបង្គំ ពិតថេរដីកាព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមចំរើនពរលោករដ្ឋលេខាធិការក្រសួងធម្មការនឹងឃោសនាការជាតិ ទាំងសហ-

ការ ព្រមទាំងអស់ពុទ្ធបរិស័ទទាំងឡាយដែលបាននិមន្តបានអញ្ជើញមក ជាអធិបតីជាកិត្តិយសក្នុងទីនេះ

សូមទានជ្រាប សូមជ្រាប ។

ក្នុងឋានៈជាតំណាងព្រះតេជគុណ ព្រះមង្គលទេព្វលោកវង្ស មេ. គណខេត្តតាកែវ ខ្ញុំព្រះករុណាអាត្មាភាព សូមថ្លែងនូវសក្ខីជាមួយ ដើម្បីជាកិច្ចរំលឹកនូវដំនាន់នៃការស្ថាបនាមន្ទីរពេទ្យព្រះសង្ឃនេះ និង គោរពទទួលនូវសមានចិត្តនៃព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងអស់ លោកជាឥស្សរជនទាំងអស់លោកសប្បុរសទាំងឡាយ ក្នុងពេលធ្វើបុណ្យ សម្ពោធមន្ទីរពេទ្យ ដែលគណៈកម្មការចាត់ចែងឡើងក្រោមអធិបតីភាព នៃលោកជាប្រមុខខេត្តតាកែវ ។

ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ !

អស់លោកសប្បុរសទាំងឡាយ !

ក្នុងនាមនៃព្រះតេជព្រះគុណព្រះមង្គលទេព្វលោកវង្ស មេគណខេត្តតាកែវ សូមសំដែងនូវមនោសញ្ចេតនាដ៏ជ្រាលជ្រៅ បីតាប្រាមោទ្យយ៉ាងក្រៃលែងចំពោះស្វាគមន៍ នៃព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ លោករដ្ឋលេខាធិការ លោកសប្បុរសទាំងឡាយក្នុងទីប្រជុំនេះ ។

ការចាប់កំណើតនៃមន្ទីរពេទ្យនេះជាដំបូងនៅឆ្នាំ ១៩៥៣ ខែកញ្ញា ដោយមកពីលោក អៀប - ហុងលីម អតីតចៅហ្វាយខេត្តតាកែវ និង លោកប៉េ កេងហ៊ាន អតីតគ្រូពេទ្យនាយក ព្រមទាំងអស់លោកជាក្រុមសមាជិកទាំងអស់ ដូចមានរាយនាមក្នុងការបូកកញ្ចក់នេះស្រាប់ ។

កល្យាណកម្មដ៏ត្រកាលនេះ កើតឡើងភ្លាមក៏ចាប់មានការស្រែកអំពាវនាវឃោសនាគ្រឿងសម្ភារៈប្រាក់កាសសម្រាប់សាងមន្ទីរពេទ្យនេះ ដល់ព្រះករុណាគ្រប់ព្រះអង្គក្នុងខែត្រទាំងមូល មានព្រះតេជព្រះគុណអនុគណចៅអធិការ ដោយមានឧបាសកឧបាសិកាជាកំឡាំង ។

ការឃោសនានេះបើគិតតាំងពីសេចក្ដីព្រាងជាបឋម គឺជំនាន់លោកអៀប - ហុងលឹម អតីតចៅហ្វាយខែត្រតាកែវ បានចាប់ផ្ដើមធ្វើបុណ្យផ្កាឃោសនាពីរលើក មកដល់ជំនាន់លោកឡា - ប៊ុនប៉ា អតីតចៅហ្វាយខែត្រ ដែលទើបនឹងផ្លាស់ទៅថ្មីៗនេះ បានចាត់ឃោសនាម្ដងទៀតជាគំរប់បីលើក ។ បច្ច័យទាំងអស់ដែលបានមកពីព្រះករុណាគ្រប់ព្រះអង្គគ្រប់វត្ត ក្នុងខែត្រទាំងមូល និងខែត្រដទៃជាច្រើន និងក្រុមអស់លោកជាសមាជិកគ្រប់ចៅក្រសួង ព្រមទាំងសហការីនៃភ្នាក់ងាររាជការ តាំងពីក្រុងខែត្រជាដើម រហូតទៅដល់ស្រុកឃុំជាទីបំផុតនោះ បានចំនួន ៣០០.០០០រ, (បីសែនរៀល) ដែលបានចំណាយរួចទៅលើមន្ទីរពេទ្យនេះ ។ ឯការយឺតដំណើរក្នុងការធ្វើឲ្យបានរូបរាងជាមន្ទីរ-ពេទ្យនេះរួចស្រេចបាច់នោះ ដោយមកពីមានការផ្លាស់ប្ដូរនៃលោកដែលជាដើមគំនិតទាំងប៉ុន្មាន មានលោកអៀប - ហុងលឹម ជាចៅហ្វាយខែត្រ និងលោកបេ - កេងហ៊ាន ជាដើម ។ តែបើទុកណាជាមានឧបសគ្គស្ទាក់-ឲ្យយឺតយ៉ាងណាក៏ដោយ ក្នុងជំនាន់នៃលោកឡា - ប៊ុនប៉ា និងលោកគ្រូពេទ្យនាយក យិត - គិមសេង បច្ចុប្បន្ននេះ លោកបានពូតផ្គុំអស់លោក

ជាក្រុមសមាជិកចាប់ផ្តើមស្ថាបនា ត្រាតែហើយស្រេចជាស្ថាពរ ដូចព្រះតេជព្រះគុណអស់លោកជ្រាបឃើញដោយប្រចក្សក្នុងពេលនេះ ។

គួរឲ្យរំភើបចិត្តយ៉ាងក្រៃលែង ចំពោះអស់លោកគណៈកម្មការស្ថាបនាមន្ទីរពេទ្យព្រះសង្ឃនេះ ដែលតាំងពីកាលណាមកអស់លោកតែងមមាញឹកក្នុងករណីយកិច្ចផ្ទាល់ខ្លួនគឺការងាររបស់រាជការរដ្ឋាភិបាល ។ អស់លោកបានឆ្លៀតឱកាសផ្តើម នូវឧត្តមកម្មដ៏វិសិដ្ឋនេះឲ្យកើតឡើង ដែលជាគ្រឿងដោបង្ហាញនូវឧត្តមគតិ របស់ពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់ លាតសន្ធឹងនូវគំនិតសប្បុរសស្មោះចំពោះប្រាកដជាពុទ្ធសាសនិកជន ទាំងនាម៉ឺនទាំងរាស្ត្រសមត្រូវទៅតាមព្រះរាជបំណង នៃព្រះករុណាជាអម្ចាស់ជីវិត សម្តេចសហជីវិន នរោត្តម-សីហនុ ឧបយុវរាជ ដែលទ្រង់អំពាវ-នាវដល់ប្រជាពលរដ្ឋគ្រប់ហុនៈ ដើម្បីពួតដៃគ្នាធ្វើកិច្ចការកុំមើលបំណាំ ៗ ប្រទេសកម្ពុជាមានកេរ្តិ៍មតិកបីយ៉ាងគឺ ជាតិ-សាសនា-ព្រះមហាក្សត្រិយ៍ ដែលបុព្វបុរសរបស់យើងទុកឲ្យ ។

ចំពោះព្រះពុទ្ធសាសនា ពលរដ្ឋខ្មែរភ្ជាប់ខ្ជាប់ហើយលើកតំកើងជាយូរសតវត្សណាស់មកហើយ, មន្ទីរពេទ្យព្រះសង្ឃនេះ គួររាប់ថាជាសម្បត្តិរបស់ប្រទេសកម្ពុជាផង ជាមហាកុសលយ៉ាងមហស្ចារ្យចំពោះផ្លូវសា-សនាផង ដោយចំពោះទៅគឺជាកិត្តិយសដល់ខែត្រតាកែវយើងនេះឯង ។ សូមឲ្យព្រះករុណាគ្រប់ព្រះអង្គ អស់លោកជ្រាបថា បណ្តាមន្ទីរពេទ្យព្រះសង្ឃពុទ្ធសាសនិកប្រទេសកម្ពុជា មន្ទីរពេទ្យនេះជាទី ៣ បន្ទាប់អំពីគិលានសង្គ្រោះចំពោះព្រះសង្ឃក្រុងភ្នំពេញ និងខែត្រសៀមរាបមក,

ខែត្រនានាដទៃទៀតមិនទាន់មាននៅឡើយទេ ។ ពីពេលនេះទៅថ្ងៃមុខ ភិក្ខុសាមណេរដែលមានអាពាធ ត្រូវនិមន្តមកព្យាបាលរោគ លែងលំបាក លែងប្រឡូកប្រឡំដោយឧបាសកឧបាសិកាទៀតហើយ គឺយើងមានកន្លែងដាច់ដោយឡែក បានដល់ទីនេះឯង ។

ម្យ៉ាងទៀត មន្ទីរពេទ្យដែលធ្វើហើយរួចជាស្រេចនេះ ជាសាលសម្រាប់ព្រះសង្ឃមានអាពាធសឹង នៅខ្វះរោងថែវមួយទៀត ជាកន្លែងសម្រាប់ស្នាក់នៃវេយ្យាវច្ចកររបស់ភិក្ខុ-សាមណេរអ្នកជម្ងឺ ។ ព្រោះថាភិក្ខុសាមណេរដែលមានអាពាធ ហើយនិមន្តមកសឹងព្យាបាលរោគក្នុងមន្ទីរពេទ្យ មិនលែងមានជាប់ដោយឧបាសកឧបាសិកាគេនាំមកជាមួយផងទេ ដើម្បីកុំឲ្យមានការប្រឡូកប្រឡំនោះ ត្រូវតែធ្វើរោងថែវមួយតួបល្មមនៅក្បែរគ្រឹះស្ថានធំនេះ ។

ទ្រឹស្ដីជាកុសលម្យ៉ាងទៀត របស់លោកគ្រូពេទ្យនាយក យិត-គិមសេង បច្ចុប្បន្ននេះថា អំណើះតទៅអនាគត បើហើយកិច្ចការដែលត្រូវធ្វើរួចជាស្រេច ដើម្បីជួយបន្ធូរការៈបំណាយនៃថវិកាជាតិខ្វះកុំឲ្យខ្វះខាត គ្រឿងសម្ភារៈផ្សេងៗសម្រាប់មន្ទីរពេទ្យនេះ មានថ្នាំព្យាបាលរោគជាដើមនោះ ត្រូវពួតដៃគ្នាមិនរើសមុខប្រមូលបច្ច័យយកទៅទិញថ្នាំមកទុកបំរុងក្នុងទីនេះ ជាគ្រឿងជំនួយដល់ថ្នាំដែលរាជការចែកឲ្យមកកុំឲ្យខ្វះខាត ។ រឿងនេះព្រះតេជៈព្រះគុណ ទាំងអស់លោកអ្នក សប្បុរសទាំងឡាយ គង់ជ្រាបថា: ព្រះសម្ពុទ្ធបរមគ្រូរបស់យើងព្រះអង្គទ្រង់ប្រកាសសំដែងជាឧឡារិកថា: ភិក្ខុសាមណេរណា បានយកចិត្តទុកដាក់បំរើជម្ងឺនៃភិក្ខុ

សាមណេរផងគ្នាដែលមានធម៌ ក៏កុំសាមណេរនោះឈ្មោះថាបានបំរើតថាគតផ្ទាល់ ។

ចុះពេលនេះយើងមិនបានមកបំរើផ្ទាល់ដោយខ្លួនយើងមែន តែកម្លាំងនៃចេតនាយើង បានលះទ្រព្យសម្បត្តិយកសាង តាំងពីមន្ទីរពេទ្យរហូតដល់ថាំផាដើមទៀត គង់បានឈ្មោះថាយើងជួយបំរើព្រះសម្ពុទ្ធ ឬព្រះពុទ្ធសាសនាដោយសព្វគ្រប់ ។ ហើយពេលនេះគឺជាជោគវាសនារបស់យើងផង នៅតែប៉ុន្មានខែទៀតទេ នឹងដល់ពាក់កណ្តាលព្រះពុទ្ធសាសនា គំរប់ ២.៥០០ ឆ្នាំ ដែលពិភពលោកទាំងមូលជនអ្នកកាន់ព្រះពុទ្ធសាសនា នឹងធ្វើបុណ្យជាខ្លាំងក្លារិក ដើម្បីគោរពនឹងបួងសួងឲ្យព្រះពុទ្ធសាសនារុងរឿងបានគ្រប់ ៥.០០០ ឆ្នាំ សរសើរកិត្តិដីរិតដែលកើតមកហើយ សេនៅពាទពាក់កណ្តាលព្រះពុទ្ធសាសនាទាំងមានសេចក្តីសង្ឃឹមជាទីបំផុតថា ព្រះពុទ្ធសាសនាគង់ពេលគំរប់ ២.៥០០ ឆ្នាំនឹងសាយភាយ ឬស្រែកដង្ហោយហៅ ភាញចំបែរសន្តានចិត្តពលលោកទាំងមូលឲ្យងាកឈមមុខឆ្ពោះទៅរកសន្តិភាព ប្រាសចាកការកំហែងគម្រាមរវាងមនុស្ស មានមេត្តាករុណាចេះយោគយល់គ្នាចែកសុខចំរើនដល់គ្នានឹងគ្នា ដែលមានព្រះពុទ្ធសាសនាជាបន្ទាត់ ។

សេចក្តីដូចខាងលើនេះ ក្នុងនាមនៃព្រះមន្ទីរទិព្វលោកនៅឡើ មេគណៈខេត្តតាកែវ សូមចាត់ទុកថាជាសេចក្តីឃោសនាដល់ព្រះករុណាគ្រប់ព្រះអង្គ នឹងពុទ្ធមាមក បរិស័ទទាំងឡាយទៅអនាគត ។ ហើយមានសេចក្តីសង្ឃឹមទុកជាមុនថា ព្រះករុណាគ្រប់ព្រះអង្គ ពុទ្ធបរិស័ទ

តាំងឡាយមុខជាប្រឹងជួយញុំាងកល្យាណកម្មនេះ ឲ្យឆាប់សម្រេចជាមាំមួនមិនខាន ។

ជាទីបញ្ចប់នេះ សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណាជាអម្ចាស់ជីវិត សម្ដេចព្រះមហាក្សត្រិយានី សម្ដេចព្រះនរោត្តម-សីហនុឧបយុវរាជ បិតាឯករាជ្យ អស់លោកឥស្សរជន សប្បុរសតាំងឡាយ សូមទ្រង់ប្រកបដោយព្រះសុខមាលភាព បានសេចក្ដីសុខ និងទុក្ខនិរភ័យ កុំបីឃ្លាតឆ្ងាយទៅជាប្រការដ៏ទៃឡើយ ។

*

* *

ក្នុងពេលចប់សេចក្ដីផ្ដងៗ គេឮស្គរទះដៃលាន់រំពងទទួលអបអរសាទរ ។

ក្រោយដែលបានរេមន្ទីរពេទ្យតាមប្រពៃណីរួច លោក យិត-គិមសេង គ្រូពេទ្យនាយក បានអញ្ជើញលោកវដ្ឋលេខាធិការក្រសួងធម្មការកាត់ខ្សែក្រហមចងកាត់មាត់ទ្វារមន្ទីរពេទ្យ ដែលជានិមិត្តរូបនៃការបើកទ្វារទទួលឲ្យព្រះសង្ឃដែលមានរោគៈចូលព្យាបាលបាន តាំងពីថ្ងៃនេះតទៅ ។

នាមុនសព្វមុខមន្ត្រី ព្រះសង្ឃនិងឧបាសកឧបាសិកា ដែលបានជួបជុំនៅពេលនោះ ក៏បានចូលទស្សនាមន្ទីរពេទ្យដែលមានបន្ទប់ ៥ មានគ្រែនិងពូក ១៥; មានបន្ទប់បន្ទោរបង់ ២, ព្រមទាំងមានបន្ទប់ ១ សំរាប់ដាក់ឱសថ ។ មន្ទីរពេទ្យនេះបានរៀបចំសាងយ៉ាងស្អាត គួរជាទីសំណាក់ផ្សះរោគនៃព្រះសង្ឃមែន ។

ពិធីនេះបានចប់នៅម៉ោង ១០ កន្លះព្រឹក ។

សព្វថ្ងៃនេះ នៅព្រះរាជធានីភ្នំពេញ មានមន្ទីរពេទ្យព្រះសង្ឃយ៉ាងធំ, នៅខេត្តសៀមរាបនឹងតាកែវ មានមន្ទីរពេទ្យគួរសមល្មមរក្សាជម្ងឺព្រះសង្ឃហើយ យើងសង្ឃឹមថា ពុទ្ធបរិស័ទនៅខេត្តឯទៀតៗ មុខជាពុំបណ្តោយឲ្យខេត្តរបស់ខ្លួនខ្វះខាតមន្ទីរពេទ្យព្រះសង្ឃយូរតទៅឡើយ ។

---